ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ៣ ខែមីនា ព. ស. ២៤៩៨ គ. ស. ១៩៥៦

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា

— ពុទ្ធសរណកថា ................ មហា ហ៊ុន-ប្រិញ ............ ២០៤
— មាតាបិតុគុណកថា .. .......... ព្រះអាចារ្យ ដៃ-ម៉ៃ .......... ២១៣
— ជាតកកថារឿងពុទ្ធរូបបុរាណ ......... ឃុនអគ្គកោវិទ ជា-យូរ ........ ២២០

ផ្នែកអក្សរសាស្ត្រ

– រឿងអ្នកស្នេហាជាតិសាសនាមហាក្សត្រ.. ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ ......... ២២៨
– រឿងព្រះបាទរុស្សវ៉ានសាជ និងព្រះនាង
សេហេរិស្ដានី ................. អ្នកស្រី សារិះយ៉ាន . . . . . . ២៣៨
— សុភាសិតរាជនីតិ ពាក្យកាព្យ (តមក).. អ្នកឧកញ៉ា នៅ . . . . . . . ២៤៧
— ពេជ្រព្រះរាជា (តមក) . . . . . . . លោក ស៊ិន-ហ៊ាន . . . . . . ២៥៨
— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ-កន . . . . . . . ២៦៨
— រឿងបល្ល័ង្កទិព្យ (តមក) . . . . . . លោក វ៉ាយ-ប៊ុក . . . . . . ២៧៨
— ពុទ្ធសាសនបណ្ឌិត្យ និងព័ត៌មានអន្តរជាតិ លោក ជាប-ពិន .. ....... ២៨៤

កំណត់និងប្រវត្តិការណ៍

— ពិធីបុណ្យគំរប់ ២.៥០០ ព្រះវស្សា នៃ
ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា. ... . ពុទ្ធសាសនបណ្ឌិត្យ .......... ៤៩១
— ពិធីបញ្ចប់កិច្ចសិក្សាខាងវិជ្ជាគរុកោសល្យ
នៃសមណសាស្ត្រាចារ្យ .......... ពុទ្ធសាសនបណ្ឌិត្យ .......... ២៩៧

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២៣០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Bouddhasaranakatha . . . . . | *Moha* HUN-PRENH . . . . . | 204 |
| — Matapitugunakatha (poème) . | *Vén.* CHEY-MAY . . . . . | 213 |
| - La statue Bouddhique primitive . . . . . . . . . | *M.* CHEA-YOU . . . . . | 220 |


### PARTIE LITTERAIRE:


| | | |
|---|---|---|
| — Le Patriotisme . . . . . . . . | *M.* BOU-PO . . . . . . . | 228 |
| — La Roi RUZVANSBHAD et la Princesse CHEHECISTANI . . . | *Mme* SRIN-SARIS-YANN . | 238 |
| — Subhasitarajaniti (suite) . . . | *Oknha* NEOU . . . . . . . | 247 |
| — Conte "Le Diamant du Raja" (suite) . . . . . . . . . . | *M.* SIN-HEAN . . . . . | 258 |
| — Histoire de SAMKOK (suite). . | *Oknha* NOU-KAN. . . . . | 268 |
| — Les trente deux récits du TRONE (suite) . . . . . . . | *M.* RAY-BUC. . . . . . . | 278 |
| — L'Institut Bouddhique à l'Exposition Internationale de Phnom-Penh . . . . . . . | *M.* CHAP-PIN . . . . . | 284 |


### NOTES ET CHRONIQUES:


| | | |
|---|---|---|
| — Le 2.500 è anniversaire de la mort du Bouddha . . . . . | *Institut Bouddhique* . . . . . | 291 |
| — La cérémonie de clôture des cours de perfectionnement des moines Professeurs . . . | *Institut Bouddhique* . . . . | 297 |


Prix d'abonnement annuel (comprenant 12 numéros) 230$00

## សព្ទសាធុការពរ

# ក្នុងឱកាសចូលឆ្នាំថ្មី នៃពុទ្ធសាសនបណ្ឌិត្យ

ឱកាសចូល ឆ្នាំវកអដ្ឋស័ក ពុទ្ធស័កកន្លងបានពីរពាន់
បួនរយកៅប្រាំបួនជៀនជាក់ស្បាន់ គ្រិស្តស័កមួយពាន់ប្រាំបួនរយថ្វាយ ៗ
ហាសិបប្រាំមួយប្រាកដពិត ត្រូវតាមកម្រិតប្រាជ្ញបរិយាយ
ជាសករាជថ្មីប្រសើរសោយ សប្បាយដល់រដ្ឋខេមរា ៗ
ក្រសួងពុទ្ធសាសនបណ្ឌិត្យ សូមប្រសិទ្ធិជោគជ័យយសសក្កា
ថ្វាយ ព្រះមហាក្សត្រ ដ៏ថ្លៃថ្លា ព្រមទាំងព្រះមហាក្សត្រិយានី ៗ
ហើយនិង សម្ដេចព្រះសីហនុ ដែលមានពន្សុក្ដាពេញទី
ទារឯករាជ្យដោយសន្តិវិធី បានមកអំពីប្រាកដវិសេស ៗ
សូមពួកទេព្តាដែលមានរិទ្ធិ និងវត្តសក្តិសិទ្ធិកុំបីធ្វេស
ព្រមទាំងត្រៃរត្នខ្ពស់លើកេស ជួយទ្រង់ពិសេសបានសោយសុខ ៗ
និងទ្រង់ប្រកបដោយព្រះជន្ម មួយរយនិរន្តរ៍និរាសទុក្ខ
ដើម្បីស្រោចស្រង់ប្រទេសស្រុក ឲ្យបានក្ដីសុខចម្រើនក្ដាត់ ៗ
មួយទៀតសូមក្រុមព្រះរាជវង្ស នាម៉ឺនក្រៅក្នុងគ្រប់សង្កាត់
ព្រមទាំងបណ្ដាស្រុកនិងរដ្ឋ បានឃ្លាតទុក្ខសោកពេកកយា ៗ
បានសុខសប្បាយស្ថាពរ មានភោគបវរគ្រប់ ៗ គ្នា
ដោយតេជះគុណនៃទេព ឆ្នាំថ្មីនេះជាកុំបីឃ្លាត !

# ផ្នែកសាសនា

## ពុទ្ធសរណគាថា

### មហា ហ៊ុន-ប្រិញ និស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ពាទិយាន្តត្តយំ វន្ទេ កាមា វា តិរិតាទរំ

តស្សេវ អានុភាវេន សោត្ថិ មេ ហោតុ សព្វទា

ខ្ញុំព្រះករុណា សូមធ្វើនូវសេចក្តីគោរព ថ្វាយបង្គំចំពោះព្រះត្រៃរត្ន មានព្រះពុទ្ធជាដើម ដោយទ្វារទាំងបី សូមសិរីសួស្តីសំរេចមានដល់យើងខ្ញុំគ្រប់កាលទាំងពួង ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំចំពោះព្រះត្រៃរត្ននោះឯង ។

លំដាប់អំពីនេះ សូមសំដែងអំពីសរណវត្ថុទៅ; សរណវត្ថុ (វត្ថុសម្រាប់ទីពឹង) ក្នុងព្រះពុទ្ធសាសនាមាន ៣ ប្រការ គឺ ពុទ្ធសរណៈ ១, ធម្មសរណៈ ១, សង្ឃសរណៈ ១ ។ ក្នុងទីនេះសូមសំដែងអំពីពុទ្ធសរណៈ ។

ក្នុងកាលមុនពុទ្ធសករាជ ៨០ ឆ្នាំ បើគិតថយក្រោយពីឆ្នាំមមែសប្តស័កនេះត្រូវជា ២៥៧៨ ឆ្នាំ, ក្នុងថ្ងៃមហាមង្គលសម័យពេញបូណ៌មីខែវិសាខ ព្រះពុទ្ធជាម្ចាស់ជាសាស្តានៃយើងស្តេចឧប្បត្តិឡើង ក្នុងត្រកូលក្សត្រិយ៍ សាក្យវង្ស គោតមគោត្រ ជាព្រះរាជឱរសព្រះបាទសម្តេចសុទ្ធោទនៈ

សោយរាជ្យនៅក្នុងកបិលពស្តុ និងព្រះនាងមហាមាយា, ជាអរិយជាតិ គឺជាជាតិដែលចំរើនដោយចំណេះវិជ្ជា របៀបបែបផែនទំនៀមទម្លាប់ព្រមទាំងមានរិទ្ធិអំណាចក្នុងមជ្ឈិមប្រទេស ដែលហៅក្នុងកាលឥឡូវនេះថា ប្រទេសឥណ្ឌា តាំងនៅក្នុងទិសពាយ័ព្យនៃប្រទេសកម្ពុជានេះ ។ ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ គឺមានលក្ខណៈជាមហាបុរសត្រូវតាមគម្ពីរព្យាករណសាស្ត្ររបស់ព្រាហ្មណ៍ ។ កាលប្រសូតបាន ៥ ថ្ងៃ ព្រះវររាជបិតាឲ្យធ្វើមង្គលពិធីទទួលព្រះលក្ខណៈព្រះអង្គព្រះរាជទាននាមថា "សិទ្ធត្ថៈ" ។ វេលានោះព្រាហ្មណ៍ដែលជំនាញក្នុងក្បួនព្យាករណសាស្ត្របានធ្វើទំនាយក្រាបបង្គំទូលថា "ព្រះរាជឱរសនេះមានលក្ខណៈល្អ ត្រូវតាមគម្ពីរមហាបុរិសលក្ខណព្យាករណសាស្ត្រយ៉ាងបរិបូណ៌ បើព្រះអង្គនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិ មានអំណាចគ្របលើពិភពផែនដី; បើព្រះអង្គចេញទ្រង់ព្រះផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធ បានជាសាស្តាឯកក្នុងលោក" ។ ព្រះសិទ្ធត្ថកុមារព្រះអង្គជាទីពេញព្រះហឫទ័យ នៃព្រះរាជបិតាណាស់ បានទទួលការទំនុកបំរុងផ្សេង ៗ តាមផ្លូវលោកវិស័យ ប្រកបដោយសុខសម្រាន្តយ៉ាងបរិបូណ៌ ។ លុះមានព្រះជន្មល្មមសិក្សាវិជ្ជាហើយ ក៏ស្ដេចយាងទៅសិក្សាវិជ្ជារដ្ឋប្បសាសនសាស្ត្រ និងវិជ្ជាផ្សេង ៗ ក្នុងសំណាក់គ្រូឈ្មោះ វិស្វាមិត្រ ទ្រង់រៀនចេះចប់ស្ទាត់យ៉ាងឆាប់ ទាល់តែអស់ចំណេះអំពីគ្រូ នឹងរកកុមារដទៃ ៗ មកប្រៀបផ្ទឹមពុំបាន ។ កាលព្រះជន្មបាន ១៦ វស្សា ព្រះវរបិតាទ្រង់ដណ្ដឹងនាងយសោធរពិម្ពា

ជាធីតាព្រះបាទសុប្បពុទ្ធ កោលិយវង្ស មកអភិសេកជាព្រះជាយា ។ លុះដល់ព្រះជន្ម ២៩ វស្សា ទើបមានព្រះរាជបុត្រមួយព្រះអង្គទ្រង់នាមថា រាហុល ។

គ្រានោះព្រះអង្គទ្រង់ប្រារព្ធសេចក្តីចាស់ ឈឺ ស្លាប់ ដែលគ្របសង្កត់មហាជនគ្រប់រូប គ្មានអ្នកណាចៀសរួចបាន ។ ហេតុការណ៍ដូច្នេះ ព្រោះតែទោសដែលសត្វនិករមិនស្តាប់ពាក្យប្រដៅអ្នកប្រាជ្ញ ។ សត្វនិករឃើញអ្នកដទៃ ចាស់ ឈឺ ស្លាប់ ក៏មិនធ្ងន់ស្អប់ខ្ពើម មិនគិតថា ខ្លួនឯងនឹងខ្លួនគេប្រហែល ៗ គ្នា វង្វេងស្រវឹងក្នុងជីវិត ហាក់ដូចជាមិនចេះចាស់ ឈឺ ស្លាប់ មិនគិតរកឧបាយឲ្យរួចចាកសេចក្តីចាស់ ឈឺ ស្លាប់ឡើយ ។ កាលបើដឹងឃើញយ៉ាងនេះហើយ គួរតែស្វែងរកឧបាយគ្រឿងរួចចាកទុក្ខទាំងនេះទើបប្រសើរ; ព្រោះសភាវៈទាំងពួងសុទ្ធតែមានរបស់ដែលផ្ទុយគ្នាសម្រាប់កែជាដរាប ដូចយ៉ាងមានក្តៅហើយមានត្រជាក់កែ, មានងងឹតហើយ មានពន្លឺកែ, ប៉ុន្តែដែលនឹងរកឧបាយកែទុក្ខទាំង ៣ យ៉ាងនេះ មិនជាការងាយឡើយ, អ្នកដែលនៅគ្រប់គ្រងគេហស្ថាន ឃើញជាស្វែងរកមិនបាន ព្រោះគេហស្ថានជាទីចង្អៀតចង្អល់ណាស់ ហើយជាទីតាំងនៃអារម្មណ៍ ដែលធ្វើចិត្តឲ្យសៅហ្មងផងទៀត ដោយហេតុសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីវង្វេង ថែមទាំងរាជត្រកូលក៏រឹតតែច្របូកច្របល់ ដោយពួកស្ត្រីបំរើទាំងថ្ងៃទាំងយប់ រឹតតែធ្វើជីវិតឲ្យទន់ណាស់ទៅទៀត ។ ទ្រង់ក៏នឿយណាយក្នុងការរស់នៅរបស់ព្រះអង្គ ដែលអ្នកដទៃសំគាល់ឃើញថាជាសុខក្រៃពេក

ក្នុងផ្លូវលោកិយ; ទ្រង់ឃើញបព្វជ្ជាជាឱកាសដែលឃ្លាតអំពីអារម្មណ៍ដែលដឹកនាំចិត្តឲ្យវង្វេងមួមៅ ជាឱកាសស្រួលនឹងបានស្វែងរកឧបាយនោះ ដើម្បីនឹងបំពេញឲ្យជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ, ធ្វើជីវិតឲ្យមានប្រយោជន៍មានផ្កាផ្លែ កុំឲ្យអសារសូន្យសោះ ។ កាលទ្រង់ព្រះចិន្តាឃើញដូច្នេះហើយ ក៏ទ្រង់បង្អោនព្រះអធ្យាស្រ័យទៅក្នុងបព្វជ្ជា មិនអាឡោះអាល័យយសសម្បត្តិ ។

សម័យថ្ងៃមួយ ព្រះសិទ្ធត្ថកុមារចេញចាកនិវេសន៍ទៅដល់ឆ្នេរស្ទឹងអនោមា ទ្រង់អធិដ្ឋានភេទបព្វជិត ហើយក៏ស្ដេចទៅសិក្សាលទ្ធិសម័យក្នុងសំណាក់អាឡារតាបសនឹងឧទ្ទកតាបស ជាមេគណៈធំដែលល្បីល្បាញកេរ្តិ៍ឈ្មោះមានមហាជនគប់អានច្រើនក្នុងវេលានោះ ។ ព្រះអង្គទ្រង់សិក្សាមើលក្នុងលទ្ធិនោះគ្រប់យ៉ាងទៅ ឃើញថាមិនមែនជាផ្លូវសម្មាសម្ពោធិញាណ ទើបព្រះអង្គចេញចាកសំណាក់អាចារ្យទាំងពីរ ស្ដេចទៅដល់ដំបន់ឧរុវេលាសេនានិគម ទតឃើញទីនោះស្រួលសម្រាប់អ្នកប្រកបសេចក្ដីព្យាយាម ។ ទើបទ្រង់សំណាក់នៅទីនោះ ទ្រង់បំពេញទុក្ករកិរិយាយ៉ាងក្រៃលែងអស់ ៦ វស្សា ។ ទ្រង់ឃើញថា គ្មានផ្លូវសម្រេចហើយ ទើបផ្លាស់ប្ដូរដំណើរប្រព្រឹត្តិជាថ្មី គឺទ្រង់ប្រព្រឹត្តតាមផ្លូវកណ្ដាល ដែលហៅថាមជ្ឈិមប្បដិបទាបំពេញវីរិយៈក្នុងចិត្ត ទើបបានត្រាស់ដឹងនូវធម៌ដ៏វិសេសជាទីពេញព្រះហឫទ័យ ទើបលាន់ព្រះវាចាថា "ត្រាស់ដឹងហើយៗ" គឺដឹងអរិយសច្ចនោះឯង ក្នុងរាត្រីនៃវិសាខបុណ្ណមី ក្រោមដើមអស្សត្ថព្រឹក្ស ក្នុងកាលមុនពុទ្ធសករាជ ៤៥ ឆ្នាំ ។

ឯកោ វ លោកេ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោ

ព្រះអង្គតែមួយអង្គប៉ុណ្ណោះ ក្នុងលោកនេះ ជាអ្នកត្រាស់ដឹងនូវពោធិញ្ញាណ ដោយប្រពៃចំពោះព្រះអង្គ គ្មានបញ្ញាដទៃរបស់អ្នកណាមួយវិសេសជាងនេះទៅទៀតបាន ។ ព្រះអង្គទ្រង់ដល់នូវសេចក្តីបរិសុទ្ធផុតប្រមាណ មានអសេក្ខធម្មក្ខន្ធ គឺ សីល-សមាធិ-បញ្ញា-វិមុត្តិ-វិមុត្តិញ្ញាណទស្សនៈ បរិបូណ៌ក្នុងព្រះសន្តាន គ្មានអ្នកណាមួយក្នុងត្រៃភព ប្រៀបផ្ទឹមឲ្យត្រឹមស្មើបានឡើយ ។ ទ្រង់លះកិលេសទាំងពួងព្រមទាំងវាសនា ឲ្យដាច់ជ្រះស្រឡះគ្មានសេសសល់, ព្រះអង្គមានកាយវាចាចិត្តដ៏បរិសុទ្ធ, សេចក្តីទុច្ចរិតណាមួយដែលព្រះអង្គលះមិនទាន់បាន គោងបិទបាំងទុកកុំឲ្យអ្នកដទៃដឹងឃើញ នោះគ្មានសោះឡើយ, ទ្រង់មានព្រះហឫទ័យតាំងស្មើក្នុងលោកធម៌ គ្មានរំភើបប្តូរស្រើបស្រាល ហើយអាចនឹងលើកបញ្ញត្តិឡើង ប្រដៅសត្វដទៃឲ្យរួចចាកសង្សារទុក្ខបានផង; ព្រះអង្គមានព្រះទ័យប្រាថ្នាប្រយោជន៍ដល់សព្វសត្វជានិច្ច, ទ្រង់ប្រកបសត្វូបការកិច្ច ដោយមិនបានសំឡឹងលាភសក្ការៈអំពីអ្នកណា, ទ្រង់សំដែងធម្មកថាប្រដៅវេនេយ្យសត្វដោយត្រៃញាណ គឺសីល សមាធិ បញ្ញា ជាឧបាយគ្រឿងលះកិលេសយ៉ាងគ្រោកគ្រៀក យ៉ាងកណ្តាល យ៉ាងសុខុម ទាល់តែអស់ទៅជាទីបំផុត, ទ្រង់ប្រដៅទេវតានិងមនុស្សឲ្យចៀសចាកមគ្គមិច្ឆាប្រតិបត្តិដែលមិនមែនជាផ្លូវព្រះនិព្វាន ឲ្យប្រតិបត្តិជាដំណើរក្នុងមជ្ឈិមប្បដិបទាផ្លូវកណ្តាល. បានមគ្គមានអង្គ ៨ គឺ:

១– សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ គឺយល់ចិត្តត្រូវ ទូទៅទាំងផ្លូវលោកទាំងផ្លូវធម៌;

២– សម្មាសង្កប្បៈ ការត្រិះរិះត្រូវ បានដល់ការត្រិះរិះក្នុងការចេញចាកកាម, ត្រិះរិះក្នុងការមិនព្យាបាទសត្វដទៃ, ត្រិះរិះក្នុងការមិនបៀតបៀនសត្វដទៃ;

៣– សម្មាវាចា វាចាត្រូវ គឺវៀរចាកវចីទុច្ចរិត ៤ ប្រការ គឺវៀរចាកការនិយាយកុហក, និយាយញុះញង់, និយាយពាក្យគ្រោតគ្រាត, វៀរចាកការនិយាយពាក្យផ្តេសផ្តាសឥតប្រយោជន៍;

៤– សម្មាកម្មន្តៈ ការងារត្រឹមត្រូវ គឺវៀរចាកទុច្ចរិត ៣ ប្រការ គឺមិនសម្លាប់សត្វ, មិនលួចទ្រព្យគេ, មិនប្រព្រឹត្តខុសក្នុងកាម;

៥– សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ គឺវៀរចាកចិញ្ចឹមជីវិតខុសគ្រប់យ៉ាង ទាំងផ្លូវធម៌ ទាំងផ្លូវលោក;

៦– សម្មាវាយាមៈ ព្យាយាមត្រូវ គឺព្យាយាមក្នុងបធានៈ ៤ ប្រការ គឺ ព្យាយាមមិនឲ្យបាបកើតក្នុងសន្តាន, ព្យាយាមលះបង់បាបដែលមានក្នុងសន្តាន, ព្យាយាមបំរើនកុសល, ព្យាយាមរក្សាកុសលដែលកើតហើយមិនឲ្យសាបសូន្យទៅ;

៧– សម្មាសតិ ការរលឹកត្រូវ គឺរលឹកក្នុងសតិបដ្ឋានទាំង ៤ ប្រការ មានកាយានុបស្សនាសតិបដ្ឋានជាដើម;

៨– សម្មាសមាធិ ការតាំងចិត្តត្រូវ គឺដំកល់ចិត្តខាប់ខ្ជួនក្នុងឈានទាំង ៤ ប្រការ ។

មគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើមនេះ សង្គ្រោះចូលក្នុងសីល, សមាធិ, បញ្ញា នោះឯង ។ ពពួកវេនេយ្យសត្វអ្នកមានឧបនិស្ស័យ បានស្តាប់ធម្មទេសនាដែលទ្រង់ប្រដៅនោះ ហើយប្រតិបត្តិតាមក៏បានលុះធម៌វិសេសគឺមគ្គ ផល និព្វាន កន្លងបង់នូវភាពជាបុថុជ្ជនឡើងកាន់អរិយភូមិជាសោតាបន្ន, សកទាគាមិ, អនាគាមិ, អរហត្តតាមសមគួរដល់ឧបនិស្ស័យរៀង ៗ ខ្លួន ។

បើសរុបសេចក្តីទៅ គុណសម្បត្តិដែលមានប្រាកដក្នុងព្រះអង្គកំណត់ជាអាការមាន ៣ ប្រការ គឺវិសុទ្ធិគុណ ១ បញ្ញាគុណ ១ ករុណាគុណ ១ ។

ដែលព្រះអង្គមានព្រះនាមថា អរហំ ព្រោះព្រះអង្គជាអ្នកឆ្ងាយចាកកិលេសគ្រឿងសៅហ្មងចិត្ត គឺ រាគៈ ទោសៈ មោហៈ យ៉ាងគ្រោតគ្រាត យ៉ាងកណ្តាល យ៉ាងល្អិត ព្រះអង្គលះបានដោយអំណាចសីល សមាធិ បញ្ញា ទៅជាបុគ្គលមានខន្ធសន្តានដ៏បរិសុទ្ធិ គួរតែងតាំងបញ្ញត្តិដល់ពពួកពុទ្ធបរិស័ទ គួរដល់អាមិសបូជារបស់សត្វលោកធ្វើសក្ការៈបូជាត ៗ មកដល់សព្វថ្ងៃនេះ, ព្រះពុទ្ធគុណបទ អរហំ នេះ ជាគុណដ៏ធំប្រកាសព្រះវិសុទ្ធិគុណក្នុងអង្គព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ។

ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គជាអ្នកត្រាស់ដឹងនូវ

ធម៌ពិតយ៉ាងប្រសើរ គឺអរិយសច្ចធម៌ ៤ ដោយព្រះអង្គឯង ។ ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គជាអ្នកដល់ព្រមដោយវិជ្ជា ៣ វិជ្ជា ៨ និងចរណៈ ១៥ ។ ព្រះនាមថា សុគតោ ព្រោះព្រះអង្គជាអ្នកទៅកាន់លោកុត្តរធម៌ដោយល្អ ។ ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជាអ្នកជ្រាបច្បាស់នូវលោក មានសង្ខារលោកជាដើម ។ បួនបទនេះជាគុណដ៏ធំ ប្រកាសព្រះបញ្ញាគុណក្នុងអង្គព្រះសម្មាសម្ពុទ្ធ ជាកំលាំងដ៏ធំក្រៃលែង ក្នុងការត្រាស់ដឹង ។

ព្រះនាមថា: អនុត្តរោ, បុរិសទម្មសារថិ ព្រោះព្រះអង្គជួបជានាយសារថីដ៏សំខាន់ ទូន្មានបុរសដែលគួរទូន្មាន គ្មានអ្នកណាមួយប៉ុនប្រសប់ទូន្មានជាងព្រះអង្គ គឺទូន្មានឲ្យបានលុះលោកុត្តរធម៌ ជាអកុប្បធម៌ គ្មានវេលានឹងត្រឡប់មកកាន់លោកិយធម៌ទៀត ។ ក្នុងគម្ពីរខ្លះលោកពន្យល់ថា អនុត្តរោ ជាព្រះគុណ ១ បុរិសទម្មសារថិ ជាព្រះគុណ ១ ។ ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គបានជាសាស្តារបស់ទេវតានិងមនុស្សទាំងឡាយ ។ ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គជាអ្នកភ្ញាក់ ព្រមទាំងជាអ្នកដាស់ពួកពុទ្ធវេនេយ្យសត្វឲ្យភ្ញាក់អំពីការដេកលក់គឺកិលេសនិទ្រារម្មណ៍, ទ្រង់បានធ្វើនូវពុទ្ធកិច្ចទាំង ៥ ប្រការពេញទី ។ ព្រះនាមថា ភគវា ព្រោះព្រះអង្គជាអ្នកចែកចាយនូវធម៌ជាសភាវៈពិតដល់វេនេយ្យសត្វទាំងឡាយ ។ បួនបទនេះ ប្រកាសព្រះមហាករុណាគុណដែលមាននៅក្នុងព្រះអង្គ ។

គុណសម្បត្តិទាំង ៩ ប្រការនេះ ប្រកាសពុទ្ធគុណ ដែលជាកំពូលនៃសេចក្ដីល្អទាំងពួង ដែលមានប្រាកដក្នុងអង្គសម្ដេចព្រះបរមសាស្ដា ទីងស្វះស្វែងរកសាស្ដាណាដែលទ្រទ្រង់គុណសម្បត្តិទាំងឡាយដូច្នេះគ្មានឡើយ ។ គុណសម្បត្តិទាំងឡាយដែលបានសំដែងមកហើយសង្ខេប ៗ នេះជាគុណដ៏ល្អ គួរឲ្យសត្វលោកចូលពឹងពាក់អាស្រ័យយកជាសរណៈ (ទីពឹង) ។ ហេតុដូច្នេះ បានជាពបថា "ព្រះពុទ្ធជាម្ចាស់ជាសរណៈរបស់សត្វលោក" ។

ឯធម្មសរណៈ នឹងសង្ឃសរណៈ មិនបាននាំយកមកសំដែងក្នុងទីនេះទេ សូមបញ្ចប់ធម្មទេសនា ដែលសំដែងអំពីពុទ្ធសរណៈ តែប៉ុណ្ណេះ ។

កាលបើចប់ហើយ ដោយអំណាចធម្មទេសនានេះ សូមសេចក្ដីសុខ-ចំរើនកើតមានដល់ប្រជាជនក្នុងដែនកម្ពុជាទាំងមូល កុំបីឃ្លៀងឃ្លាតឡើយ !

## ប្រយ័ត្ន ៤ :

១ - ហោរាប្រយ័ត្នមាត់រអិល

២ - ជាងទងកាន់សីលប្រយ័ត្នទៀង

៣ - ទៅគ្រំប្រយ័ត្នការលំអៀង

៤ - អ្នកផ្សៀងប្រយ័ត្នបាត់អក្ខរា ។

សុត្តន្តប្រីជា គង់

# មាតាបិតុគុណកថា

ពាក្យកាព្យ

ព្រះអាចារ្យ ជៃ - ម៉ៃ វត្តសំពៅមាស ភ្នំពេញ

រៀបរៀង

---

មាតាបិតាថ្លៃ មានគុណក្រៃយ៉ាងអស្ចារ្យ
ដោយធម៌ ៤ ប្រការ បុត្រធីតាគួរចាំទុក ។
ទី ១ គឺមេត្តា អត្ថប្រែថាស្និតក្នុងសុខ
ចិត្តម្តាយនឹងពុក ស្វែងរកសុខសព្វវេលា ។
តាំងពីថ្ងៃពពោះ លោកទាំងនោះមានចិន្តា
អាណិតដល់បុត្រា គ្រប់វេលាទាំងយប់ថ្ងៃ ។
ការពារលៀងជីវិត ទោះឆ្ងាយជិតឥតសំចៃ
ក្នុងស្រុក ឬ ក្នុងព្រៃ ពុំតែងលៃធ្វើគ្មានឈប់ ។
ស្វះស្វែងរកទ្រព្យា ទុកភរិយាឲ្យនៅម្ហូប
អាស្សូរទាំងសព្វគ្រប់ ប្រពន្ធឈប់គ្មានទោសា ។
ផ្តុំថ្នាំរក្សាផ្ទៃ យ៉ាងប្រពៃឲ្យភរិយា
នេះឯងគឺមេត្តា ខាងបិតាបុត្រប្រុសស្រី ។
ចំណែកខាងមាតា ធ្លាប់ពិសារអស់ចំណី
ហាលហាងយ៉ាងណាក្តី តាមប្រក្រតីឥតមានតម ។
តែដល់មាននិមិត្ត មកសណ្ឋិតតាំងនៅព្រម
មាតាក៏តាំងតម កាន់ត្រណមមិនភោគ្គា ។

ព្រោះហេតុលោកអាណិត មេត្រីចិត្តជាប់មេត្តា
ចំពោះបុត្រធីតា ជាទារកានៅក្នុងផ្ទៃ ។
តរិយាបថទាំងបួន មានក្នុងខ្លួនមាតាថ្លៃ
បើតាមដោយប្រក្រតី សឹងរហ័សគ្រប់កិរិយា ។
លុះដល់មានគភ៌ហើយ មាតាស្បើយប្រែយឺតណា
ដោយចិត្តមានមេត្តា ឈប់ស្ទុះស្ទាយរាំងរហ័ស ។
ហើយតែងនឹកទន្ទឹង ដោយចង់ដឹងកូនពេកណាស់
ចង់ឃើញកូនឲ្យច្បាស់ តើទារកឬទារិកា ។
ទី ២ ករុណាគុណ គុណនេះធ្ងន់ ៗ មហិមា
ដោយអត្ថប្រែមកថា ការជួញទុក្ខរបស់បុត្រ ។
សេចក្តីអធិប្បាយថា ចិត្តមាតាតែងស្រយុត
ក្នុងពេលដែលពួកបុត្រ មានទុក្ខភ័យអ្វីកើតឡើង ។
បុត្រី ឬ បុត្រា កើតមកណាម្តាយតក់កើង
សម្រាម ឬ បម្បែង ធ្លាក់មកលើស្មើរពុំបាន ។
កំពុងបរិភោគ អស់ភោជនាក្នុងគ្រឹះស្ថាន
ឬមាត់កូនកល្យាណ ស្រែកយំស្ទុះឈប់ពីសា ។
បើកូនមានជម្ងឺ គ្រុនក្តៅឈឺយំសម្បា
ម្តាយឪពុកក៏ខ្វោចផ្សា ភ័យរន្ធត់រកពេទ្យហ្ម ។
បើពេទ្យឲ្យទិញថ្នាំ លក់បញ្ចាំស្រូវអង្ករ
ខ្ចីបុលគេបន្ត មានទីងក្រគិតទៅក្រោយ ។

បើកូនមានទុក្ខទោស ឬកំហុសដោយថ្ងស់ក្លោយ
បង់ខាតអ្វីក៏ដោយ ឲ្យតែកូនរួចទុក្ខភ័យ ៗ
យ៉ាងនេះហៅគុណា ចិត្តមាតាបិតាថ្លៃ
ផ្សាយលើកូនសព្វថ្ងៃ សព្វវិថីខណៈចិត្ត ៗ

ទី ៣ មុទិតា

អត្ថប្រែថាទន់ពេកពិត
ក្បែរគ្នាទឹងអាណិត ទោរទន់ចិត្តឥតសោយ ៗ
កូនប្រុសឬកូនស្រី តាមសេចក្ដីនៃបរិយាយ
រមែងមានជេរម្ដាយ ឬក៏យកប់លោកវិញខ្លះ ៗ
ជិះជាន់ចាប់កេសា យំសម្ភាដោយម្នាម្នះ
លុះតែល្អងលោមខ្លះ ថ្នាក់សំពះកូនក៏មាន ៗ
បំពេះហើយបីព ពោលបន្ទូរកែកំសាន្ត
ចិត្តទន់ល្វន់មែនមាន ដូចយើងបានអធិប្បាយមក ៗ
សំលៀកបំពាក់កាយ កូនទាំងឡាយម្ដាយខំរក
ខំធ្វើឲ្យបានមក យកមកទុកឲ្យតែកូន ៗ
ឲ្យរៀនសព្វសិល្បសាស្ត្រ មិនឲ្យផ្ដាសខ្វិលវេះពួន
ឲ្យរៀនពេញសំនួន ឲ្យបេះបប់សព្វរហូត ៗ
ស៊ូទៀយមិនគិតខ្លួន ឲ្យតែកូនខំរៀនសូត្រ
ឲ្យបេះចាំរហូត ស្រូតឲ្យផុតពីអវិជ្ជា ៗ
កូនសល្អស្រសឆើត ឬក៏ខ្មៅសៅអគ្គា
លោកផ្សាយព្រហ្មវិហារ ស្មើៗគ្នាគ្រប់ៗកូន ៗ

ឯកូនអ្នកដទៃ　　　　ទោះបេះស្ដីយ៉ាងសមសួន
មិនស្មើនឹងកូនខ្លួន　　　　គ្មានតែយំក៏ពីរោះ ។
ធម៌អាថ៌លោកសំដែង　　　　មានហេតុដែងពោលត្រកោះ
ថាធម៌មិនពីរោះ　　　　មោះគឺគ្មានមុទិតា ។
ទ្រព្យធនមានច្រើនយ៉ាង　　　　ខំសំអាងឲ្យបុត្រា
បុត្រីមានប៉ុនណា　　　　គិតរចនាទាល់តែគ្រប់ ។
រៀបចំគូស្រករ　　　　ទោះទ័លក្រក៏មិនឈប់
ប្រឹងរកទាល់តែគ្រប់　　　　នៅមិនទាន់ចប់ក្នុងចិត្ត ។
នេះហៅមុទិតា　　　　អង្គសាស្ដាមារវិជិត
ទេសនាពិស្ដារពិត　　　　ថ្វែងពីគុណបុព្វាចារ្យ ។
ត្រាស់ប្រាប់ភិក្ខុទាំងឡាយ　　　　យ៉ាងគ្រោះក្បាយដោយពិស្ដារ
ដូចយើងបានបរិយា　　　　គុណមុទិតាថ្នាក់ទី ៣ ។
ទី ៤ ឧបេក្ខា　　　　ប្រាជ្ញប្រែថាចិត្តប្រក្រតី
មិនស្អប់មិនមេត្រី　　　　មិនបែកីនៅព្រងើយ ។
បំពោះបុត្រធីតា　　　　មានភរិយាស្វាមីហើយ
ចិត្តលោកបានធូរស្បើយ　　　　ចិត្តព្រងើយពីសុខទុក្ខ ។
ដោយអាងថារូបកូន　　　　រៀងរាល់ខ្លួនគេមានមុខ
រកស៊ីទៅគគុក　　　　ទាំងបានសុខក្នុងគ្រួសារ ។
កូនប្រុស ឬ កូនស្រី　　　　ដែលឃ្លាតខ្ចីរៀនវិជ្ជា
អាចនឹងតដីកា　　　　ក្នុងអត្តភាពនេះបានហើយ ។

ចិត្តលោភក្ខុបត្ថា ទើបទៅជានៅកន្តើយ
ឥតស្អប់ស្រឡាញ់ឡើយ នេះឯងហើយក្ខុបត្ថា ។
សប្បុរសទាំងឡាយអើយ ស្ដាប់ឮហើយគួរជ្រះថ្លា
នឹងគុណ ៤ ប្រការ ដែលហៅថាវិហារធម៌ ។
សឹងមានក្នុងសន្ដាន នៃអ្នកមានគុណបវរ
បំពោះសត្វនិករ ដែលជាបុត្រមាសឆ្អិនឆ្អៅ ។
ដូច្នេះយើងកល់គ្នា ប្រសិនជានៅម៉ែឪ
គួរគោរពឲ្យត្រូវ តបគុណលោកតាមលំនាំ ។
ធម៌នេះចប់ប៉ុណ្ណេះ សូមទុកស្មេរពាក្យបណ្ដាំ
អ្នកប្រាជ្ញអាចចេះចាំ ថ្លែងបណ្ដាំនេះឯងហោង ។

## អវិសានកថា

មេធាធិធម្មម៉ែ ខ្ញុំបានលៃបងនិពន្ធ
ធម៌នេះឲ្យគ្រប់គ្រាន់ តាមលំនាំជាពាក្យកាព្យ ។
ព្រោះខ្ញុំស្ដាយក្ដីពិត មានក្នុងចិត្តឥតប្រែភាព
នៃមាតាជនក ជាបុញ្ញលាភនៃសព្វសត្វ ។
តែឮគេស្រដី ទាំងប្រុសស្រីយូរមកក្ដាត់
ថាគុណម្ដាយត្រូវចាត តែដប់ពីរប្រការគត់ ។
បិតាមានថ្លៃ មួយទៀតន័យជាកំណត់
យកធាតុមកសន្មត់ ហើយកំណត់ថាគុណថ្លៃ ។

បើម៉ឺនជឿម្ដេចបាន ខុសលំអានពីបាលី
មិនដឹងអាងគុណអ្វី ហ៊ានស្រដីតៗគ្នា ។
ពាក្យនេះខុសយូរហើយ ញាតិញោមអើយកុំសង្កា
សម្ដេចព្រះកគក់ មិនទេស្នាដូច្នេះទេ ។
ទ្រង់ចាត់ព្រហ្មវិហារ ៤ ប្រការនេះជាមេ
គុណនោះឯណេះទេ ដែលជាគុណគួរគោរព ។
ដូច្នេះបុត្រធីតា គួរឧស្សាហ៍រៀនឲ្យចប់
ស្គាល់គុណនេះឲ្យគ្រប់ ហើយគោរពក្នុងគុណបុះ ។
បើបានគោរពហើយ មិនយូរឡើយនឹងផុលផុះ
ក្ដីសុខកើតកកកុះ ដល់កូនប្រុសនឹងកូនស្រី ។
ដូចកាលពោធិសត្វ ទ្រង់លះកាត់ការលោកិយ
បួសជាតាបសខ្វី ខំស្វឹងស្វាធិធម៌ប្រសើរ ។
បានឈានជាលោកិយ ព្រះឥសីតែងហោះហើរ
ស្វែងរកផលប្រសើរ មកបម្រើបុព្វាចារ្យ ។
គឺម្ដាយនឹងឪពុក ព្រះអង្គទុកក្នុងសាលា
បម្រើព្រះមាតា នឹងបិតាសព្វៗថ្ងៃ ។
ជាក់ពោសតាបសប្អូន ថាត្រូវសូន្យការប្រពៃ
ដ្បិតឯងមនុស្សចង្រៃ កុំបីមកជិតសាលា ។
កិច្ចដែលបម្រើឪ ឪងម៉ែគួរតាំងទេណា
ខ្លួនយើងជាជេដ្ឋា យើងបម្រើតែម្នាក់ឯង ។

តាបសជាប្អូនពៅ    មានក្តីសៅហ្មង់ចំបែង
ទៅពឹងអស់ស្តេចស្តែង    ឲ្យមកថ្លែងជួយសុំទោស ។
ពួកស្តេចមួយរយមួយ    យាងមកជួយដោយសន្តោស
មកសុំខមាទោស    ចំពោះព្រះពោធិសត្វ ។
មាតាជួយសុំផង    ទោសធ្ងាំធ្ងន់ដែលក្អាំងក្អាត់
សូមឲ្យពោធិសត្វ    ដកបញ្ញត្តិកាត់ពេលចេញ ។
តាបសក៏អាណិត    ដោយខ្វាបចិត្តមាតាមិញ
បើកឲ្យបម្រើវិញ    បំពេញកិច្ចកតញ្ញូ ។
ឯអង្គពោធិសត្វ    បុរសឧត្តមឧង្គ្រ
ព្រះអង្គទ្រង់បង្ហូរ    នូវមធុរៈទេស្នា ។
ប្រោសស្តេចមួយរយមួយ    ដែលមកជួយប្អូនអាត្មា
លុះចប់ព្រះធម្មា    អស់ពួកជាកើតជ្រះថ្លា ។
ប្រគេនបច្ច័យ ៤    មានចំនួនច្រើនមហិមា
និមន្តពោធិសម្ភារ    ទៅឋានទីរៀងកល់អង្គ ។
ថ្វាយខ្លួនជាឧបដ្ឋាក    បម្រើអ្នកដោយផ្ចិតផ្ចង់
នេះគឺជាអានិសង្ស    ការបម្រើពោធិសត្វ ។
ដូច្នេះបុត្រធីតា    បានបញ្ញាគួរប្រតិបត្តិ
ធ្វើដូចពោធិសត្វ    កុំឲ្យភ្លាត់ប្រមាទអើយ ។

ចប់

# បាឋកថារឿងពុទ្ធរូបបុរាណ

ឃុនអត្ថកោវិទ ជា - យ៉ូវ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែអំពីទស្សនាវដ្ដីដំណឹងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ (ភាសាថៃ)

---

បាឋកថារឿងនេះ ហ្លួងបរិបាលបុរីភ័ណ្ឌ ជាអ្នកជំនាញក្នុងបុរាណគតិនៃក្រមសិល្បករ បាន ថ្លែងឲ្យប្រជាជនស្ដាប់ នៅរបៀងព្រះវិហារវត្តបញ្ចមបពិត្រ ក្នុងការប្រឡងព្រះពុទ្ធរូបប្រចាំឆ្នាំ សំរាប់វត្តនោះ នៅថ្ងៃទី ៤ កុម្ភៈ ព. ស. ២៤៩១ ជារឿងដែលពុទ្ធសាសនិកជនជាតិយើង គួរសិក្សាឲ្យដឹងឲ្យចូលចិត្តច្បាស់លាស់ ។

សូមទូល សូមជំរាប ដល់ព្រះសង្ឃនិងសាធុជន !

ខ្ញុំព្រះករុណា ខ្ញុំមានសេចក្ដីត្រេកអរជាពន្លឹក ដែលបានឱកាសមក សំដែងបាឋកថារឿង ព្រះពុទ្ធរូបបុរាណ ក្នុងថ្ងៃនេះ, តែមុននឹងពោល អំពីរឿងព្រះពុទ្ធរូបបុរាណ ខ្ញុំសូមពន្យល់អំពីវត្ថុបំណង ដែលមានការ ប្រឡងព្រះពុទ្ធរូបក្នុងឆ្នាំនេះជាមុនសិន ដូចតទៅនេះ :

ពុទ្ធសមាគមនៃប្រទេសថៃ នៅក្នុងព្រះបរមរាជូបត្ថម្ភ ព្រមទាំង គណៈវត្តបញ្ចមបពិត្រ មានសម្ដេចព្រះវន្នរ័តជាប្រធាន បានរួបរួមគ្នាចាត់ ឲ្យមានការប្រឡងឡើង ដោយមានវត្ថុបំណងឲ្យពួកប្រជាជន ដែលកាន់ អានព្រះពុទ្ធសាសនា បានទស្សនាព្រះពុទ្ធរូបដែលប្រកបដោយមហា- បុរិសលក្ខណៈ ដើម្បីបំពេញបសាទសទ្ធាក្នុងព្រះពុទ្ធសាសនាឲ្យជា ភិយ្យោភាពឡើង ។ ព្រះពុទ្ធសាសនាបានចូលមកប្រតិស្ឋាននៅក្នុង ប្រទេសថៃនេះជិត ២.០០ ឆ្នាំមកហើយ ទាំងព្រះពុទ្ធរូបក៏មានមកជា យូរយារណាស់ជិតដល់ ២.០០០ ឆ្នាំដែរ ។ ចំពោះប្រទេសយើងមាន

ព្រះពុទ្ធរូបច្រើនណាស់ទាំងច្រើនយុគច្រើនសម័យផង មានទាំងព្រះពុទ្ធ-រូបដែលសាងហោយស្នាដៃដ៏អាក្រក់ ឲ្យគ្រាន់តែជាព្រះបដិមាករប៉ុណ្ណោះក៏មាន ដែលល្អវិចិត្របញ្ចង់រហូតដល់ជឿថាទេវតាចុះមកកសាងក៏មាន ដូចជាព្រះពុទ្ធជិនរាជនៅខែត្រពិស្ណុលោកជាដើម ល្អហួសវិស័យនៃថ្វីដៃជាងមនុស្ស តែដែលពិតនោះមិនមែនទេវតាចុះមកសាងឡើយ គឺមនុស្សក្នុងសម័យនោះឯងសាងឡើង ។ ព្រោះបុគ្គលដែលជ្រះថ្លាក្នុងពុទ្ធសាសនាមានច្រើនពួកច្រើនជាន់ រាប់តាំងអំពីព្រះមហាក្សត្រាធិរាជរហូតដល់សាមញ្ញជនអ្នកក្រីក្រ, បណ្ដាជនទាំងនេះ អ្នកមានទ្រព្យសម្បត្តិច្រើន គេអាចរកជាងដែលមានថ្វីដៃល្អ ៗ មកសាងព្រះពុទ្ធរូបបានតាមបំណងរបស់គេ ចំណែកអ្នកក្រីក្រដែលមានបសាទសទ្ធាតែមិនមានទ្រព្យសម្បត្តិ ក៏មិនអាចនឹងរកជាងដែលមានថ្វីដៃល្អមកសាងព្រះពុទ្ធរូបឲ្យល្អបានទេ គេសាងតាមតែកំលាំងទ្រព្យនិងកំលាំងសទ្ធារបស់ខ្លួន ហេតុនោះទើបមានព្រះពុទ្ធរូបទាំងពីរយ៉ាងដូចពោលមកហើយ ។ វត្ថុបំណងក្នុងការប្រឡងគ្រានេះ ក៏ព្រោះហេតុថាព្រះពុទ្ធរូបមានច្រើនជាន់ច្រើនសម័យនោះឯង ថាបើមានការដឹកនាំបណ្ដាពុទ្ធបរិស័ទដែលមានព្រះពុទ្ធរូបសំរាប់បូជា យកមកប្រៀបគ្នាដើម្បីប្រឡងមើលឲ្យដឹងថា អង្គណាប្រកបដោយមហាបុរិសលក្ខណៈល្អបែបណា ទ្រង់ទ្រាយបែបណា ជាជំនាន់ចាស់លើសគេយ៉ាងណា ក៏ជាហេតុឲ្យកើតបសាទសទ្ធាជាភិយ្យោភាពឡើង ។ ព្រោះសេចក្ដីល្អជាគុណសម្បត្តិអាចដឹកនាំទឹកចិត្តឲ្យកើតសទ្ធាជ្រះថ្លា ប្រៀបដូចពួកយើងបានបួសទៅ

ថ្វាយបង្គំព្រះជ័រក្នុងវិហារ ១ បើឃើញព្រះរូបល្អ ដូចអង្គព្រះជ័រក្នុង
វិហារនេះ គឺថ្វាយបង្គំព្រះជិនរាជអង្គនេះក្តី ឬព្រះជិនរាជនៅពិស្ណុ-
លោកក្តី យើងក៏នឹងកើតសេចក្តីជ្រះថ្លាជាងទៅថ្វាយបង្គំព្រះដែលមាន
ព្រះរូបអាក្រក់ បើយើងបានទៅអង្គុយចំពោះព្រះភក្ត្រព្រះពុទ្ធជិនរាជ
ហើយរំលឹកព្រះពុទ្ធគុណ ព្រមទាំងបានទស្សនាព្រះបដិមាករ យើងក៏នឹង
កើតសទ្ធាព្រមទាំងបីតិយ៉ាងចំឡែកអស្ចារ្យ ៗ ចំណែកការលំអរបស់
ព្រះពុទ្ធជាម្ចាស់នោះ លោកដែលបានរៀនពុទ្ធប្រវត្តិ គង់ជ្រាបច្បាស់ថា
ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះរូបឆោមដ៏ល្អល្អះ ប្រកបដោយមហាបុរិស-
លក្ខណព្យាករណសាស្ត្រ, សេចក្តីល្អនេះឯងជាគ្រឿងដឹកនាំបណ្តាជន
ឲ្យកើតបីតិសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាជាច្រើន សូម្បីព្រះវក្កលិថេរ
ដែលបានចូលមកបួសក្នុងព្រះពុទ្ធសាសនា ក៏ព្រោះត្រូវការចង់មើល
ព្រះរូបព្រះបរមសាស្តាប៉ុណ្ណោះ ព្រោះដូច្នោះទើបឃើញថា សេចក្តីល្អជា
គ្រឿងដឹកនាំបណ្តាជនឲ្យនិយមរាប់អានមួយយ៉ាងដែរ ៗ ព្រះពុទ្ធអង្គទ្រង់
មានព្រះរូបសម្បត្តិដ៏ល្អលើសលុប ព្រះពុទ្ធរូបស្នងព្រះអង្គក៏ដូចគ្នាដែរ បើ
យើងបានទៅអង្គុយមើលព្រះពុទ្ធរូបដែលល្អ ៗ ក៏ជាហេតុឲ្យកើតបសាទ-
សទ្ធាដ៏ក្រៃលែង សូម្បីតែអ្នកដែលមិនធ្លាប់ជ្រះថ្លាក៏ទៅជាជ្រះថ្លាបាន ៗ
យើងខ្ញុំធ្លាប់បាននាំពួកអឺរ៉ុបទៅមើលបុរាណវត្ថុនៅពិស្ណុលោក នៅពេល
ដែលចូលទៅថ្វាយបង្គំព្រះពុទ្ធជិនរាជក្នុងព្រះវិហារ អង្គុយត្រង់តុដែល
សម្រាប់ឲ្យបណ្តាជនដាក់បច្ច័យបូជា ព្រោះទីត្រង់ណោះជាទីដ៏គួរដល់ការ
ទស្សនា ពួកអឺរ៉ុបទាំងនោះមិនបានកាន់ព្រះពុទ្ធសាសនាទេ តែគេប្រាប់

យើងខ្ញុំថា ព្រះពុទ្ធជិនរាជល្អណាស់ មានទ្រង់ទ្រាយសក្តិសមត្រឹមត្រូវតាមខ្នាតរង្វាស់ គេប្រាប់ខ្ញុំថា គេអាចនឹងអង្គុយតែមើលប៉ុណ្ណោះ ចំពោះព្រះភក្ត្រព្រះជិនរាជប៉ុន្មានម៉ោង ក៏អង្គុយបានដែរ ដោយគ្មានទ្រាន់ណាយអ្វីសោះឡើយ ព្រោះសេចក្តីល្អពិតនោះ អាចនាំមកនូវផលដោយប្រការដូច្នេះ ៗ បើយើងមានព្រះពុទ្ធរូបដែលមានទ្រង់ទ្រាយល្អ ៗ សំរាប់បូជា ក៏នឹងបន្ថែមសទ្ធាជ្រះថ្លារឹតតែច្រើនឡើង ហើយយើងក៏នឹងនឹកដល់គុណរបស់ជាងជាន់ចាស់ ហើយនឹកដល់គុណរបស់អ្នកដែលបានថែរក្សាព្រះពុទ្ធរូបបុរាណទុករហូតដល់យើងបានធ្វើសក្ការៈបូជាសព្វថ្ងៃនេះ ៗ តែមានការចំឡែក ១ យ៉ាង គឺពុទ្ធសាសនិកជនដែលកាប់កាន់ព្រះពុទ្ធសាសនា ច្រើនតែមានព្រះពុទ្ធរូបគ្រប់ៗផ្ទះ តាំងអំពីផ្ទះអ្នកធំរហូតដល់ផ្ទះជនសាមញ្ញ តែមិនសូវមានអ្នកណាចូលចិត្តរៀនលក្ខណៈរបស់ព្រះពុទ្ធរូបដែលខ្លួនគោរពបូជានោះ មានព្រះពុទ្ធរូបដូចម្តេចក៏ដោយក៏ដឹងតែពីថ្វាយបង្គំប៉ុណ្ណោះ ទោះបីក្នុងវត្តណាក៏ដោយ គេចូលទៅថ្វាយបង្គំព្រះដ៏ក្នុងវិហារ ក៏ចេះតែថ្វាយបង្គំទៅ មិនសូវចេះគិតថាអ្នកណាសាងហើយសាងពីក្នុងសម័យណា ស្នាដៃជាងដែលសាងល្អឬអាក្រក់ យើងមិនសូវយកចិត្តទុកដាក់ក្នុងរបៀបទាំងនេះ ខុសពីពួកអឺរ៉ុបសូម្បីដោយច្រើនគេមិនបានកាន់ព្រះពុទ្ធសាសនា តែក្នុងពិពិធភណ្ឌប្រទេសគេ ក៏មានព្រះពុទ្ធរូបដែរ ហើយគេអាចអធិប្បាយប្រាប់យើងបានថា ព្រះពុទ្ធរូបបែបនោះសាងក្នុងយុគនោះ ឬក្នុងសតវត្សរ៍នោះ គេដឹងច្បាស់លាស់ជាងយើងដែលជាពុទ្ធសាសនិកជន ៗ រឿងនេះ

កាលខ្ញុំនៅធ្វើការក្នុងហោរព្រះសមុទ្រ នៅពេលរយៈចុងរជ្ជកាលទី ៦ តាំងពីមានព្រះរាជបញ្ញត្តិនិយាយពីការថែរក្សាបុរាណវត្ថុគ្រាដំបូង ខ្ញុំទទួលតំណែងជាគូឈ្មួយចាងហ្វាងបុរាណវត្ថុ ( សាស្ត្រាចារ្យ សឺក-ស៊ីដែស ) ខ្ញុំក៏បានផ្ដើមរៀនលក្ខណៈរបស់បុរាណផ្សេងៗ ដើម្បីឲ្យមានសមត្ថភាពក្នុងការពិនិត្យបុរាណវត្ថុ ។ បណ្ដាបុរាណវត្ថុផ្សេងៗនោះ មានព្រះពុទ្ធរូបរួមនៅផងជាចំនួនច្រើន ខ្ញុំបានយកចិត្តទុកដាក់សិក្សាលក្ខណៈព្រះពុទ្ធរូបយ៉ាងមុតមាំ ស្រាវជ្រាវគេមើលរូបក្នុងក្រាំងផ្សេងៗ ខ្លះ ដើរមើលតាមវត្តផ្សេងៗ ខ្លះ ។ ថ្ងៃមួយខ្ញុំបានសួរអ្នកធំម្នាក់ដែលជាកម្មការហោរព្រះសមុទ្រក្នុងពេលនោះថា ហេតុអ្វីជនជាតិខ្មែរ គេមិនសូវសិក្សាលក្ខណៈព្រះពុទ្ធរូបសោះៗ គេឆ្លើយថា ស្រុកយើងមិនទាន់ស៊ីវិល័យដល់ថ្នាក់នោះទេ ។ ខនេះជារឿងដែលពិតជួបប្រទះមែន, ខ្ញុំដើរសួរអ្នកដទៃទៀតជាច្រើន ក៏មិនសូវមានអ្នកណាដឹងរឿងនេះជាពិតប្រាកដ មានដឹងខ្លះតែជារឿងដែលពូតែគេថា ដែលមិនមែនជាផ្លូវវិទ្យាសាស្ត្រដ៏ពិតប្រាកដឡើយ ឬមិនមែនជាផ្លូវស្រាវជ្រាវឲ្យផ្ទាត់រកដើមរកចុង ។ មន្ត្រីនោះបានប្រាប់ខ្ញុំទៀតថា គ្មានអ្នកណារៀនទេ ព្រោះមានទំនៀមប្រកាន់ថា អ្នកណាចាប់ពាល់ព្រះពុទ្ធរូបមានបាបដល់ខ្លួន បើជាស្ត្រីផងហើយ រឹតតែមិនហ៊ានចាប់ប៉ះពាល់សោះតែម្ដង ។ ខ្ញុំឆ្លើយថា ដែលលោកថានេះមិនពិតទេ ព្រោះមិនឃើញមានក្នុងគម្ពីរណានិយាយថា ចាប់ពាល់ព្រះពុទ្ធរូបមានបាបនោះទេ បើទុកជាមានបាប យើងក៏អាចសូមខមា-ទោសបានដែរ ដូចក្នុងពាក្យសូត្រថ្វាយបង្គំព្រះពេលល្ងាច កាលសូត្រ

សរសើរព្រះពុទ្ធគុណចប់ហើយ ក៏ត្រូវក្រាបចុះសូត្រថា:

កាយេន វាចាយ វ ចេតសា វា ពុទ្ធេ កុកម្មំ បកតំ មយា យំ
ពុទ្ធោ បដិគ្គណ្ហតុ អច្ចយន្តំ កាលន្តរេ សំវរិតុំ វ ពុទ្ធេ

ប្រែថា "ខ្ញុំព្រះករុណាបានប្រព្រឹត្តល្មើសគុណព្រះពុទ្ធជាម្ចាស់ ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី សូមព្រះពុទ្ធអង្គទ្រង់អត់ទោសដល់ខ្ញុំព្រះករុណា ដើម្បីសំរួមគុណព្រះពុទ្ធជាម្ចាស់តទៅ" ។ នេះជាពាក្យសូមខមាទោស ដែលពុទ្ធបរិស័ទធ្លាប់ប្រតិបត្តិមក; បើពាក្យសូមខមាទោសមានហើយ ហេតុអ្វីក៏នៅតែចាប់ពាល់មិនបាន? មន្ត្រីនោះប្រាប់មកខ្ញុំទៀតថា ទោះបីមានពាក្យសូមខមាទោសបាន ក៏នៅតែមិនមានអ្នកណារៀន ព្រោះរៀនរួចហើយ ក៏មិនបានអ្វី ខ្ញុំដឹងណាស់រដ្ឋាភិបាលយកធ្វើការ ២-៣ នាក់ ហើយឱ្យប្រាក់ខែបន្តិចបន្តួចបាយហយមិនគ្រប់គ្រាន់ បើដូច្នេះមានអ្នកណាទឹងចង់រៀន ។ - នេះខ្ញុំក៏ឃើញពិតដូច្នោះដែរ ព្រោះថាបើគ្មានការទាក់ទងដោយការចិញ្ចឹមជីវិតទេ មិនមានអ្នកណាចង់រៀនសោះឡើយ ព្រោះមនុស្សគ្រប់គ្នាត្រូវការរៀនតែចំណេះវិជ្ជាដែលចិញ្ចឹមជីវិតបាន ។ សេចក្តីនេះជារឿងពិត ចំណេះណាដែលទាក់ទងដោយការចិញ្ចឹមជីវិត ត្រូវតែរៀន បើមិនជឿ សូមអញ្ជើញទៅសួរចិនដែលលក់បុរាណវត្ថុនៅ ផលធាតរៈខ្យម (ណាខន ខ្យម) មើលចុះ សួរគេថា ព្រះពុទ្ធរូបអង្គនេះ សាងក្នុងសម័យណា គេនឹងប្រាប់លោកឱ្យដោយថា សាងក្នុងសម័យនោះ សតវត្សទីប៉ុណ្ណោះ ហើយបើជាបុរាណវត្ថុដែលចាស់ជាងគេ គេ

គំរាយតម្លៃយ៉ាងថ្លៃបំផុត ៗ ខនេះបញ្ជាក់ឲ្យឃើញថា បើចំណេះណាគេប្រើក្នុងការអាជីពហើយ គេត្រូវតែរៀនឲ្យចេះឲ្យដឹងដោយខានមិនបាន ព្រោះជាប្រយោជន៍ក្នុងការស្វែងរកប្រាក់កាសឲ្យរឹតតែចំណេញច្រើនឡើង ៗ ក្នុងពេលនេះអ្នកដែលរៀនដោយមិនប្រាថ្នានឹងប្រកបអាជីពក៏មានច្រើនណាស់ដែរ តែដោយច្រើន ច្រើនតែអ្នកដែលមានចំណេះប្រកបអាជីពស្រេចហើយ រៀនរឿងព្រះពុទ្ធរូប រូបរូមព្រះពុទ្ធរូប ឬសិក្សារឿងព្រះពុទ្ធរូប,ជាការពិសេស តែការពិសេសនេះ ពួកអឺរ៉ុបប្រកាន់ថាជាការសំខាន់ជាងការចិញ្ចឹមជីវិតទៅទៀត អ្នកដែលមានកេរ្តិ៍ឈ្មោះក៏ព្រោះគេបានធ្វើការពិសេស ដូចជាសម្តេចក្រុមពញាតម្រង់រាជា-នុភាព, ការងាររបស់ព្រះអង្គដោយច្រើនជារឿងដែលទាក់ទងដោយការគ្រប់គ្រងស្រុកទេស និងការសិក្សា; រឿងពិនិត្យព្រះពុទ្ធរូបជាការពិសេសរបស់ព្រះអង្គ ព្រោះដូច្នោះទ្រង់ទើបមានព្រះកិត្តិយសប្រាកដទូទៅក្នុងនានាប្រទេស គប់ ៗ សមាគមនិងគប់មន្ទីរសារមោសរ ដែលទាក់ទងដោយវិជ្ជាសេចក្តីចេះដឹង គេទទួលស្គាល់ទ្រង់ថាជាអ្នកចេះដឹង ១ ក្នុងលោក សឹងតែអញ្ជើញស្តេចឲ្យទៅជួយឧបត្ថម្ភក៏មាន ឲ្យស្តេចទៅជាសមាជិកកិត្តិយសក៏មាន ឲ្យទៅធ្វើ៚ប្រធានឬធ្វើជាអ្វីដទៃទៀតក៏មាន ចំណែកវិជ្ជាការគ្រប់គ្រងស្រុកប្រទេស និងការសិក្សានោះមិនសូវមានអ្នកណាស្គាល់ព្រះអង្គប៉ុន្មានទេ ទទួលស្គាល់ទ្រង់តែក្នុងរង្វង់ការដែលទ្រង់កាន់កាប់ប៉ុណ្ណោះ បើវិជ្ជាការខាងបុរាណគតិវិញ ច្បាស់ជាស្គាល់ទ្រង់ទូទៅទាំងលោក ៗ ម្យ៉ាងវិញទៀតមន្ត្រីនោះបានប្រាប់ខ្ញុំថា

ក្បួនតំរាដែលនឹងយកមករៀនលក្ខណៈព្រះពុទ្ធរូបបុរាណនោះមិនមាន បើមានខ្លះច្រើនតែជាភាសាអ៊ឺរ៉ុប ឬភាសាបាលី ដែលមនុស្សធម្មតាមើលមិនបាន ។ តាមការពិតរឿងនេះដូច្នោះមែន អំពីដើមសៀវភៅរៀនលក្ខណៈព្រះពុទ្ធរូបទាំងនោះកម្រនឹងរកបានណាស់ តែឥឡូវនេះមានច្រើនបែបហើយ រឿងនេះព្រះពុទ្ធរូបបុរាណនេះ បុព្វបុរសយើងត្រូវការឲ្យយើងសិក្សាសូត្ររៀនណាស់ ទើបលោកព្យាយាមតែងតម្រាយ៉ាងល្អៗ ដែលត្រូវប្រើជាបែបសិក្សាទុកច្រើនយ៉ាង ដូចសៀវភៅព្រះពោធិវង្ស ពួកឡាន-ណា-ថៃតែង, សិហិង្គនិទាន ដំណាលរឿងព្រះពុទ្ធសិហិង្គ ហើយព្រះព្រហ្មរាជបញ្ញា ពួកសុខោទៃ (សុខោថៃ) តែង, រតនពិម្ពវង្ស គឺរឿងព្រះកែវមរកតនេះជាតម្រាបុរាណដែលយើងធ្លាប់រាប់អានសិក្សាសូត្ររៀនមកជាភាសាបាលី តែឥឡូវនេះប្រែជាភាសាថៃហើយ អ្នកដែលមិនចេះភាសាបាលីត្រូវរកសៀវភៅដែលជាភាសាថៃមកសិក្សាចុះ ។

(មានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងអ្នកស្នេហាជាតិ សាសនា មហាក្សត្រ

ឃុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ ស្រង់ចាកគម្រាផ្សេង ៗ

---

## គំនិតរបស់អ្នកដកស្រង់

រឿងអ្នកស៊ូប្ដូរជីវិត ដើម្បីនឹងជួយស្រោចស្រង់ប្រទេសជាតិ, ជួយទ្រទ្រង់ព្រះពុទ្ធសាសនា, ជួយដំកើងព្រះមហាក្សត្រ និងជួយសង្គ្រោះអ្នកដទៃនេះ មិនមែនខ្ញុំតែងតាមគំនិតខ្លួនខ្ញុំទេ គឺខ្ញុំបានដកស្រង់យកមកអំពីច្បាប់ផ្សេងៗ ដែលលោកជាន់ដើមបានតែងទុកស្រាប់ហើយ ។ ខ្ញុំគ្រាន់តែស្រង់ដោយសេចក្ដីសង្ខេបយកតែត្រួសៗមកក្នុងទីនេះ ។

រឿងនេះ ខ្ញុំយល់ឃើញថា មានសារប្រយោជន៍ជាយ៉ាងសំខាន់ណាស់ដល់មនុស្សគ្រប់ប្រភេទ ទាំងប្រុសស្រី ទាំងក្មេងចាស់ ទាំងគ្រហស្ថបព្វជិត ទាំងក្សត្រមន្ត្រី ។ ដ្បិតមនុស្សគ្រប់រូបដែលកើតមកក្នុងលោកនេះ ដែលនឹងមានជីវិតរស់នៅជាសុខសប្បាយបានដោយសារតែប្រទេសជាតិចំរើនរុងរឿង, ដែលប្រទេសជាតិបានរុងរឿងក៏ដោយសារតែអ្នកប្រទេសនោះប្រតិបត្តិតាមសាសនាផង គោរពជឿកាន់តាមច្បាប់នៃព្រះមហាក្សត្រផង ជួយសង្គ្រោះគ្នាទៅវិញទៅមកផង ។

ហេតុនេះ យើងគួរយកតម្រាប់តាមអ្នកស្នេហាជាតិ សាសនា មហាក្សត្រ ដូចមាននិទានតទៅនេះ ៖

# ១ — រឿងអ្នកស៊ូប្តូរជីវិតជួយប្រទេសជាតិ

## រឿងអ្នកឧញ៉ាមនោមេត្រី (១)

ក្នុងរជ្ជកាលនៃព្រះបរមរាជាពញា តន់ ព. ស. ២១៣០ គ. ស. ១៥៨៦ នៅប្រទេសខ្មែរ បានធ្វើចំបាំងនឹងប្រទេសសៀម ។ គ្រានោះមានមន្ត្រីខ្មែរម្នាក់ឈ្មោះជា ឧកញ៉ាមនោមេត្រី ហៅហ្វាយស្រុកបាត់ដំបងនិង ឧកញ៉ាបវរនាយក បានដឹងថាកងទ័ពខ្មែរដែលឲ្យលើកទៅការពារទប់ទ័ពសៀមនោះ ត្រូវបាញ់ទ័ពសៀមៗ វាយយកបានខែត្រជាច្រើន ។

ឧកញ៉ាទាំងពីរនាក់ប្រឹក្សានឹងមេទ័ពទាំងពួងថា “ទ័ពសៀមលើកមកជាន់នេះក្លៀវក្លាណាស់ ដូចកទ័ពព្រះមហាក្សត្រសៀមកាន់តែមកជិតដល់ខែត្រយើងហើយ យើងនឹងច្បាំងឬដូចម្តេច?” ។ មេទ័ពទាំងពួងឆ្លើយថា “ការដែលព្រះបាទអ្នកម្ចាស់ត្រាស់ប្រើយើងមកនេះ ដើម្បីឲ្យធ្វើសង្គ្រាមនឹងសៀម បើយើងមិនទាន់បានច្បាំងសោះ ហើយលើកទ័ពថយទៅវិញ ឲ្យស្រុកធ្លាក់ទៅដៃពជសត្រូវទទេៗ នោះឃើញជាការមិនគួរ ខុសនឹងព្រះរាជអាជ្ញា គួរតែយើងច្បាំងល្បងមើលកំឡាំងសិន បើមិនឈ្នះគេទេ ចាំថយទៅតាំងច្បាំងនៅខែត្រពោធិ៍សាត់ទៀត” ។

វេលានោះ អ្នកឧកញ៉ាមនោមេត្រីនឹងមេទ័ពទាំងពួងយល់ព្រមព្រៀងគ្នា ទើបចាត់កងទ័ពឲ្យលើកទៅចោមព័ទ្ធវាយបន្ទាយសៀមនៅ

---

១ ; ស្រង់ចាកច្បាប់ព្រះរាជពង្សាវតារខ្មែរ ភាគ ទី ៤ អក្សរដៃ ត្រង់ទំព័រលេខ ២៥៥ - ២៦១ មានក្នុងពុទ្ធសាសនបណ្ឌិត្យ ។

ស៊ឹងគ្នា; ទ័ពខ្មែរបាញ់ទ័ពសៀមរត់ដោះថយមកតាំងបន្ទាយនៅខែត្របាត់ដំបងវិញ ។ អ្នកឧកញ៉ាទាំងពីរដឹងថាទ័ពសៀមលើកតាមមកទាន់ហើយ ក៏លើកទ័ពចេញច្បាំងតទល់នឹងទ័ពសៀម ។ ពេលនោះ ឧកញ៉ាបវរនាយកត្រូវគ្រាប់កាំភ្លើងស្លាប់ក្នុងសង្គ្រាម ។ ឧកញ៉ាមនោមេត្រីឃើញឧកញ៉ាបវរនាយកស្លាប់ដូច្នោះហើយ ក៏ទុកតូចចិត្តណាស់ បង្គាប់ឲ្យបក់ទង់ជ័យថយទ័ពចូលបន្ទាយវិញ ។

ព្រះនរេន្ទសូរស្តេចសៀមលើកទ័ពតាមមក ឲ្យបោមព័ទ្ធបន្ទាយខ្មែរនៅបាត់ដំបង ។ បណ្តារាស្ត្រខ្មែរឃើញទ័ពស្តេចសៀមលើកមកជាច្រើនដូច្នោះ ក៏មានចិត្តភិតភ័យជញ្ជូនទ្រព្យសម្បត្តិ ប្រពន្ធកូនចៅរត់ចូលពួនព្រៃអស់ ។ ពួកពលសៀមឃើញផ្ទះទទេគ្មានមនុស្សនៅ ក៏ដើររើជញ្ជូនយកទ្រព្យរបស់ដែលសេសសល់ព្រមទាំងស្រូវអង្ករយកជាស្បៀងអាហារអស់ហើយ ក៏ដុតផ្ទះសម្បែងនេះអស់ ផ្សែងភ្លើងហុយងងិតឥពូមេឃ ។

ឧកញ៉ាមនោមេត្រីដឹងដូច្នោះហើយលែងគិតខ្លាចស្លាប់ ព្រោះអាណិតបណ្តារាស្ត្រណាស់ ស្រែកប្រកាសប្រាប់សេនាទាហានថា « ព្រះចៅក្រុងស្រីអយុធ្យាលើកទ័ពមកជាន់នេះ ដោយចំណងនឹងយកក្រុងកម្ពុជាជាចំណុះឲ្យបាន ខែត្រយើងនេះជាទ្វារនាំងព្រះនគរ បើគេវាយខែត្រយើងនេះបែកហើយ គេនឹងទៅដល់ក្រុងពុំខាន មួយទៀត យើងជាប់ក្នុងចំណោមគេហើយ ប្រៀបដូចជាដំរីជាប់ប្រកាំនឹងសៀមពុំបាន ត្រូវតែគិតដោះពីប្រកាំឲ្យរួចទើបហៅថា ដំរីសារ ជាតិជាប្រុសត្រូវកុំខ្លាចសង្គ្រាម ទើបហៅថាប្រុស វេលានេះយើងកុំស្តាយជីវិត ត្រូវយកឈាម

លាបផែនដី ទុកកេរ្តិ៍ឈ្មោះឲ្យសេនាទាហានខាងក្រោយដឹងថា ខ្ញុំឧកញ៉ាមនោមេត្រី មានចិត្តកតញ្ញូនឹងព្រះបាទអ្នកជាម្ចាស់ ស៊ូប្តូរជីវិត ហេតុនេះត្រូវតែយើងលើកទ័ពចេញច្បាំងតទល់នឹងទ័ពព្រះមហាក្សត្រសៀម ឲ្យអស់ជំរះ តើអ្នកកល់គ្នាយល់ដូចម្តេច?'' ។ មេទ័ពទាំងអស់ឆ្លើយថា ''យើងខ្ញុំកល់គ្នាក៏មិនស្តាយជីវិតដែរ ទំពាសៀមជាទ័ពព្រះមហាក្សត្រ យើងជាទ័ពខែត្រក្រៅតនឹងព្រះមហាក្សត្រពុំបានទេ ប៉ុន្តែស៊ូច្បាំងឲ្យឃើញថ្វីដៃ'' ។ ឧកញ៉ាមនោមេត្រីឮដូច្នោះ ក៏ត្រេកអរណាស់ទើបចាត់សេនាទាហាន ១ ម៉ឺនឲ្យចេញច្បាំងនឹងទ័ពសៀម ខ្លួនឯងជិះដំរីនាំពលចេញច្បាំងឥតខ្លាចស្លាប់ ។

សម្តេចព្រះនរេន្ទ្រសូរទតពីលើដំរីព្រះទីនាំងទៅឃើញឧកញ៉ាមនោមេត្រីនៅលើដំរីបរពលចូលច្បាំងឥតក្លុកដូច្នោះ ក៏មានព្រះទ័យស្រឡាញ់ឧកញ៉ាមនោមេត្រី ។ វេលានោះ ដំរីដែលឧកញ៉ាមនោមេត្រីជិះនោះត្រូវគ្រាប់កាំភ្លើងដួលទៅ ។ ឧកញ៉ាមនោមេត្រីលោតចុះពីលើដំរីហូតដាវនាំពលចូលប្រកាប់នឹងសេនាសៀម ។ ព្រះនរេន្ទ្រសូរត្រាស់បង្គាប់ឲ្យចាប់ឧកញ៉ាមនោមេត្រីទាំងរស់ បានហើយនាំខ្លួនចូលថ្វាយ ទ្រង់ត្រាស់សួរថា ''អ្នកឯងងារជាអ្វី? ។ – ទូលព្រះបង្គំងារជាឧកញ៉ាមនោមេត្រី ចៅហ្វាយស្រុកបាត់ដំបងនេះ ។ – ចុះអ្នកឯងមិនដឹងថាយើងជាមហាក្សត្រទេឬ បានជាហ៊ានលើកទ័ពមកច្បាំងនឹងយើង? ។ – ទូលព្រះបង្គំជាខ្ញុំដឹង ប៉ុន្តែគិតឃើញថា ធម្មតាអ្នកធ្វើជាខ្ញុំផែនដីត្រូវតែមានចិត្តកតញ្ញូនឹង

អម្ចាស់ ត្រូវយកជីវិតជូនព្រះតេជៈព្រះគុណ ហើយទូលព្រះបង្គំជាមន្ត្រីមានថ្វីដៃ ដែលគិតស្តាយជីវិតដូចជាស្ត្រីមិនពេញជាប្រុសទេ អស់ខ្ញុំរាជការកើតមកគង់តែស្លាប់ដូចគ្នា ល្អអាក្រក់តាមកុសលអកុសល ធម្មតាធ្វើសង្គ្រាមតែងតែចាញ់និងឈ្នះ គួរតែយកជីវិតខ្លួនជូនទឹកផែនដី ទើបពេញជាមន្ត្រី ។

ព្រះនរេន្ទ្របុរបានទ្រង់ព្រះសណ្តាប់ពេញព្រះទ័យណាស់ ទើបសរសើរក្នុងព្រះទ័យថា ឧកញ៉ាមនោមេត្រីនេះមានចិត្តក្លាហានមែនប្រកបដោយសត្យកតញ្ញូ គួរតែអញចិញ្ចឹមទុក ទើបត្រាស់ថា ''វេលានេះជីវិតអ្នកឯង ទៅក្នុងកណ្តាប់ដៃយើងហើយ តែយើងអាណិតមិនសម្លាប់អ្នកឯងឡើយ ត្រូវអ្នកឯងនាំគ្រួសារមកថ្វាយបង្គំយើងដោយស្រួលចុះ យើងមិនធ្វើអន្តរាយដល់អាណាប្រជានុរាស្ត្រទេ'' ។

ឧកញ៉ាមនោមេត្រីបានស្តាប់ព្រះតម្រាស់ហើយគិតថា ''វេលានេះជីវិតអញនៅក្នុងកណ្តាប់ដៃរាជសត្រូវហើយ គួរតែអញទទួលព្រមតាមទៅចុះ ដើម្បីនឹងបានរក្សាប្រជារាស្ត្រក្នុងខែត្រតទៅ បើសៀមធ្វើការជយដៃអញនឹងលើកទ័ពវាយផ្ចប់ពីក្រោយទៀត'' គិតហើយទើបក្រាបទូលដោយផ្លូវឧបាយកលថា ''ការដែលទ្រង់ព្រះមេត្តាប្រោសកខ្លួនជីវិតទូលព្រះបង្គំក្នុងគ្រានេះ ទូលព្រះបង្គំជាខ្ញុំទទួលតាម ប៉ុន្តែសូមព្រះរាជាអនុញ្ញាតកុំឱ្យកងទ័ពសៀមធ្វើបាបបណ្តារាស្ត្រខ្មែរ'' ។ ស្តេចសៀមក៏ព្រមអនុញ្ញាត ទើបឱ្យឧកញ៉ាមនោមេត្រីទទួលរកពាក្យសច្ចារួចស្រេច ឱ្យទៅនាំក្រុមការនិងមេទ័ពមកគាល់ ។

ទុកញ៉ាំមនោមេត្រីប៉ាយបន្តិលាចូលទៅក្នុងបន្ទាយប្រជុំអស់ក្រមការបណ្ដាក្រស្ដីប្រាប់ថា ''វេលានេះយើងភាល់តម្រែះហើយ ត្រូវតែចុះចូលសិនទៅចុះ សិមគិតការតាមតម្រែះប្រាជ្ញាជាខាងក្រោយ ហើយនាំក្រមការទាំងពួងទៅគាល់ព្រះនរេន្ទសូរ ។ ទ្រង់ត្រាស់ប្រលោមលួងលោមថា ''យើងលើកទ័ពមកនេះ មិនមែនប្រុងធ្វើបាបឲ្យអ្នកទាំងពួងបានសេចក្ដីក្ដៅក្រហាយទេ ដ្បិតយើងឮថាព្រះចៅក្រុងកម្ពុជាពុំប្រកបដោយទសពិធរាជធម៌ដុតរំលាងព្រះពុទ្ធបដិមាករអំពីបុរាណពេលអស់ ធ្វើព្រះពុទ្ធសាសនាឲ្យសៅហ្មង យើងលើកទ័ពមកនេះប្រយោជន៍នឹងធ្វើឲ្យផែនដីទាំង ២ ឲ្យជាប់ជាព្រះរាជមេត្រីនឹងគ្នាដូចពីដើមវិញ ជាទីញុំាងព្រះពុទ្ធសាសនាឲ្យរុងរឿង អ្នកទាំងអស់ប្អូននាំគ្នាត្រឡប់ទៅភូមិលំនៅវិញចុះ'' ។ ព្រះនរេន្ទសូរត្រាស់យ៉ាងនេះដោយព្រះទ័យបំណងថា នឹងប្រមូលគ្រួខ្មែរយកទៅស្រុកសៀម ។

អាណាប្រជារាស្ត្រខ្មែរឮព្រះតម្រាស់ដូច្នោះហើយត្រេកអរណាស់នាំគ្នាទៅនៅតាមភូមិលំនៅរបស់ខ្លួនដូចដើមវិញ ។

*
* *

## ២ — រឿងអ្នកស្លាប់ជីវិតជួយព្រះពុទ្ធសាសនា

### រឿងអ្នកតាគុយ (១)

កាលនោះស្រុកកូសាំងស៊ីននៅជារបស់ខ្មែរនៅឡើយ ។ មានព្រះ

១ ស្រង់ចាកច្បាប់កម្ពុជសុរិយា ឆ្នាំ ១៩២៨ ។

មហាក្សត្រិយ៍ខ្មែរ១ ព្រះអង្គ ព្រះនាម អង្គមី ជាព្រះរាជបុត្រីនៃព្រះបាទ អង្គច័ន្ទ បានសោយរាជសម្បត្តិគ្រប់គ្រងដែនដីខ្មែរ ។

ក្នុងរជ្ជកាលនៃព្រះអង្គមីនោះ (ព.ស. ១៨៣៤ ដល់ ១៨៤១) មានយួនម្នាក់ឈ្មោះ ទៀង-មិញ-យ៉ាង ជាសេនាធិការធំរបស់ស្ដេចយួនលើកទ័ពមកបង្កាំងដណ្ដើមយកទឹកដីខ្មែរ ។ ស្ដេចអង្គមីបរាជ័យចាញ់ទ័ពយួន ។ ដណ្ដើមយកបានទឹកដីព្រៃនគរ, មីថរ, ឡុងហោ, ផ្សារដែក, បាសាក់, ព្រះត្រពាំង ។

ព្រះអង្គមីសោយរាជ្យបានតែ ៧ ឆ្នាំទ្រង់ទិវង្គតទៅ ។ ក្រោយនោះពួកយួនមានអំណាចជិះជាន់ញាំញីបណ្ដាជនខ្មែរ និងព្រះពុទ្ធសាសនាខ្លាំងណាស់ បង្គាប់ឲ្យពួកលោកសង្ឃខ្មែរស្លៀកខោពាក់អាវ ដូចជាពួកលោកសង្ឃយួន ។ ក្នុងសម័យនោះ មានចៅហ្វាយស្រុកខ្មែរម្នាក់ឈ្មោះ គុយ ជាអ្នកត្រួតត្រារក្សាខេត្តនេះ ប៉ុន្តែនៅក្នុងអំណាចយួន លោកនឹកតូចចិត្តពេកណាស់ ដោយបានឃើញពួកយួនជិះជាន់ជាតិខ្មែរញាំញីព្រះពុទ្ធសាសនាប្រាថ្នានឹងបំបាត់ភេទសមណៈដូច្នោះ លោកនឹករលឹកដល់គុណព្រះពុទ្ធសាសនា ហើយកើតសទ្ធាជ្រះថ្លាដ៏មានកំឡាំងខ្លាំងក្លាអាចហ៊ានបូជាជីវិតអាត្មាជួយព្រះពុទ្ធសាសនា ទើបលោកចូលទៅនិយាយនឹងពួកអ្នករាជការយួនថា "បណ្ដាជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនាហើយបានលះបង់ផ្ទះសម្បែង ទ្រព្យសម្បត្តិ ប្រពន្ធកូន ចូលមកកាន់ភេទជាសមណៈនេះ ត្រូវតែស្លៀកស្បង់ពាក់ចីពរតាមបែបច្បាប់លោកសង្ឃខ្មែរទើបហៅថាជាអ្នកបួសដោយត្រឹមត្រូវ មិនត្រូវឲ្យស្លៀកខោពាក់អាវ

ដូចជាពួកលោកសង្ឃយួនទេ" ។ ពួកអ្នកពជការយួនមិនព្រមស្ដាប់ ចេះតែបង្ខំញាំញីបៀតបៀនលោកសង្ឃខ្មែរឲ្យស្លៀកខោពាក់អាវ ដូចលោកសង្ឃយួន ។

លោកចៅហ្វាយស្រុក គុយ ឃើញដូច្នោះ អត់ទ្រាំមិនបាន ក៏គាត់ចិត្តស៊ូប្រថុយជីវិតខ្លួនប្ដូរនឹងព្រះពុទ្ធសាសនា ចូលទៅនិយាយនឹងអ្នកពជការយួនម្ដងទៀតថា "ខ្ញុំសូមឲ្យកេទអ្នកបួសនឹងកិច្ចការក្នុងព្រះពុទ្ធ-សាសនាខ្មែរ ដែលតាំងនៅក្នុងស្រុកនេះប្រតិបត្តិដូចពីដើមវិញ បើលោកយល់ព្រមតាមខ្ញុំសុំនេះហើយ សូមៈលោកសម្លាប់ខ្ញុំចុះ" ។ ពជការយួនក៏សុខចិត្តព្រមទទួលធ្វើតាមសន្យាហើយ ទុកកេទអ្នកបួសនឹងកិច្ចការខាងព្រះពុទ្ធសាសនារបស់ជាតិខ្មែរឲ្យនៅដូចដើម ទើបប្រហារជីវិតលោកចៅហ្វាយស្រុក គុយ នោះទៅ ។ ក្នុងវេលាដែលគេសម្លាប់លោកចៅហ្វាយស្រុក គុយ នោះ បង្កើតជាហេតុកេទដ៏អស្ចារ្យក្រៃលែង មេឃមីរស្រទំងងឹតចុះអ័ព្ទ ភ្លៀងបង្អុរយ៉ាងខ្លាំងអស់ ៧ យប់ ៧ ថ្ងៃ ។

ក្រោយពីពេលនោះមក បណ្ដាជនជាតិខ្មែរទាំងឡាយ បបួលគ្នាលើកសពលោកចៅហ្វាយស្រុកគុយ ធ្វើបុណ្យឈាបនកិច្ចរួចស្រេចហើយ បានកសាងចេតិយ ១ បញ្ចុះធាតុលោកទុកជារំលឹក នៅក្នុងវត្តកំពង់ធំ ខែត្រត្រាវិញ ខាងទិសឦសានវិហារ ។ ចេតិយនោះនៅមានរហូតមកដល់សព្វថ្ងៃនេះ ដោយមានអ្នកស្រុកចេះតែជួសជុលតៗគ្នាមក ។

រឿងលោកចៅហ្វាយស្រុក គុយ នេះ ប្រជាជនជាតិខ្មែរនៅដែនកូសាំងស៊ីន ស្រឡាញ់រាប់អានទឹកគុណលោកមិនភ្លេចថាជាអ្នកស៊ូប្ដូរជីវិត

ជួយទ្រទ្រង់ព្រះពុទ្ធសាសនាមែន បានតាំងគោរពបូជាប្រកាន់ថាជាអ្នកតាសម្រាប់ជួយកិច្ចការបុណ្យទានក្នុងផ្លូវព្រះពុទ្ធសាសនា ទាល់តែក្លាយទៅជាទំនៀមទម្លាប់ជាប់មកដល់សព្វថ្ងៃនេះ ។

*
* *

## ៣– រឿងអ្នកសុំប្តូរជីវិតជួយព្រះមហាក្សត្រ

រឿងអ្នកតាឃ្លាំងមឿង (១)

ក្នុងរជ្ជកាលនៃព្រះស្តេចកន ដែលរាជ្យ (គ.ស. ១៥០៥ ដល់-១៥៥១) ។ វេលានោះព្រះចន្ទរាជា ដែលគង់នៅឯស្រុកសៀមបានជ្រាបដំណឹងថា ក្នុងស្រុកខ្មែរកើតសឹកសង្គ្រាមច្បាំងគ្នាជាយូរឆ្នាំ ទើបទ្រង់ធ្វើឧបាយកលរត់រួចពីស្រុកសៀមមកដល់ខេត្តបាត់ដំបង ទ្រង់បញ្ចុះបញ្ចូលបណ្តារាស្ត្រធ្វើជាសេនាទាហានបានច្រើន ទ្រង់នាំលើកទ័ពមកវាយបន្ទាយនៅខេត្តពោធិ៍សាត់ទៀត ។ វេលានោះឧកញ៉ាសួគ៌ាលោក ដែលទៅហ្វាយស្រុកពោធិ៍សាត់ជាមេទ័ពខាងព្រះស្តេចកនបានដឹងថាព្រះចន្ទរាជា យាងមកគង់នៅខេត្តបាត់ដំបងហើយ ក៏កេណ្ឌរេហ៍ពលបាន ១ ម៉ឺននាក់ឲ្យចាំរក្សាបន្ទាយស្រុកពោធិ៍សាត់ ហើយធ្វើសំបុត្រទូលទៅព្រះស្តេចកនគ្រប់សេចក្តី ។

នៅក្នុងខេត្តពោធិ៍សាត់នោះ មានតាម្នាក់ឈ្មោះ មឿង បានដឹងថា ព្រះចន្ទរាជា យាងត្រឡប់ពីស្រុកសៀមមកគង់នៅខេត្តបាត់ដំបងហើយ

១ ស្រង់ចាកល្បាប់ព្រះរាជពង្សាវតារ ភាគទី ៣ អក្សរដៃ ត្រង់ទំព័រ ១៦០–១៦៥ មាននៅពុទ្ធសាសនបណ្ឌិត្យ ។

គាត់ក៏ចំដើរបញ្ចុះបញ្ចូលប្រមូលញាតិសន្តានបានគ្នា ៣ ពាន់នាក់ចូលធ្វើជាកងទ័ពឧកញ៉ាសួគ៌ាលោក កែវ លុះដល់វេលាយប់ស្ងាត់នាំទ័ពលុកសម្លាប់ឧកញ៉ាសួគ៌ាលោក កែវ ស្លាប់ក្នុងបន្ទាយ ហើយតាមឿងប្រកាសប្រាប់រេហ៍ពលទាំងអស់កុំឲ្យកិតភ័យថា ព្រះមហាក្សត្រជាអម្ចាស់យើងនឹងយាងមកដល់ក្នុងវេលាព្រឹកស្អែកនេះហើយ ។

លុះព្រឹកឡើងព្រះចន្ទរាជា យាងមកដល់ខែត្រពោធិសាត់មែន ទើបតាមឿងនាំក្រមការទាំងរេហ៍ពលចូលទៅថ្វាយបង្គំគាល់ទូលសព្វសេចក្តី ។ ព្រះចន្ទរាជាទ្រង់ត្រេកអរណាស់ត្រាស់សរសើរតាមឿងផ្សេងៗ ហើយចាត់ការឲ្យធ្វើបន្ទាយកាយចម្រឹងក្នុងខែត្រពោធិសាត់យ៉ាងមាំមួន ។

ព្រះចន្ទរាជាទ្រង់ឡើងសោយរាជសម្បត្តិគ្រប់គ្រងក្រុងកម្ពុជា ក្នុងព្រះជន្ម ៣៦ ឆ្នាំ ក្នុងឆ្នាំជូតអដ្ឋស័ក ព.ស ២០៦០ គ.ស. ១៥១៦ ទ្រង់ព្រះមេត្តាប្រោសតាំងតាមឿងឲ្យធ្វើជាឧកញ៉ាសួគ៌ាលោកចៅហ្វាយស្រុកខែត្រពោធិ៍សាត់ ហើយឲ្យធ្វើជាមេទ័ពផង ។ ឯឧកញ៉ាសួគ៌ាលោក មឿង បានតាំងកូនប្រុសទាំង ៤ នាក់ឲ្យធ្វើជាមេទ័ពលើកទៅវាយខែត្រក្រគរ, ខ្លុង, ក្រង ជាមុន ។

(មានត)

# រឿងព្រះបាទរុសក៉ានសាដ

នឹង

# ព្រះបាទសេហេរីស្តាង

អ្នកស្រីពេជ្រ–សល់ ហៅ សាវ៉ិះយ៉ាង ប្រែរៀបរៀង

---

ថ្ងៃមួយ ព្រះបាទរុសក៉ានសាដ ដែលជាយុវក្សត្រមួយព្រះអង្គ សោយរាជសម្បត្តិនៅនគរចិន, ទ្រង់បានទតឃើញឈ្លូសមួយសស្គុះ មានពណ៌ចុចខ្មៅហើយទឹងខៀវ ក្នុងពេលដែលទ្រង់យាងចេញទៅក្រសាលបរបាញ់ម្រឹគក្នុងព្រៃ ។ ឈ្លូសនោះមានកងមាសមួយនៅជើង ហើយមានកម្រាលធ្វើអំពីសំពត់លើបពណ៌លឿង ប៉ាក់សែសយព្រាក់នៅពីលើខ្នងផង ។ លុះទ្រង់បានយល់សត្វល្អបម្លែក ទ្រង់មានព្រះទ័យចង់បានយកទុកជាសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់ចាត់ឲ្យអមាត្យទឹងកងពលបំផាយសេះតាមចាប់ ក៏ប៉ុន្តែឈ្លូសនោះរត់លឿន ហើយបន្ទើរៗជើងលើដី គ្មានឃើញធូលីហុយឡើងបន្តិចសោះ ។ ព្រះអង្គទ្រង់ខ្វាល់ទឹងការដេញតាមឈ្លូសនោះមិនទាន់, តែបន្តិចមកស្រាប់តែទ្រង់ក្រឡេកព្រះនេត្រទៅឃើញឈ្លូសដេកនៅលើស្មៅ ក្បែរមាត់ត្រពាំងទឹកមួយ បែបដូចជាអស់កំលាំងល្ហិតល្ហើយ ព្រោះរត់ឆ្ងាយពេក ។ ព្រះអង្គទ្រង់ញាក់សេះឲ្យបោលសំដៅទៅជិតឈ្លូស, សត្វឈ្លូសលុះឃើញសេះបោលតម្រង់មករកខ្លួន ក៏ងើបឈរឡើងហើយដើរពីរបីជំហានចុះទៅក្នុងទឹកស្រាប់តែបាត់មួយរំពេច ។ ព្រះបាទរុសក៉ានសាដទ្រង់លោតចុះពីលើពាជី ដើររកមើលជុំវិញថ្លុកទឹក បាចក្រញាកទឹក ក៏នៅតែរកមិនឃើញ

ទ្រង់នឹកឆ្ងល់នឹងការអស្ចារ្យនេះណាស់ ទើបទ្រង់ព្រះដំរិះថា ឈ្លូសនេះប្រហែលមិនមែនសត្វព្រៃធម្មតាទេ គឺជាអាទិទេពមួយរូប ដែលចូលចិត្តដំណែងខ្លួនធ្វើជាសត្វ ដើម្បីនឹងមកប្រឡែងលេងនឹងពួកព្រានព្រៃទេដឹង? ។ ពួកអ្នកហែហមព្រះអង្គក៏ចូលចិត្តយល់ដូចព្រះអង្គដែរ ។

ក៏ប៉ុន្តែព្រះបាទរុសកាំនសាជ នៅតែធ្វៀងព្រះនេត្រទៅត្រង់ថ្លុកទឹកនោះទៀត ហើយចេះតែទ្រង់ដកដង្ហើមធំ មិនដឹងជាទ្រង់គិតដូចម្តេច ។ បន្តិចមកទ្រង់មានព្រះឱង្ការទៅនឹងរដ្ឋមន្ត្រីធំម្នាក់ឈ្មោះ មុយអេស៊ុន ថា ៖

– យប់នេះខ្ញុំនឹងសម្រាកនៅទីនេះ ដើម្បីមើលអាទិទេព ព្រោះខ្ញុំចេះតែនឹកមមៃថាខ្ញុំនឹងឃើញជាមិនខាន ។

លុះទ្រង់មានព្រះបន្ទូលហើយ ទើបបង្គាប់ឲ្យពួកសេនាទាហានថយទៅវិញអស់ ទុកតែលោកមុយអេស៊ុនឲ្យនៅកំដរព្រះអង្គ ។ ជនទាំងពីរនៅអង្គុយជជែកគ្នាអំពីសត្វឈ្លូសចម្លែករាល់តែព្រះអាទិត្យអស្តង្គត ។ បន្ទាប់មកព្រះបាទរុសកាំនសាជ ដោយទ្រង់នឿយអស់ព្រះកាយពលខ្លាំង ទ្រង់បង់ផ្ទំឲ្យលក់យកកំលាំង ទើបទ្រង់ត្រាស់បង្គាប់ទៅលោកមុយអេស៊ុនថា ៖

– លោកមុយអេស៊ុន ! ខ្ញុំងងុយណាស់ រឺងត្របកភ្នែកអស់ហើយនឹងទ្រាំនៅអង្គុយតទៅទៀតពុំបានទេ ដូច្នេះនៅពេលដែលខ្ញុំដេកលក់ ចូរលោកកុំដេក នៅយាមចាំគន់មើលទៅកន្លែងថ្លុកទឹកនេះ, បើលោកឃើញអ្វីផុសចេញពីកន្ធ្លឹកនោះមក ចូរលោកដាស់ខ្ញុំភ្លាម ។

ឯរដ្ឋមន្ត្រីដែលនៅកំដរស្តេច ទោះងងុយដេកយ៉ាងណាក៏ពុំហ៊ានដេក

ដោយបង់បំពេញព្រះទ័យស្តេច តែមិនយូរប៉ុន្មាន នាម៉ឺននោះក៏លង់លក់ទៅទៀត ៗ ព្រះរាជានិងអមាត្យទើបនឹងលក់បន្តិចសោះ ស្រាប់តែភ្ញាក់ព្រឺតទាំងពីរនាក់ ដោយឮសូរតូរ្យតន្ត្រីលាន់រងំ ហើយឃើញប្រាសាទមួយក្ដិចញាចល្អហួសវិស័យនៃស្នាដៃមនុស្សលោក ផុសនៅត្រង់ចុកទឹកនោះ ៗ ព្រះបាទសុរ៉ិនសាដត្រាស់សួរទៅលោកមុយអេស៊ីនថា ៖

— យី! ចុះសូរភ្លេងមកពីណា មុយអេស៊ីន? ហើយប្រាសាទនោះទៀត តើផុសពីណាមក? នេះប្រាកដជាមិនមែនប្រាសាទធម្មតាទេ ៗ

— ក្រាបទូលព្រះករុណាថ្លៃវិសេស! នេះមិនគឺអ្វីក្រៅអំពីការផុសទេ... ទុ! បើសិនជាយើងនាំគ្នាដើរចេញពីកន្លែងនេះទៅ ប្រហែលជាគាប់ចិត្តទេវតា ក៏នៃអ្នកណាមិនដឹង ប្រាកដជាអ្វី ក្រែងប្រាសាទនេះជាអន្ទាក់ដែលមេធ្មប់បោះដាក់ព្រះអង្គទេក៏មិនដឹង?

— អ៊ឹះ! ដោយ លោកកុំស្មានថាខ្ញុំខ្លាចមិនហ៊ានទៅនោះ មកទៅ! យើងទៅមើលឲ្យឃើញ តើអ្នកណាខ្លះនៅទីនោះ ៗ

ព្រះមហាក្សត្រនិងលោកមុយអេស៊ីន នាំគ្នាដើរតម្រង់ទៅទីប្រាសាទ ហើយឃើញទ្វារចំហ ក៏ដើរចូលទៅក្នុងទីធ្លាមួយធំ ហើយដើរចូលទៅក្នុងបន្ទប់មួយ ក្រាលសុទ្ធតែឥដ្ឋធ្វើអំពីសាច់ដីដូចចានស្រកចិន ហើយមានពូកកំណាល់សម្រាប់អង្គុយ មានកម្រាលសុទ្ធសឹងប៉ាក់ខិន ហើយផ្ទុំចំហាយក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់ ប៉ុន្តែគ្មានឃើញមនុស្សម្នាក់សោះ ទ្រង់យាងកាត់បន្ទប់នេះទៅចូលបន្ទប់មួយទៀត ឃើញសុទ្ធតែស្រីក្រមុំប្រហែលជាហាសិបឬហុកសិបនាក់ ស្លៀកពាក់ពណ៌ផ្កាកុលាប ហើយមានផ្សរផង

ខ្សែគ្លាប់ទឹងសាច់សំពត់ផង ។ ស្រីទាំងនោះឈរដេញពិណហើយច្រៀង នៅចំពោះមុខស្រីម្នាក់ អង្គុយលើបល្ល័ង្កមាសរំលេចដោយពេជ្រមុក្តា ស្រីនោះមានរូបល្អផ្ដើឲ្យព្រះបាទរុសរ៉េនសាដរំភើបព្រះហឫទ័យជាខ្លាំង ។

ទ្រង់ខុនគិតចាប់ព្រះនាង ហើយយាងចូលរហូតទៅដល់កណ្ដាលប្រជុំជន ។ ពួកស្រីៗឃើញភ្ញៀវហើយ ក៏នាំគ្នាបញ្ឈប់ភ្លេង បញ្ឈប់ចម្រៀង ។ ព្រះអង្គទ្រង់មានព្រះឱង្ការទៅកាន់ព្រះនាងថា:

— ឱ ! ម្ចាស់ក្សត្រីអើយ ! ដោយសារតែកែវព្រះនេត្រព្រះនាងនេះហើយ បានជាខ្ញុំដែលជាស្ដេចប្រទេសចិនធ្លាក់ខ្លួនទៅជាទាសៈនៃសេចក្ដីស្នេហា ។ ដូច្នេះ សូមព្រះនាងព្រះរាជទានអភ័យទោសដល់ខ្ញុំ ហើយសូមព្រះនាងមេត្តាប្រាប់ឈ្មោះស្រីទេពកញ្ញា ដែលគ្រាន់តែខ្ញុំក្រឡេកឃើញ ធ្វើឲ្យខ្ញុំរំភើបចិត្តជាខ្លាំង ។

ព្រះនាងទ្រង់ព្រះសណ្ដាប់ហើយក៏ញញឹម ហើយទ្រង់ត្រាស់តបថា :

— ខ្ញុំជាសត្វឈ្លូសមួយដែលកាចបង្ខំដល់ទៅសត្វសិង្ហបាន រូបខ្ញុំនេះហើយជាសត្វឈ្លូសដែលអ្នកបានដេញតាមមក, ដើម្បីនឹងដោះខ្លួនឲ្យរួចអំពីដៃអ្នក ខ្ញុំបានលោតចូលក្នុងចក់ទឹក ។

ព្រះមហាក្សត្រធ្ងល់ណាស់ ទ្រង់ត្រាស់សួរទៀតថា ៖

— ឱ ! ព្រះនាង ! ចុះហេតុអ្វីបានជាព្រះនាងប្រែកាយទៅជាយ៉ាងដូច្នេះ? គួរឲ្យខ្ញុំគត់ស្ងួតណាស់, តើរូបព្រះនាងដែលបង្ហាញឲ្យខ្ញុំឃើញនៅពេលនេះ ជារូបនិម្មិតបន្ទំទេឬ?

— ទេ គឺជាធម្មជាតិរបស់ខ្ញុំ តែតាមពិតគឺខ្ញុំផ្លាស់ភេទជាសត្វទៅពេលណាដែលខ្ញុំចង់ផ្លាស់, ខ្ញុំចង់ឲ្យមនុស្សឃើញក៏បាន មិនឲ្យឃើញក៏បាន ប៉ុន្តែមិនមែនខ្ញុំសូត្រសែកមន្តអាគមអ្វីទេ គឺជាធម្មជាតិរបស់ខ្ញុំតាំងតែអំពីកំណើតមកតែម្តង ។

ត្រាស់ហើយ ព្រះនាងយាងចុះពីលើព្រះទែន មកចាប់ព្រះហស្តព្រះមហាក្សត្រនាំចូលទៅក្នុងបន្ទប់មួយ ដែលមានគុម្ពយពាសពេញទៅដោយម្ហូបយ៉ាងឆ្ងាញ់ៗ ។ ព្រះនាងទ្រង់គង់នៅកណ្តាល ព្រះមហាក្សត្រទ្រង់គង់អមម្ខាង, លោកមុយអេសុីនអង្គុយអមម្ខាង, ប៉ុន្តែលោកនេះ មិនមានទឹកមុខរីករាយសោះ ព្រោះខ្លាចមានគ្រោះថ្នាក់ដល់ខ្លួន ។ ចំណែកព្រះបាទរុស្សាំងសាដរិញ ទ្រង់ត្រេកអរពេក ទ្រង់គ្មាននឹកដល់គ្រោះថ្នាក់អ្វីបន្តិចសោះ ទ្រង់ងាកទៅរកព្រះនាង ដើម្បីនឹងលើកម្ហូបថ្វាយព្រះនាង ប៉ុន្តែព្រះនាងមានព្រះបន្ទូលថា :

— សូមទ្រង់សោយតែព្រះអង្គនិងមន្ត្រីទៅចុះ ពួកខ្ញុំម្ចាស់ទាំងអស់គ្នានៅទីនេះស្រេចតែក្លិនអាហារប៉ុណ្ណោះទេ ។

លុះដល់ព្រះមហាក្សត្រនិងរដ្ឋមន្ត្រីបរិភោគអាហារស្រេចហើយ មានស្រីពីរនាក់យកកែវចរណៃពីរដាក់ស្រាពណ៌ក្រហម នាំមកថ្វាយព្រះអង្គហើយថែមស្រានោះមិនឲ្យកន្ទុះទាន់ទេ ។ គេយកស្រាបែបនេះមកថ្វាយព្រះនាងដែរ តែព្រះនាងគ្មានសោយបន្តិចបន្តួចសោះ ព្រះនាងគ្រាន់តែហិត ៗ ប៉ុន្តែគេឃើញផលនៃស្រានោះលើព្រះភក្ត្រព្រះនាងដូចជានៅលើព្រះភក្ត្រព្រះមហាក្សត្រដែរ ។ អ្នកទាំងបីស្រវឹងស្រាតែរៀងខ្លួន

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលបែបនឹងព្រះនាង ហើយព្រះនាង ក៏បណ្ដោយបន្ទន់ខ្លួនតាមព្រះអង្គ ហើយមានបន្ទូលទៅកាន់ព្រះអង្គថា ៖

– ទោះព្រះអង្គមានឋានៈទាបជាងខ្ញុំម្ចាស់ក៏ដោយ ក៏ខ្ញុំម្ចាស់មិនអាចនឹងព្រមមិនស្រឡាញ់ព្រះអង្គបានឡើយ, ដើម្បីនឹងឲ្យព្រះអង្គជ្រាបនូវដំណើរនៃចិត្តរបស់ខ្ញុំ ចង់ទូលព្រះអង្គអំពីជាតិកំណើតរបស់ខ្ញុំនៅពេលនេះក្លាមមិនបង្អង់ «ក្រាបទូលព្រះមហាក្សត្រ! នៅក្នុងមហាសមុទ្រមានកោះមួយឈ្មោះ សេរេហ៍ស្ដង់ មានសុទ្ធតែអាទិទេពនៅ ហើយមានស្ដេចសោយរាជ្យព្រះនាម មេឌូតសែរ ។ ព្រះអង្គមានព្រះរាជបុត្រីតែមួយព្រះអង្គ គឺខ្ញុំម្ចាស់នេះឯង ហើយខ្ញុំម្ចាស់ឈ្មោះសេរេហ៍ស្ដានី ខ្ញុំម្ចាស់បានចេញឃ្លាតពីព្រះបិតាខ្ញុំម្ចាស់មកបីខែហើយ ដើម្បីនឹងធ្វើដំណើរទៅមើលស្រុកទេសផ្សេងៗ ដែលមានមនុស្សនៅ ។ លុះខ្ញុំបានដើរមើលនគរផ្សេងៗគ្រប់អស់ហើយក្នុងលោក, ហើយខ្ញុំនឹងត្រឡប់ទៅនគរវិញ ខ្ញុំម្ចាស់ក៏បានផ្លងកាត់តាមនគរព្រះអង្គនេះ ហើយបានឃើញរូបព្រះអង្គ ខ្ញុំម្ចាស់ចាប់ចិត្តស្រឡាញ់ព្រះអង្គតាំងពីពេលនោះមក ហើយខ្ញុំម្ចាស់ហួសចិត្តនឹកតែក្នុងចិត្តខ្ញុំម្ចាស់ថា «គួរអ្វីមករំភើបចិត្តចំពោះរូបមនុស្សលោកយ៉ាងនេះ» តើបុកខ្ញុំដែលធ្លាប់តែធំ ហេតុម្ដេចក៏ថយមកស្រឡាញ់រូបមនុស្សម្នាក់នេះវិញ? ខ្ញុំម្ចាស់នឹកអៀនខ្លួនពន់ពេក ខ្ញុំម្ចាស់ចង់ជៀសចេញឲ្យឆ្ងាយពីព្រះអង្គ ប៉ុន្តែខ្ញុំម្ចាស់មិនដាច់ចិត្តសោះ ។ ម៉្លោះហើយ ដោយអំណាចនៃសេចក្ដីស្នេហារបស់ខ្ញុំម្ចាស់ៗ ក៏គិតតែរកមធ្យោបាយណា ឲ្យបានតែទ្រង់សព្វព្រះរាជហឫទ័យ ។ ខ្ញុំម្ចាស់ក៏តាំងតែងខ្លួនធ្វើជាឈ្លួស

សមួយក្លាម ហើយចេញបង្ហាញខ្លួនចំពោះព្រះនេត្រទ្រង់ ដើម្បីឲ្យទ្រង់មកតាមខ្ញុំម្ចាស់ ។ ព្រះអង្គក៏បានតាមខ្ញុំម្ចាស់រហូតមកដល់ថ្លុកទឹកនេះ ខ្ញុំម្ចាស់សប្បាយចិត្តពេកណាស់ ដោយឃើញព្រះអង្គខំត្រេកត្រអាលទឹករកខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់ខំត្មៀនត្រចៀកស្តាប់ទ្រង់ ខ្ញុំម្ចាស់ត្រេកអរណាស់ ដែលព្រះអង្គមានព្រះឧង្ការថា ទ្រង់នឹងផ្តុំនៅលើមាត់ទឹកនេះ ។ នៅពេលដែលទ្រង់ផ្ទំលក់ ខ្ញុំម្ចាស់បង្គាប់ឲ្យគេសង់ប្រាសាទនេះ ដើម្បីនឹងទទួលព្រះអង្គ ។ ពួកអាទិទេពបានសង់ប្រាសាទនេះតែមួយភ្លែតហើយក្លាម ។

ព្រះនាងសេហេរីស្តាទីរៀបនឹងមានបន្ទូលតទៅទៀត ស្រាប់តែមានស្រីបំរើម្នាក់ ទឹកមុខស្រងូតចូលមកទូលព្រះនាងថា ៖

— ឱ ! ព្រះនាង, ព្រះនាងជាបទេះ ពួកកាទិទេព ដើម្បីនឹងរស់នៅបានយូរជាងមនុស្សលោក មិនមែនទុកខ្លួនឲ្យស្លាប់ទេ, ឥឡូវនេះព្រះរាជបិតាព្រះនាង បានផ្លងពីជីវភាពមិនទៀងទាត់ ទៅកាន់ជីវភាពទៀងទាត់ហើយ ។ បណ្តាភស្តុ សូមឲ្យព្រះនាងយាងទៅគ្រប់គ្រងរាជ្យស្នងព្រះអង្គ ហើយនឹងចាំរៀបអភិសេកព្រះនាង បើដូច្នេះ សូមព្រះនាងយាងទៅទទួលអភិវឌ្ឍនាការ នៃនាម៉ឺនសព្វមុខមន្ត្រីព្រះនាង ព្រោះរដ្ឋមន្ត្រីទាំងឡាយនាំគ្នារង់ចាំត្រៀបត្រា ។ រោកករដ្ឋមន្ត្រីដែលជាឪពុកខ្ញុំម្ចាស់បានប្រើខ្ញុំម្ចាស់យ៉ាងប្រញាប់ ឲ្យមកអញ្ជើញព្រះនាងស្តេចទៅ ។

ព្រះនាងកាលបានឃើញសេចក្តីទុក្ខធ្លាក់មកលើខ្លួន ក៏ទ្រង់ព្រះ

កឡើងសោក , ព្រះបាទរុសេនាដក៏ស្រងូតស្រងាត់ដោយអាណិតព្រះនាង ៗ ក៏មានបន្ទូលថា ៖

— នៃម៉ែម្ជុណា ! ខ្ញុំនឹងទៅជាមួយនឹងនាងឥឡូវនេះ . . . បើដូច្នេះខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គហើយ ព្រោះគង់ពេលនេះខ្ញុំត្រូវតែឃ្លាតអំពីព្រះអង្គ" ថាហើយព្រះនាងហុចព្រះហស្តព្រះនាងទៅថ្វាយស្តេច, ព្រះមហាក្សត្រទ្រង់ទទួលទាញមកថើបដោយសេចក្តីស្នេហាយ៉ាងខ្លាំង ៗ ព្រះនាងមានបន្ទូលតទៅទៀតថា "សូមព្រះអង្គជឿជាក់ថាយើងមុខជានឹងបានជួបគ្នានៅថ្ងៃណាមួយមិនខាន ហើយបើដល់ថ្ងៃនោះហើយ ខ្ញុំឃើញទ្រង់នៅតែមានព្រះទ័យស្មោះត្រង់នឹងខ្ញុំម្ចាស់ដដែល នោះខ្ញុំម្ចាស់គ្មានទទួលអ្នកឯណាមកធ្វើជាព្រះស្វាមី ក្រៅអំពីព្រះអង្គទេ ។

ក្រោយពីមានព្រះបន្ទូលដូច្នេះហើយ ស្រាប់តែបាត់ព្រះនាងសេហេរ៍ស្តាទី កាលបាត់ព្រះនាងហើយស្រាប់តែងងឹតឈឹងសូន្យមួយរំពេច បាត់ពន្លឺទៀននឹងពន្លឺចង្កៀង ព្រះមហាក្សត្រចិននឹងរដ្ឋមន្ត្រីង៉ើមង៉ាមង្ងេង្ងោមិនដឹងជាទៅខាងណាមកខាងណា បើងងឹតបាក់ក្អកមិនយល់យ៉ាងនេះ ៗ លុះភ្លឺស្វាងឡើងកាលណា ស្រាប់តែបាត់ប្រាសាទអស់ ឃើញតែវាលល្ហល្ហេវតែផ្ទះមួយគ្មាន ៗ ព្រះមហាក្សត្រសួរទៅលោកមុយអេស៊ីនថា:

— ម៉េចមុយអេស៊ីន ! តើការណ៍ដែលយើងឃើញទាំងប៉ុន្មាននោះជាយល់សប្តិឬយ៉ាងណា ?

— ក្រាបទូលមិនមែនទេ ប្រាកដជាអំពើរបស់ពួកជប់, ក្សត្រ

ដែលយើងឃើញនោះ ច្បាស់ជាស្រីបេះធ្ងប់ ហើយដើម្បីនឹងធ្វើឲ្យព្រះអង្គសព្វព្រះទ័យ រាំដំណែងខ្លួនធ្វើជាអាទិទេពមួយយ៉ាងល្អ, ពួកស្ត្រីបំរើដែលនៅក្មេងហើយល្អ ៗ នោះទៀតក៏សុទ្ធតែព្រាយទាំងអស់ ៗ

ទោះជាយោបល់របស់លោកមុយអេស៊ុនត្រូវយ៉ាងណា ក៏ព្រះមហាក្សត្រនៅតែពុំទ្រង់សព្វព្រះទ័យឡើយ ហើយទ្រង់ក៏យាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយតាំងក្នុងព្រះទ័យថានឹងប្រគល់បេះដូងព្រះអង្គចំពោះតែព្រះនាងនោះមួយ ៗ ចាប់តាំងតែពីថ្ងៃនោះមក ព្រះអង្គបេះតែមានព្រះភក្ត្រស្រងូតស្រងាត់ ទុកជាព្រះអង្គពុំដែលបានដំណឹងអ្វីពីព្រះនាង ទុកជាលោកមុយអេស៊ុនបេះតែបន្ទូបន្ទាប់យ៉ាងណា ក៏ព្រះអង្គនៅតែមិនភ្លេចព្រះនាងសោះៗ ព្រះអង្គលែងទឹកក្រសាល លែងទឹកកំសាន្តអ្វីដទៃលើកតែការបរបាញ់ប៉ុណ្ណោះ ហើយទ្រង់នឹងស្តេចទៅបរបាញ់នោះទៀត ក៏ស្តេចទៅតែត្រង់កន្លែងដែលទ្រង់បានប្រទះនឹងឈ្លូសសនោះទៀត ៗ ទ្រង់បេះតែសញ្ជប់សញ្ជឹងដូចនេះពេញមួយឆ្នាំ ៗ

(មានត)

## សុភាសិតភាជនីតិ

ពាក្យកាព្យ

# អ្នកឧកញ៉ាមហាវិធិប៉ួយ នៅ

*រៀបរៀង*

( តមក )

---

ប្រការមួយទៀតគឺឲ្យស្គាល់     រៀងកល់ត្រកូលរតនាករ
មួយតែងធ្វើការស្អាតស្អោះសរ     មួយមិនធពស្រ្ដបំបាត់ហ្វូង ។
ហេតុប្រាំនេះពិតជាក្រិត្យក្រម     នាយធំក្នុងឃ្លាំងគ្រប់ក្រសួង
ត្រួតត្រាពជទ្រព្យផងទាំងពួង     ទីងហ្វូងហែងទុកមិនខ្វាត់ខ្វាយ ។
បោរាណកវីជាគន្ថំ     អក្ខុំ បាបនេះបែបរិយាយ
ប្រដៅប្រដាប់ប្រាប់កិប្រាយ     អធិប្បាយតាយបែងសំដែងថា ។
មហាក្សត្រទីងចាត់រើសបុរស     តាំងស្មោះជាប់ស្មើនៅត្រួតត្រា
ជានាយទ្វាររាំងទាំងរក្សា     ប្រកបប្រការប្រាំមួយពិត ។
មួយគឺឲ្យស្គាល់កាជបរិស័ទ     ចាស់ថ្មីបញ្ញាតិគ្រួរពិនិត្យ
មួយមានស្មារតីវៃគន់គិត     មួយរូបល្អល្អិតកាយសមរម្យ ។
ប្រការមួយឲ្យមានការងារស្អាត     មួយមានមារយាទបុករម្យទម
អត់ធន់លំបាកទុក្ខទោសធំ     មួយឈ្លាសនិយមសាកស្មួរល្អិត ។
ប្រាំមួយបទនេះជាបែបក្បួន     កងខ្លួនអមាត្យជាក្រមក្រិត្យ
ប្រកបប្រកាន់ជាប់ក្នុងចិត្ត     សុចរិតប្រ ពជានាយទ្វារ ។
បញ្ញារី ភក្ត្រី សុរី     ប៉ាបី បាបបទគម្ពីក

អធិប្បាយស្រាយថាព្រះរាជា
គួរកេយកមនុស្សដែលប្រកប
ប្រាំមួយប្រាកដបទបែបថា
មួយមានថ្វីមាត់ស្ទាត់បរបា
មួយមានគំនិតគិតល្អស្អាត
ប្រការមួយទៀតឲ្យប្រាកដ
ប្រាំមួយបទនេះតាមបាលី

## សកិទ្ធបរិក្ខំ

ជាក្រុមអាល័ក្សអ្នកថែងចាត់
គួររើសរកមនុស្សប្រកបបទ
មួយគឺចាំពាក្យដែលចរចា
ប្រការមួយសរសេរក៏រហ័ស
មួយមានថ្វីដៃល្អចំណាន
មួយឈ្លាសក្នុងលេខនឹងអក្សរ
ឯកទោទណ្ឌឃាដពដបក្សី
ប្រការប្រាំមួយនេះប្រាកដ
ជនបែបនេះឯងទើបសមសួន

## បញ្ញរិ បរមទ្ទេ

សេនាបតីសិរីសក្តិ

រើសនានៃអ្នកនាំពលសារ ។
ស្រួលស្របស្រេចសព្វគ្រប់ប្រការ
មួយគឺប្រាជ្ញាឈ្លៀវឆ្លុះឆ្លាត ។
មួយគឺក្លៀវក្លាអាចសាមាថ
មួយឆ្លាតនឹងពាក្យគួរទឹងស្តី ។
កំណត់ដឹងចិត្តជនប្រុសស្រី
សេចក្តីគួរជាពលទូតក្សត្រ ។
ស្តេចទ្រង់នឹងតាំងពលបរិស័ទ
បញ្ញត្តប្រញ័ត្តបញ្ជាប់ពលការ ។
កំណត់ប្រាំមួយដូចថ្លែងថា
តែម្តងអាចក្លាគ្រាប់ចាំបាន ។
មួយធ្លាតឆ្លៀវឆ្លាសប្រាជ្ញរហាន
មួយមានស្នានឈ្លាសសំដី ។
ហានន្តរញ្ញញ្ញនៈបាប់បាលី
ប្រកបសេចក្តីត្រូវបែបក្បួន ។
សន្តុតបុរេសមានក្នុងខ្លួន
សំនួនក្នុងទីជាអាល័ក្ស ។
ខត្តិយោ ទ្រង់តាំងអគ្គឯកអគ្គ
ជាឡាក់លើសលែងមុខមន្ត្រី ។

គួររិះត្រិះរើសរកដសេរីកា
ប្រាំបួនប្រការប្រាកដខ្ចី
មួយមានប្រាជ្ញាអាចបំបាក់
មួយដឹងជយភូមិទិឝកាស
មួយគឺនាកាលដល់អាប់បុន
មួយគឺដឹងកលពលអាសា
មួយគឺប្រកបដោយសេចក្តី
មួយគឺក្លៀវក្លាហានតតាំង
មួយគឺអម្ចាស់លើសិរសា
អត់ធន់ទ្រាំទ្រជួយការភ័យ
មួយគឺអត់ធន់នឹងពួកខ្លួន
សន្តោសប្រោសប្រាប់ដោយទំនង
មួយចេះគម្ពីរសេនង្គ:
ប្រាកដកំណត់ជាសេនីយ
ប្រាំបួនបទនេះប្រាកដថា
តម្រិះត្រិះត្រែកតម្រែកគិត

បិតុបិតាមហាទក្កោ

ប្រយោជន៍ក្សត្រាក្នុងរាជ្យរម្យ
ព្រះចមបក្រពង្សទ្រង់តាំងតែង
គួរជ្រើសរើសរកពងបរំពារ

កិរិយាប្រកបធបសេចក្តី
ទើបជាអធិបតីដោះទុក្ខស្ត្រី ៗ
បរប័ក្សញើញក់ឲ្យវិនាស
និពសប្រាសចាកក្តីទុក្ខា ៗ
ស៊ូធន់នឹងគ្នាស៊ីជីវ៉
រអាលំបាកតោកយ៉ាកខ្លាំង ៗ
ព្យាយាមគប្បីជាកម្លាំង
ប្រណាំងប្រយុទ្ធយកជោគជ័យ ៗ
មានការកេរិយុត្តទុក្ខមោះមែ
ដោយន័យកតញ្ញូស៊ូក៏ប់រង ៗ
មិនគួនសុខទុក្ខក្តីធ្មាំធ្ងង
គន្ធងដំណើរប្រើសំដី ៗ
ព្យុហៈសង្គ្រាមសព្វសេចក្តី
ដោយន័យពិជ័យសង្គ្រាមពិត ៗ
ប្រកបកិរិយាការប្រព្រឹត្តិ
បរិតសេនាបតីធំ ៗ
ប្រាបៅ ធាប់បទនេះនិយម
សុខុមលៃបខាយធិប្បាយថា ៗ
តំណែងពិសេសភោជនាហារ
ប្រកបប្រការប្រាំប្រាកដ ៗ

មួយផ្ទាប់ជាប់តពីបិតា | ធ្វើការពិសេសល្អម៉ត់ចត់
មួយឈ្លាសឆ្លៀវឆ្លាតបានបាឋបទ | កំណត់គន្ថការស្ងួដណ្ដាំ ។
មួយប្រាជ្ញអាចចេះក្បួនគម្រា | សំឡូពីសាពិសេសចាំ
មួយចេះដាំស្លតាមចំណាំ | សៃមសាំថែមថយល្មមប្រមាណ ។

មួយនៅជាប់ជាពួកពិសេស | ដកបមិនធ្វេសប្រហែសខាន
ប្រាំបទកំណត់ពីបុរាណ | ស្ពានគន្ថទិពិសេសហួង ។
អាយុភេទសត្ថេទក្លោ | វេញ្ញា ទន់តាំងក្រមក្រសួង
ពេទ្យខុសជាផងទាំងពួង | គួរហួងយកមនុស្សមានវិជ្ជា ។
ប្រកបគុណប្រាំចាំប្រាកដ | ទីមួយគឺស្ទាត់បទពេទ្យា
គម្ពីរខុសចតុមហិមា | វិជ្ជានាអាយុឲ្យវែងឆ្ងាយ ។
ហើយឲ្យអាចស្គាល់ខ្យល់ដីពចរ | ឆាយក្រដូចម្ដេចកេតគន្ថកាយ
កំណត់ស្ទាត់ចាំខ្យល់ស៊ុះសាយ | តាមដោយតម្រាយតម្រាផង ។
មួយគឺឆ្លៀវឆ្លាសខាងរក្សា | រោគាព្យាធិឲ្យម៉ត់ម៉ង
មួយគឺអាចចាំថ្នាំគ្រប់គង | ចេះចងសារពើខុសថា ។
មួយមានស្ពានកល្យាណទន់ | ល្អអង្គត្រង់ត្រឹមត្រូវលក្ខណា
មួយគឺប្រកបសីលាចារ | សេដ្ឋាប្រសើរដ៏ឧត្ដម ។
បាឋបទកំណត់ប្រាំវិជ្ជា | ពណ៌នាមកនេះជាក្រិត្យក្រម
បុរសណាប្រាជ្ញអាចចេះចំ | គន្ថទីពេទ្យធំចមពជគ្រ ។
សុជាតត្ថិ សុបិទក្កិ | វិបដិ សត្វនេះលោកផ្ទឹមផ្ទួប

តម្រង់ត្រឹមត្រូវក្បួនគំរូ　　បុរាណរាជបូរពោលទុកមក ។
ជាព្រះបរមរាជខត្តិយា　　តែកទ្រង់ចិន្តាតែលៃលក
នឹងជ្រើសរើសបុរសស្មោះត្រូវយក　　រិះរកមកតាំងជាសេវកា ។
ត្រូវឲ្យប្រកបហេតុប្រាំពីរ　　មួយគឺមានសីលសមាចារ
រក្សាសុចរិតចិត្តមេត្តា　　ប្រព្រឹត្តចរិយាធម៌ប្រពៃ ។
មួយឈ្លាសក្លាសជំនឹងដោយរហ័ស　　អធ្យាស្រ័យម្ចាស់សព្វព្រះទ័យ
មួយមានប្រាជ្ញាឆ្លៀវឆ្លាសវៃ　　ជឿនទ័យទំនងតាមដំណើរ ។
មួយអាចប្រាជ្ញដឹងគម្ពីរច្រើន　　ចំរើនតម្រិះដ៏ប្រសើរ
មួយជាមនុស្សស្អាតធ្លាតបំរើ　　មិនមានសើរើធ្វើឲ្យហួង ។
មួយគឺមានចិត្តមិនលោភា　　មុះមោះធ្វើតាមបំណង
មួយមានស្មារតីវៃកន្ទង　　ចាំបង់ចាប់ជាប់គ្រប់សេចក្តី ។
ប្រាំពីរបទនេះជាចារិក　　មហាតលិកបំរើគាល់ប្រក្រតី
ដំណិតជិតអង្គព្រះចក្រី　　មេត្រីតាំងទុកជាសេវកា ។

## ភេទាភេទង្គសត្តញ្ញោ

　　សារសព្វសេដ្ឋដោយវិត្ថារ
បានបទកំណត់តាមតម្រា　　តម្រាយក្រោយពីបុរាណ ។
សម្តែងវែងចាត់ទុកជាច្បាប់　　សំរាប់តំណរាជក្រឹត្យក្រាន្ត
នឹងតាំងបុរោហិតគិតប្រមាណ　　ប្រកបហេតុបានទាំងបំពិត ។
មួយចេះគម្ពីរត្រៃវេទ　　សត្វសេដ្ឋធំតូចតែងប្រព្រឹត្ត
មួយឈ្លាសធ្លាតជំនិតតម្រាយគត់　　ប្រឌិតប្រដាប់បូជាយ័ន្ត ។
ប្រការមួយប្រកបព្រហ្មវិហារ　　តាំងចិត្តមេត្តាជានិរន្តរ៍

ចំរើនព្រះជន្មឲ្យគប់គ្រាន់ បានដល់រយពាន់អង្វែងទៅ ។
បីបទកំណត់នេះជាទី វិធីព្រាហ្មណ៍ត្រូវប្រកបទៅ
ប្រកាន់ប្រាកដបទភក់ផ្សៅ ទើបហៅថាទឹកដបុរោហិត ។

វគ្គតិត្រ្យិយសាធុកំ

បាថបទភពចំតាំងភាសិត
សម្ដែងវែងច្បាប់ជាក្រមក្រិត្យ លិខិតន័យនេះពណ៌នាថា ។
សម្ដេចចមពង្សទ្រង់តាំងតែង តំណែងក្រុមកាំងខាំងរក្សា
ស្រីគ្គារព្រះស្នំក្រុមបរិវារ គួររើសបុរិសាដែលប្រព្រឹត្ត ។
ដោយអង្គប្រាំពីរជាសុភាព មួយចិត្តទន់ទាបត្រង់ស្លូតពិត
មួយរក្សាខ្លួនស្ងួនគំនិត គន់គិតរាំងខ្លាចទោសភ័យ ។
មួយឆ្លាតឈ្លាសចេះពាក្យបរហា ភាសាប្រទេសផងដទៃ
មួយគឺកើតអរធម៌ប្រពៃ ប្រព្រឹត្តដោយន័យពុទ្ធចាក់ទ ។
មួយគឺប្រកបត្រកូលវង្ស ចេតនាទ្រទ្រង់សីលដ៏ស្អាត
មួយគឺអាចចេះសិល្បសាស្ត្រ ផ្សេងៗ ជាខ្នាតមានកន្ធខ្លួន ។
មួយគឺមានចិត្តគិតក្រែងខ្លាច អំណាចអម្ចាស់ណាស់ម៉ាំមួន
ប្រាំពីរបទនេះទើបសមសួន ខ្ជាប់ខ្ជួនក្នុងទីក្រុមកាំងស្ដេច ។

បញ្ញាអក្សរត្រោប

អក្ខរៈបទនេះលោកសម្រេច
សម្រាប់បុរសស្រស់ស្រីបស្រេច តាមដោយបំណាច់បទសរិយា ។
ដែលគួរតែងតាំងជាមន្ត្រី ប្រកបសេចក្ដីបួនប្រការ
មួយគឺជាមនុស្សមានប្រាជ្ញា ត្រិះរិះដឹងអាថ៌ការណ៍ទាំងឡាយ ។

មួយគឺកាលម្ចាស់មានវល់
មិនមានធុញថប់ចប្រប់កាយ
មួយគឺប្រកបចិត្តក្លៀវក្លា
បំបាត់សត្រូវឲ្យបង់បាត់
មួយមានគតិជាអ្នកគិត
ដឹងយល់យោបល់កលបញ្ហា
បួនបទកំណត់ដូចពណ៌នា
ដល់ខ្ញុំមួលីកាមហាក្សត្រក្សាន្ត

## សាអឹមបួញរដ្ឋញ

សំដែងពីអង្គម្ចាស់ផែនដី
ប្រការមួយគឺជាតិជាម្ចាស់
មួយមានអមាត្យក្លៀវក្លាសជួយ
ប្រការមួយសោតប្រកបមាន
ខ្លះទាំងក្លៀវក្លាកប់យសែន
ប្រការមួយប្រកបគូកំពែង
ប្រយ័ត្នសំរាប់អចិន្ត្រៃយ៍
មួយគឺព្រះឃ្លាំងពីរដណ្តប់
មួយគឺព្រះរាជសម្ពន្ធមិត្រ
ប្រាំមួយបទនេះជានិយម
ប្រព្រឹត្តសុចរិតពិតដោយន័យ

យកខ្លួនទប់ទល់ធ្វើការថ្វាយ
មិនណាយលះបង់រាជការក្សត្រ ៗ
ប្រកាន់កលការកិច្ចកំបាត់
ដោយរាជបញ្ញត្តិព្រះអាជ្ញា ៗ
ប្រព្រឹត្តត្រិះរិះតាមត្រូវការ
ដោយមានឧស្សាហ៍គន់គិតអាន ៗ
សាធារណ៍ទូទៅពលរូបប្រាណ
ស្ថាននេះជាទីមន្ត្រី ៗ
ករ. ប្រាប់បទបែបសេចក្តី
គប្បីប្រកបអង្គប្រាំមួយ ៗ
ត្រូវឈ្លាសដឹងរាស្ត្រសុខទុក្ខព្រួយ
ជំនួយឲ្យឈរកង់ខេត្តដែន ៗ
ទាហានយោធាស្ទាត់វៃខ្លួន
ណាន់ណែនរក្សារាជក្រុងក្រែ ៗ
បន្ទាយបំរែងតាំងសព្វថ្ងៃ
អាស្រ័យទាំងខាងបច្ចាមិត្រ ៗ
មានសព្វសម្បត្តិសម្បូរពិត
ស្គាល់ជិតស្និទ្ធគ្នាកាលមានភ័យ ៗ
បរមចក្រពត្តិដ៏ប្រពៃ
ជាមហៃឥស្សរៈរាជរដ្ឋ ៗ

អត្តានមេរាជិតាមិ
និងសេពសមាគមគ្រូអាចារ្យ
ហើយទ្រង់ប្រកបគុណវិជ្ជា
ស្ទាញស្ទាត់ប្រាកដដោយតេជវិទ្ធ
ឲ្យស្អាតប្រាកដនឹងព្រះអគ្គ
នៅព្រះទីនាំងរថញ្ញក់
ហើយទើបដំរិះពិចារណា
មានពួកអមាត្យជាដើមផង

បញ្ញាភិពុទ្ធិមាបេរិ
សំរាំងតាំងទុកសំរាប់ស្តេច
នេះគួរគប្បីឲ្យប្រកប
ឈ្វេងយល់អត្ថាស្រ័យជនទានា
គប្បីរៀបចំពាក្យទោគោះ
ទ្រង់តាំងអំណត់ក្នុងព្រះទ័យ
មានព្រះចរិតទ្រង់ប្រពឹត្ត
ព្រះមនោសោមនស្សបរិសុទ្ធថ្លា

សុដ្ឋិកាលសម្មន្តាទិ
សំដែងថែងស័ព្ទប្រាប់អភិប្រាយ
ដ៏ជាឥស្សរៈកំពូលក្សត្រ

ជាស្ដេចគួរតាំងទីប្រាជ្ញា
ដ៏មានប្រាជ្ញាជាបណ្ឌិត ។
ចំណានដំនាចំណេះពិត
ដំនិតចំណាប់សិល្បសាស្ត្រ ។
មានដើមថាគង់រាជអស្សា
គ្រឿងក្ដាសកក្ដឹកដល់ប៉ុនល្អង ។
មើលខ្ញុំរាជការប្រាំមួយកង
បំណងចិញ្ចឹមដោយបំណាច់ ។
អក្ខរៈបាទនេះលោកសំរេច
ប្រសើរលើសជាចំផែនកតការ ។
ដោយរបបប្រាជ្ញាថ្លាសវិជ្ជា
មិនរួញរាហើសឈ្លាសកងវៃ ។
អស្សុគេះគំគេះពុំប្រែពៃ
ដោយន័យខន្តីនឹងសត្យា ។
ទសពិធរាជធម៌សមាចារ
មិនប្ញស្សាសម្បត្តិអ្នកតាំងឡាយ ។
គតិន័យនេះលោកបរិយាយ
អធិប្បាយដើម្បីព្រះក្សត្រា ។
ទុកាសឥស្សរាជរដ្ឋា

នឹងទ្រង់ព្រះវត្តសារពើការ   គួរទ្រង់ព្រះចិន្តាដោយយោបល់ ។
ពិចារណាដោយល្អិតរួចសឹមធ្វើ   សារពើទាំងពួងទើបមានផល
សម្រេចស្រេចកើតការកិច្ចកល   នឹងមិនរង្វើងធ្លល់ដោយយល់ស្រាប់ ។
ហើយឲ្យប្រព្រឹត្តប្រកបបទ   កំណត់ប្រាំមួយជាតំរប់
តំរាយបុរាណចងជាច្បាប់   សំរាប់ខត្តិយវង្សទ្រង់ប្រព្រឹត្ត ។
ប្រការមួយគឺឲ្យប្រកបមាន   ជាស្ពានមេត្រីសម្ពន្ធមិត្ត
ដើម្បីស្រេចក្ដីរួមគំនិត   រិះគិតកំចាត់សត្រូវផង ។
ហើយឲ្យរាងវៃការរណរង្គ   ឈ្លាសក្នុងឧបាយដ៏កន្ទង
កិច្ចកលសត្រូវឲ្យសៅហ្មង   កាច់កងបំបាក់ឲ្យខ្ចុបខ្ចាច ។
ជាទីសរណប្រជាករ   នឹងបានស្មោះសរដោយអំណាច
អំណរអររឹទ្ធីដែលអង់អាច   ប្រះប្រាជ្ញប្រាប់ទុក្ខមានសុខសន្ត ។
ប្រការមួយព្រះទ័យទ្រង់រំពេក   មមៃញឹកការងារជាប្រមាណ
មិនមានប្រមាទឲ្យខាតខាន   ដរាបដល់បានសំរេចការ ។
ប្រការមួយចេះញាំងបរបក្ស   បំបាក់បំបបឲ្យរអា
ដោយយុត្តិធម៌សម្មាចារ   ជាទ័នថ្វាបំផ្លាញឲ្យរាងចាល ។
ប្រការមួយប្រកបដោយព្រះទ័យ   ក្លៀវក្លាប្រពៃមិនស្រាកស្រាល
ត្រង់ក្ដីព្យាយាមជានិច្ចកាល   ត្រអាលត្រេកទ្រង់គង់មាំមួន ។
ប្រការមួយគឺមានព្រះស្មារតី   មិនវង្វេងវង្វេសទ្រង់ខ្ជាប់ខ្ជួន
គួបកត់កំណត់ចាំថែជួន   ក្រខ្ទួនគួនគិតក្រណាន់នៅ ។
ប្រការមួយគឺមានព្រះប្រាជ្ញា   ជ្រាបការវិនាសនិពាសទៅ

ជ្រាបក្ដីចំរើនក្ដីពក់ជ្រៅ កោតៅផុលផុសផ្ទុះសព្វសាយ ។

ឧបការញ្ញោសុរោ វិសុទ្ធសេដ្ឋសព្វអធិប្បាយ

ថាព្រះបមពង្ស្រទង់ខ្វល់ខ្វាយ ដល់គុណតាំងឡាយដែលគេមាន ។

ហើយឲ្យក្មៀវក្លាសមាគម អ្នកធំតាំងបីជាប្រធាន

មួយគឺបណ្ឌិតប្រាជ្ញវៃញ្ញាណ ជាអ្នកវិជ្យានឈ្លាសឆ្លៀវក្រៃ ។

មួយគឺជនជាតិចាស់ព្រឹទ្ធា វិញ្ញូនាចំរើនអាយុក្ខ័យ

មួយគឺអ្នកមានត្រកូលថ្លៃ ខ្ពង់ខ្ពស់ជាមហៃលើសមហាជន ។

ហើយទ្រង់ប្រកបព្រមដោយអង្គ តាំងបីត្រឹមត្រង់ត្រូវពេកពន់

មួយមិនបានធ្វើអំពើធ្ងន់ លើសលន់ឲ្យដល់វិនាសខ្លួន ។

មានដើរដល់មាន់ទីងការគ្នាល់ គ្រប់កល់ល្បែងផងពុំទ្រង់គួន ។

ជាហេតុទុច្ចរិតមិនសមសួន កុំគ្រនួនគួនគិតជាប្រក្រតី ។

ប្រការមួយគឺមិនគ្នះតិះដៀល រាំចាដំទៀលមិនគប្បី

គឺពោលផ្ទុសរាំទពាក្យអប្រិយ ជាក្ដីអ័ប្បយសចំពោះគ្នា ។

ប្រការមួយគឺទ្រង់ព្រះបេ្តជ្ញា ប្រារព្ធថាដូចម្ដេចជាប្រធាន

ខ្ជាប់ខ្ជួនដូរប្រោះចំពោះមាន មិនបំពានធ្វើខុសពីបេ្តជ្ញា ។

អរិត្យសងការញ្ញោ រាំទៅ បទនេះពណ៌នាថា

ក្សត្រដ៏ទ្រង់អង្គឥស្សរា គប្បីជ្រាបការណ៍ហេតុកំចាត់ ។

បរពក្សគឺពួកសត្រូវផង គ្រប់កងដែលកើតនោះឲ្យខ្ចាត់

ដំនះក្ដីក្រោធឲ្យបង់បាត់ ទ្រង់កាត់ដាច់ចេញចាកសន្ដាន ។

គឺឲ្យដំនះនូវឥន្ទ្រិយ មាននេត្រតាំងឡាយជាដើមជាន

ហើយមិនលោកលន់ពន់ប្រមាណ ត្រេកអរតាមបានមិនឈ្មានពាន ។
ព្រះទ័យប្រកបដោយឧស្សាហ៍ ជះថ្វាបរិច្ចាគទេយ្យទាន
ឧស្សាហ៍ប្រដៅច្បាប់ទូន្មាន ប្រិតប្រៀនដល់ខ្ញុំព្រះរាជការ ។
ណាមួយមិនថ្លាតមិនឈ្លាសដឹង ដំណឹងដំណើរដោយប្រាជ្ញា
ទ្រង់ព្រះបញ្ញត្តច្បាប់មាត្រា ប្រយោជន៍កិច្ចការឲ្យឈ្លាសឡើង ។

**វិមោហោអបរិគ្គហោ** ជារាជខត្តិយោផ្ដល់ចំរើន
លោកឲ្យរាំងកុំបើង តំកើងហើយក្លួចព្រះស្មារតី ។
ន័យមួយលោកប្រៀបធៀបឧបមា អគ្គអគ្គក្សត្រាគួរកុំបី
កាច់បង់ចង្ក្រមធ្នុំបុរី កុំញីញក់ទង់ជ័យរាជរដ្ឋ ។
កុំក្រៀលវៀលក្អែកព្រះនគរ កុំវះឧទររាជសីមា
កុំកាច់បំបាក់បាទហត្ថា កុំទំណាក់មុខរាជក្រុងត្រៃ ។
ហើយមានកិរិយាល្អវិសុទ្ធ វិសេសបំផុតដោយនិស្ស័យ
ដំទ្រង់ឥស្សរភាពជាមហា អធ្យាស្រ័យរាប់គេជនសប្បុរស ។
ប្រព្រឹត្តព្រមដោយរាជវត្ត ប្រាំពីរទៀងទាត់ស្អាតឥតខ្ចោះ
ជាហេតុចំរើននគរស្មោះ មិនមានចន្លោះកង្វះបច្ចុប្បន្ន ។
ជាបន្ទូរប្រទេសអាក្រក់ល្អ ការក្រកកើតក្ដីអាសន្ន
ស៊ុខទុក្ខកលិយុគជានិរន្តរ៍ អប្បអន់ទន់ទាបប្រការម្ដេច ។
ជាបកាលដ៏គួរទឹងមិនគួរ មិនមួជជាតិឃ្លាតកលកិច្ច
មិនហួសហែងទ្រព្យជាប់ខ្ជាបតិប ក្រឡូចកិច្ចកាត់ចាត់តាមការណ៍ ។

(មានត)

# ពេជ្រព្រះភជា

លោក ស៊ិន-ហ៊ិន ប្រែរៀបរៀង

លោក យ៉ូវ-អ៊ិន ពិនិត្យកែសម្រួល

(តមក)

---

មាណពបានសង្កេតឃើញនូវសេចក្ដីពេញចិត្តនៃអមាត្យ ដោយសារស្ដាប់វាទៈនៃខ្លួនត្រឹមលើកដំបូង ក៏ត្រេកអរយ៉ាងខ្លាំង តែមានបំណងនឹងឲ្យអមាត្យ បានចូលចិត្តនូវសេចក្ដីពិតចំពោះពាក្យប្រដៅដែលជាគោលធំមុន ទើបប្រាប់ថា:

" ការបៀតបៀនដោយសេចក្ដីក្រោធ ដោយសេចក្ដីលោភនឹងដោយសេចក្ដីវង្វេង ជាហេតុធ្វើឲ្យមនុស្សរកសេចក្ដីសុខគ្មានឡើយ សំឡាញ់!..." ៗ

"ការបៀតបៀនមិនមានផ្លូវណាដែលនឹងហាមឃាត់បានទេ មាណពសំឡាញ់, ព្រោះកាលកើតលោកឡើងហើយ អ្នកណាឈ្លាសជាងគេ ក៏រមែងបានប្រៀបជាងគេ, អ្នកណាល្ងង់ខ្លៅជាងគេក៏ត្រូវធ្លាក់ខ្លួនទៅជានុយគេ ស្រេចហើយតែគេសង្កត់សង្កិនជិះជាន់បានតាមចិត្ត, លោកយើងនេះក៏យ៉ាងនោះដែរ នរណានឹងអាចហាមលោកបាន, អ្នកធ្វើការបៀតបៀនមានលក្ខណៈជាចោរ ព្រះរាជាទើបបានទ្រង់បញ្ញត្តច្បាប់ដាក់ទោស តែការប្រព្រឹត្តអាក្រក់របស់មនុស្សអាក្រក់ក៏នៅតែមានជានិច្ច"

នេះជាពាក្យអមាត្យបាលិតពោលជំទាស់ឡើង ក្នុងខណៈមាណពកំពុងនិយាយមិនទាន់ចប់ ទើបមាណពតបវិញ :

"សំឡាញ់ជក! ឈ្មោះថាការហាមអ្នកដទៃ បង្ខំអ្នកដទៃឲ្យធ្វើតាមពាក្យប្រដៅរបស់ព្រះពុទ្ធអង្គមិនមានឡើយ, ព្រះពុទ្ធអង្គសូម្បីក្នុងកាលដែលកំពុងផ្សាយសាសនា ក៏ព្រះអង្គទ្រង់ប្រោសប្រដៅចំពោះតែអ្នកដែលចូលចិត្តនឹងពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ព្រមទទួលធ្វើតាមព្រះអង្គ នរណាមិនជឿមិនជ្រះថ្លា ក៏ព្រះអង្គមិនទ្រង់ហាមឡើយ ៗ ព្រះអង្គតែងទ្រង់ប្រដៅថាធ្វើអំពើបែបនេះអាក្រក់ គួរលះចេញ អំពើបែបនេះល្អ គួរកាន់យកធ្វើឲ្យមានឡើង អ្នកឈ្លាសវៃប្រើប្រាជ្ញាពិចារណាតាមឱវាទព្រះអង្គហើយ ក៏អាចយល់ហើយប្រតិបត្តិតាមបាន, វិសេសជាងនោះទៅទៀត កាលបើសាសនារបស់ព្រះអង្គត្រូវគេបៀតបៀន ព្រះអង្គមិនម្រង់ហាមអ្នកបៀតបៀនឡើយ ព្រះអង្គទ្រង់ហាមចំពោះតែអ្នកកប់កានសាសនារបស់ព្រះអង្គទៅវិញ ដូចមានរឿងដែលកើតឡើងដល់ព្រះអង្គ កាលទ្រង់ស្ដេចប្រោសសត្វលោកបានលើកតំកើងនូវសាវ័ក ១ រូបរបស់ព្រះអង្គ ខណៈដែលចេញទៅបំពេញករណីយកិច្ចនៅជនបទដទៃ ១ ដែលសម្បូរទៅដោយមនុស្សអ្នកប្រទូសរ៉ាយ, ព្រះអង្គបានត្រាស់សួរសាវ័ករបស់ព្រះអង្គនោះថា:

"បានឮថាទីដែលលោកទៅនៅនោះមានមនុស្សពាលច្រើន ដែលប្រព្រឹត្តឲ្យជាទីក្ដៅក្រហាយផ្សេង ៗ មិនប្រាកដថានឹងបានធ្វើយ៉ាងណា ៗ ទេ តែបើប្រសិនជាលោកត្រូវគេស្ដីថា តើនឹងធ្វើយ៉ាងដូចម្ដេច?

សាវ័កតបថា ៖

"កាលបើគេស្ដីឲ្យ ក៏គង់ល្អជាងគេដេរ, ខ្ញុំព្រះអង្គក៏ល្មមនឹងអត់ទ្រាំនៅបាន";

ព្រះសម្មាសម្ពុទ្ធម្ចាស់ត្រាស់សួរតទៅទៀត :

"កាលបើគេដេរលោក តើលោកនឹងធ្វើយ៉ាងដូចម្ដេច?";

"បពិត្រព្រះអង្គដ៏ចំរើន! កាលបើគេដេរខ្ញុំព្រះអង្គ ក៏គង់ល្អជាងគេប្រហារខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គនឹងអត់ទ្រាំនៅក្នុងទីនោះបាន";

"ម្នាលភិក្ខុ! បើប្រសិនជាគេធ្វើវិសេសជាងនោះទៅទៀត គឺគេមិនស្ដីឲ្យ, មិនដេរ, មិនប្រហារលោកទេ តែគេសម្លាប់លោក?";

"បពិត្រព្រះអង្គដ៏ចំរើន! កាលបើគេសម្លាប់ខ្ញុំព្រះអង្គហើយ ក៏គង់ល្អជាងអ្នកដែលប្រាថ្នាចង់ស្លាប់តែមិនមានអ្នកណាសម្លាប់?";

ឧទាហរណ៍មានន័យដូចបានលើកមកនេះឯង សំឡាញ់! ព្រះពុទ្ធអង្គមិនទ្រង់ហាមអ្នកដទៃ តែព្រះអង្គទ្រង់លើកតំកើងនូវការហាមខ្លួនឯង កាលបើសាវ័កទូលតបដូច្នេះហើយ ព្រះអង្គទ្រង់សរសើរសាវ័កនេះថាជាឯតទគ្គៈខាងផ្លូវមានខន្តិគុណ ព្រោះអត់ធន់ចំពោះការបៀតបៀន ការដេរស្ដី ការធ្វើប្រទូសរ៉ាយ" ។

អមាត្យបាលិតនៅស្ងៀម ក្នុងពេលដែលស្ដាប់ពាក្យរបស់មាណពចប់ហើយ ព្រោះការភ្លឺស្វាងក្នុងចិត្តកើតឡើង ជាហេតុនាំឲ្យមានសេចក្ដីដឹងខ្លួន ក៏បន្លឺឧទានវាចាថា:

"មាណពសំឡាញ់! ព្រះពុទ្ធអង្គគឺនរណា? គង់នៅទីណា?

ផ្ទុយមកវិញ ខ្ញុំនឹងបានស្ដាប់ពាក្យប្រដៅរបស់ព្រះពុទ្ធអង្គដ៏ជ្រាលជ្រៅក្រៃលែងជាងនេះទៅទៀត ដែលអាចនឹងកើតប្រយោជន៍ដល់ខ្ញុំយ៉ាងច្រើន ; សូមសំឡាញ់មេត្តាប្រាប់ទីរបស់ព្រះអង្គនឹងទិសដែលត្រូវទៅគាល់ព្រះអង្គដល់ខ្ញុំផង, ខ្ញុំគិតថាថ្ងៃណាមួយខាងមុខ ខ្ញុំគង់តែជួបនឹងព្រះពុទ្ធអង្គពុំខានឡើយ" ។

មាណពត្រឹក្បាល មុនដែលពោលពាក្យចេញមក ដោយមានសេចក្ដីរំភើបភ្ញាក់ផ្អើលក្នុងខ្លួនយ៉ាងក្រៃលែង ក្នុងកាលបានជួបពាក្យដូចជាក្មេងមិនទាន់ដឹងក្ដីមកអង្វរសួរនូវតែដែលមិនមានក្នុងលោកនេះ សូម្បីតែខ្លួនរបស់គាត់ក៏មិនបានដឹងនូវពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធម្ចាស់ដោយពិតប្រាកដផង ទាំងមិនធ្លាប់ឃើញនូវតួអង្គរបស់ព្រះសម្មាសម្ពុទ្ធម្ចាស់ឡើយ, សេចក្ដីគក់ស្លុតបានកើតឡើងក្នុងចិត្ត ទើបគេចមុខចេញទៅអំពីអមាត្យ ហើយពោលថា :

"ព្រះពុទ្ធអង្គដែលលោកប្រាថ្នាចង់ជួបនោះ សូម្បីនរណា ៗ ក៏មិនអាចជួបនឹងព្រះអង្គបានទេ ព្រោះសេចក្ដីពិតដ៏ទៀងទាត់ដែលព្រះអង្គទ្រង់បានទទួលរាប់រងមកក៏កើតប្រាកដដល់ព្រះអង្គហើយ គឺព្រះអង្គបានស្ដេចរំលត់ខន្ធបរិនិព្វានហើយ ក្នុងកាល ១២០០ ឆ្នាំដែលកន្លងមកនេះ" និយាយមកដល់ត្រឹមនេះ មាណពក៏លែងនិយាយតទៅទៀត ហើយក៏គេចមុខចេញ ។

អមាត្យបាលិត ឃើញមាណពគេចមុខទៅខាងម្ខាង ក៏ដេញសួរថែមទៀតថា :

"បើដូច្នោះ ខ្ញុំអស់មានឱកាសនឹងជួបស្ដាប់ពាក្យប្រៀនប្រដៅផ្ទាល់អំពីព្រះពុទ្ធអង្គហើយឬ?" ។

កាលអមាត្យសួរយ៉ាងនេះ មាណពក៏ដកដង្ហើមធំ តបថា:

"ឱកាសនៅមាន សំឡាញ់, តែលោកអាចនឹងជួបបានចំពោះតែពាក្យប្រៀនប្រដៅរបស់ព្រះអង្គប៉ុណ្ណោះ, ចំណែកព្រះពុទ្ធអង្គគឺលោកមិនអាចនឹងជួបឡើយ" រួចមាណពពោលតទៅទៀតថា:

"សេចក្ដីសាបសូន្យវត្ថុគ្រប់យ៉ាងក្នុងលោកនេះ ជារបស់ធម្មតា, ព្រះធម៌របស់ព្រះពុទ្ធអង្គនៅមាន ទោះបីមិនសាបសូន្យទៅតាមក៏ដោយ តែក្នុងសភាពធម្មតា តែងប្រដុំចុះក្នុងសេចក្ដីសាបសូន្យដូចគ្នា, បើមិនមានសាវ័ករបស់ព្រះសាស្ដាដករបណា ដករនោះពាក្យប្រដៅរបស់ព្រះអង្គក៏ឈ្មោះថាសាបសូន្យអស់ទៅដែរ. . ." ។

អមាត្យបាលិតសំដែងទឹកមុខស្រស់ថ្លា ធ្វើអាការហាក់ដូចជាមានបំណងអ្វីមួយ និយាយតបថា:

"ខ្ញុំជឿជាក់ថាធម៌របស់ព្រះអង្គនៅមានពិតប្រាកដ, ព្រោះក្នុងនគរពារាណសី នៅមានព្រះសង្ឃ ១ ពួកគង់ក្នុងអារាមជាមួយគ្នា តែគ្រាប់ចារិកអំពីអារាមក្នុង ១ ឆ្នាំ ៗ យូរ ៗ ទើបត្រឡប់ចូលទៅនៅក្នុងអារាមម្ដង ខ្ញុំជឿថាព្រះសង្ឃទាំងនោះហើយជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធម្ចាស់មែន ព្រោះត្រូវនឹងពាក្យដែលលោកពោលអំពីដំបូងថា មិនបង្គាប់នរណាឲ្យរាប់អានឬជ្រះថ្លាឡើយ" ។

"ត្រូវហើយ សំឡាញ់ជក! លោកជាអ្នកក្រុងពារាណសីឬ?

ហេតុដូចម្តេច លោកមិនស្គាល់សាវ័ករបស់ព្រះពុទ្ធជាម្ចាស់? ព្រោះនគរពារាណសីជានគរមួយធ្លាប់ជាទីតាំងរបស់សាវ័កព្រះគោតមមក តាំងអំពីកាលព្រះពុទ្ធអង្គនៅមិនទាន់ស្តេចរំលត់ខន្ធចូលកាន់បរិនិព្វានម្ល៉េះ" មាណពតប ។

អមាត្យបាលិតក៏ទឹកភ្នែកញញើមណ្ណៈនេះភ្លាម ទាំងទឹកតិះដៀលខ្លួនឯងដែលចេះតែមើលរំលងនូវសាវ័ករបស់ព្រះសម្មាសម្ពុទ្ធម្ចាស់ សូម្បីធ្លាប់បានជួបស្ទើរតែគ្រប់ពេលវេលា, ក្នុងពេលបានជួបម្តងៗ គួរណាស់តែនិយាយសាកសួរពាក់ទាក់ខ្លះ, ទើបប្រាប់មាណពថា:

"ព្រោះសេចក្តីល្ងង់ខ្លៅរបស់ខ្ញុំ ដែលខ្វះខាតការយកចិត្តទុកដាក់ហើយប្រកាន់ក្នុងលទ្ធិរបស់ខ្ញុំថាមានខ្លឹមសារផង បានជាមិនបានគិតថានៅមានសាស្តាប្រសើរក្រៅពីសាសនាព្រាហ្មណ៍" ។

មាណពស្តាប់ពាក្យអមាត្យបាលិតដោយសេចក្តីពេញចិត្ត តាំងអំពីបានសន្ទនាគ្នាមក, អមាត្យបាលិតជាអ្នកចេះនូវលំទោនមានភាពជាធំសមគួរដល់វ័យ លុះកាលបានស្តាប់រឿងរ៉ាវរបស់ព្រះពុទ្ធអង្គត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ក៏បានដឹងដោយជាក់ច្បាស់, មាណពក៏កើតសេចក្តីរាប់អានចំពោះអមាត្យនោះរឹងរឹតតែខ្លាំងឡើង ទើបពោលថា:

"សំឡាញ់ជក! ឥឡូវនេះដល់វេលាដែលគួរទីឯឈប់សម្រាកហើយ ខ្ញុំកំពុងគិតនឹងសង្គ្រោះចំពោះសត្វដែលត្រូវគេបៀតបៀន, សូមលោក

អញ្ជើញទៅស្រោកនៅបន្ទប់ខាងណោះចុះ សូមសេចក្តីសុខសប្បាយកើតមានដល់លោកអស់កាត្រៃកុំបីឃ្លាតឡើយ" ។

*

* *

— ២ —

ថ្ងៃ ១៥ កើត ព្រះចន្ទពេញវង់ ជាថ្ងៃកំណត់ឫក្សធ្វើពិធីបូជាយ័ញរបស់ព្រះរាជាមកដល់ហើយ, ក្នុងរោងពិធីមុខព្រះបរមរាជវាំងសឹងណែនណាន់តាន់តាប់ ដោយទាហានក្រុមរក្សាព្រះអង្គឈរជាជួររៀងកាយត្រៀមចាំរក្សានូវសេចក្តីស្ងប់រៀបរយ ។ ការត្រៀមពិធីបុណ្យនេះបានចាប់ផ្តើមឡើងអំពីព្រលឹម, ពួកព្រាហ្មណ៍ក៏ធ្វើពិធីសូត្របួងសួងដោយមានពិធីការផ្សេងៗ, ពួកប្រជាជននាំគ្នាដើរជ្រៀតចូលទៅក្នុងបរិវេណដើម្បីមើលពិធីបុណ្យបូជាយ័ញទាំងមហោស្រពផ្សេងៗ ។ ខណៈនោះព្រះរាជាមិនទាន់ស្តេចមកដល់នៅឡើយ តែជិតនឹងដល់វេលាដែលស្តេចមកហើយ ។ ក្បួនហែ ១ នាំមុខ ដោយមានទាហានសេះចេញតាមទ្វារព្រះរាជវាំង ទាហានសែងស្នែងមានដំបូល ដែលបិទបាំងដោយវាំងននជិតស្និទ្ធ ក៏មកក្នុងក្បួននោះ ។ សម្លេងប្រជាជនដែលនៅក្នុងបរិវេណក៏ស្រែកប្រាប់គ្នាតៗថា "ព្រះអង្គម្ចាស់ក្សត្រីកំពុងប្រឈួនខ្លាំង. អាការព្រះឈួននោះអាចនឹងដល់នូវសេចក្តីអន្តរាយព្រះជន្មបាន" ក្បួនហែលឿនសន្សឹមៗ ចូលទៅតាំងនៅរោងពិធី ។ ខណៈនោះ ព្រាហ្មណ៍កំពុងតែស្វាធ្យាយ, ទាហានឈរជាជួររៀងកាយការពារប្រជាជនមិនឲ្យចូលទៅក្នុងផ្លូវដែលព្រះរាជានឹងស្តេចមក ។

បណ្ដាពួកមហាជនដែលនាំគ្នាដើរចូលមកមើលពិធីយញ្ញ មាន អមាត្យបាលិតនឹងមាណពកម្មោះទៅផងដែរ ជន ២ នាក់នេះក៏ព្យាយាម វែកញែកជ្រៀតជ្រែកគេចូលទៅដល់ជួរខាងមុខ ដែលជាទីអាចមើល ពិធីគ្រប់យ៉ាងដោយជាក់ច្បាស់បាន ។

មាណពកេះអមាត្យបាលិតឲ្យមើលគ្រប់ទាំងសត្វក្នុងពេលពិធីដែល ដាក់សត្វផ្សេង ៗ មានពពែ សេះ គោ ក្របី ជាដើម ដែលគួរឲ្យវេទនា ហើយប្រាប់ថា:

សំឡាញ់ចាស់ ! ក្នុងសម័យមួយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បាន ទ្រង់ហាមឃាត់នូវពិធីបូជាយញ្ញ របស់ព្រះរាជាមកអំពីមុនដែរ ហើយ ដោយព្រះអង្គជ្រាបក្នុងព្រះទ័យថា កម្មមានទោសជាទម្ងន់នឹងកើតមាន ដល់ព្រះរាជា ព្រោះតែពិឃាតសត្វមានជីវិត, បណ្ដាសត្វទាំងនោះ សត្វខ្លះ មានកូន ខ្លះកំពុងឈឺចាប់ ខ្លះមានគភ៌ មិនគួរដល់ការពិឃាត ដែលជា ទារុណកម្មដ៏សាហាវយង់ឃ្នង" កាលនិយាយហើយក៏ចង្អុលទៅមេគោ ១ ដែលមានសម្បុរស កំពុងតែលទ្ធតាមដងខ្លួនកូនតូចមួយ ដែលកំពុង បៅដោះដោយសេចក្ដីសប្បាយ, ទាំងមេទាំងកូនក៏មិនដឹងថាសេចក្ដីស្លាប់ កំពុងតែសសៀរចូលមកដល់ឡើយ; ហើយប្រាប់ថា:

"សំឡាញ់ចាស់ ! ព្រះពុទ្ធអង្គទ្រង់សំដែងថា សេចក្ដីស្លាប់ជា របស់ដែលនរណា ១ មិនអាចដឹងពិតបានឡើយ ដូចសត្វទាំងឡាយនេះ មិនដឹងនូវសេចក្ដីស្លាប់របស់វាដែរ" ។

អមាត្យបាលិត មានសេចក្ដីតក់ស្លុតចិត្តទៅតាមពាក្យរបស់មាណព,

កូនចិត្តទឹកចង់ជួយសត្វទាំងនោះឲ្យផុតពីការពិឃាតក្នុងគ្រានេះ ទើបសួរថា ៖

"លោកនឹងអាចជួយសត្វទាំងនេះឲ្យរួចផុតចាកអន្តរាយបានទេ?" ។

មាណពទ្រឹងមួយស្របក់ ទើបតបថា:

"ក្នុងរឿងនេះ ខ្ញុំកំពុងតែគិតរកផ្លូវ" ។

ខណៈនោះ ពួកអ្នកប្រកបពិធីបាននាំហ្វូងសត្វទាំងនោះចូលទៅជិតវេទនបូជា, ឯពួកសត្វសេះ គោ និងក្របី ដែលត្រូវគេដឹកនាំទៅ ក៏ភ្ញាក់ផ្អើលប្រែប្រួលប្រទាញគ្នាយ៉ាងកោលាហល ។

ប្រជាជនដែលនៅក្នុងបរិវេណជុំវិញកេងពិធី ក៏យល់ថាយញ្ញពិធីផ្តើមឡើងហើយ ។ សម្លេងស័ង្ខជាសញ្ញាថាព្រះរាជាស្តេចមកហើយ ក៏បន្លឺឡើង សម្លេងគឹកកងរំពងនោះស្ងប់ស្ងាត់ទៅ, ព្រះរាជាក៏ស្តេចចូលទៅប្រថាប់នៅព្រះពន្លា, ពួកព្រាហ្មណ៍ទើបស្ងប់សម្លេងសូត្រ ភ្នាក់ងារបាននាំគ្រឿងសំណែនថ្វាយព្រះរាជា ទាំងថ្វាយព្រះអង្គម្ចាស់ក្សត្រីដែលស៊ើយកំពងទនឲ្យឃើញអង្គដ៏ស្គមកំព្រឹង គង់ផ្អែកនឹងភ្នាក់ដៃ ថ្វាយបង្គំព្រះបិតា, ភ្នាក់ងារថ្វាយគ្រឿងសំណែនរួចហើយក៏នាំគ្នាចេញមក ។ បន្ទាប់មក ពួកព្រាហ្មណ៍ពោលពាក្យបូជាយញ្ញដ៏គួរគក់ស្លុត រួចទើបឲ្យគេនាំសត្វចូលមកសម្លាប់នៅវេទនបូជា :

"ឧមៈ បពិត្រមហិស្សរទេពជាធំក្នុងភពបីជាអម្ចាស់ដ៏មានមហិស្សគ្គតេជានុភាពលើសលប់ មិនមាននរណាទប់ទល់បាន, ឥឡូវនេះព្រះរាជាដ៏ទ្រង់ធម៌ ទ្រង់ស្តេចមកធ្វើពិធីបួងសួង សូមអំណាចមហិស្សគ្គតេជា-

នុភាពទ្រង់ការពារនូវព្រះរាជ. ទីងសត្វទាំងឡាយ សូមបំបាត់កំចាត់កយន្តរាយទាំងពួងឲ្យវិនាសសាបសូន្យ ហើយបណ្ដាលឲ្យមានទឹកភ្លៀងធ្លាក់ត្រូវតាមរដូវកាល, សូមឲ្យរោគដែលកើតដល់ពួកប្រជារាស្ត្រសាបសូន្យទៅ . . . " ។

ក្នុងឧកាសសូត្រនូវឧង្ការនេះ ជើងក្រានភ្លើងធំដែលគេដុតកំដៅរឹតតែខ្លាំងឡើង ដុំផ្សែងធំក៏ហុយឡើងទៅលើពេញទាំងបរិវេណ, មួយរំពេចនោះ ព្រាហ្មណ៍ក៏បង្គាប់ឲ្យភ្នាក់ងារនាំសត្វចូលមក ។

មេគោសទីងកូនខ្ចីជាសត្វចិញ្ចឹម មិនមានអាការតក់ស្លុតសោះ ព្រោះវាស៊ាំងដោយសារចំណីគឺស្មៅនិងទឹក ដែលគេចិញ្ចឹមរាល់ៗថ្ងៃ, កាលគេដឹកវាក៏ដើរតាមគេទៅដោយស្ងាត់ស្ងៀម, កូនគោអាល័យមេឃើញគេដឹកមេទៅក៏ដើរតាមមកផង វាឥតដឹងថាគេដឹកមេយកទៅដើម្បីសម្លាប់សោះ ហើយខ្លួនឯងត្រូវគេសម្លាប់ទៅតាមមេផងដែរ មេគោដើរតាមគេដឹកមកដល់ទីនធំ, ព្រាហ្មណ៍បង្គាប់ឲ្យមនុស្សដឹកឈរតទ្ធមេគោនោះ, កាលមេគោត្រូវគេផ្តួលក៏ដេកសណ្តូកជើងទាំង ៤ ចេញទៅខាង មាត់នៅចំពាអៀង, មនុស្សដឹកទាញខ្សែមកដើម្បីចងជើង, កូនគោដើរចូលទៅបៅដោះមេ, មនុស្សដែលកំពុងចងជើងមេគោឃើញដូច្នោះហើយ បានកាត់ចុងខ្សែវាយកូនគោនោះត្រូវត្រង់ក, កូនគោឈឺក៏ស្រែករោទ៍រត់ត្រឡប់ទៅ; ខណៈនោះ មេគោបានឮសម្លេងកូនរោទ៍ក៏ក្រោកឡើងរត់ចេញទៅ ធ្វើឲ្យពួកភ្នាក់ងាររត់ដេញចាប់ពាក់ពួន ។

# រឿងសាមកុក

## កណ្ឌទី ២៣

ឧកញ៉ាវិបុលរាជសេនា ង៉ួន-កាង ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្ដានស្នេហាជាតិ ។

គួនអ៊ូក៏ពណ៌នាសេចក្ដីតាំងពីដើមដល់ចប់ ប្រាប់ស៊ុនខៀនស្ដាប់គ្រប់ប្រការ; ស៊ុនខៀនក៏និយាយនឹងគួនអ៊ូថា ខ្ញុំបាទឮដំណឹងថា ឡៅតីទៅនៅនឹងអ៊ួនសៀវចៅហ្វាយស្រុកគីដីវ, ដែលខ្ញុំមកនៅនឹងឡៅផេកនេះ ខ្ញុំក៏បាននិយាយបញ្ចុះបញ្ចូលឡៅផេកនឹងកុងតៅ ៗ ក៏ព្រមចូលទៅធ្វើការនឹងឡៅតី ដើម្បីជួយគិតការកំចាត់ចូចូចេញឲ្យបាន, ឥឡូវឡៅផេកដឹងថាអ្នកលើកទ័ពមក ទើបប្រើទាហាននេះឲ្យនាំផ្លូវខ្ញុំមក មានបំណងនឹងឲ្យខ្ញុំជូនដំណឹងអ្នកថា ពេលព្រឹកស្អែកឡៅផេកនឹងកុងតៅនឹងចេញមកច្បាំង ហើយធ្វើជាចាញ់ថយទ័ពទៅឲ្យអ្នកមានបំណាច់គាប់ប្រសើរនឹងចូចូ ដើម្បីនឹងបាននាំបងថ្លៃទាំង ២ ទៅជួបនឹងឡៅតីឯក្រុងគីដីវ ។

គួនអ៊ូបានស្ដាប់ដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ថា ឥឡូវយើង

ដឹងដំណឹងជាក់ហើយថា ឡៅតីទៅនៅនឹងអ៊ូនសៀវ មុខជាយើងនឹងនាំបងថ្លៃទាំង ២ ទៅជួបនឹងឡៅតីមិនខាន ពោះបើអ៊ូនសៀវដឹងថាយើងបានសម្លាប់សេនាឯកអ៊ូនសៀវ ២ នាក់ស្លាប់ អ៊ូនសៀវនឹងសម្លាប់ជីវិតយើងវិញក៏តាមចិត្តចុះ សុំឲ្យតែឃើញមុខឡៅតីបងយើងសិន បើយើងមានជ័យជំនះឡៅផេកហើយ យើងនឹងត្រឡប់ចូលទៅក្រុងហ៊ូតោ ដើម្បីនឹងលាចូចូនាំបងថ្លៃទាំង ២ ទៅរកឡៅតី ។ ស៊ុនខៀនថា បើដូច្នោះខ្ញុំនឹងទៅរកឡៅតីមុនអ្នក ដើម្បីស្តាប់ដំណឹងមើលជាអ៊ូនសៀវខឹងខ្ញាំងនឹងអ្នកណាស់ទៅ ឬប្រការម្តេច? បើបានដំណឹងល្អ ឬអាក្រក់យ៉ាងណា ខ្ញុំនឹងស្រតមកជំរាបអ្នកឲ្យដឹងវិញ ។ គួនអ៊ូក៏ពេញចិត្តណាស់ លុះពេលយាម ៣ ក៏បង្គាប់ឲ្យទាហានដែលទំនុកទុកចិត្តនោះ ស្រាយលែងស៊ុនខៀននឹងទាហានម្នាក់ឲ្យលបរត់ចេញទៅពីបន្ទាយ ដល់ពេលព្រឹកគួនអ៊ូក៏ចាត់ចែងទាហានលើកចេញទៅច្បាំងនឹងពួកចោរ ។

ឯគុងតៅលុះដឹងថាគួនអ៊ូលើកទ័ពមក ក៏លើកទាហានចេញទៅត ៗ គួនអ៊ូក្រឡេកឃើញក៏បរសេះស្ទុះទៅពីមុខទាហានហើយក៏ស្រែកថា នែគុងតៅ ! ហេតុម្តេចបានជាខ្លួនមកគប់នឹងបក្សពួកចោរ ធ្វើអំពើទុច្ចរិតក្បថផែនដីដូច្នេះ? ។ គុងតៅឆ្លើយតបថា យើងនឹងបានជាមនុស្សទុច្ចរិតនឹងផែនដីក៏ទេ តែខ្លួនអ្នកឯងទេតើជាមនុស្សអកតញ្ញូមិនដឹងគុណនាយចៅហ្វាយ ដូចយ៉ាងឡៅតីជានាយចៅហ្វាយរបស់ខ្លួនទៅនៅជ្រកកោននឹងអ៊ូនសៀវ ហេតុម្តេចក៏ខ្លួនទៅចូលខាងចូចូ បើដូច្នេះខ្លួនមិនក្បថនឹងឡៅតីឬ? ។ គួនអ៊ូមិនឆ្លើយតបសោះក៏បរសេះចូលកយុទ្ធនឹងគុងតៅ

បាន ៤ ក្លែង, កុងតៅធ្វើជាទាញសេះរត់ គួនអ៊ូក៏បំផាយសេះដេញពីក្រោយ កុងតៅឃើញគួនអ៊ូដេញទាហានចូលទៅក៏រាបង្អង់សេះមកទឹមស្មាគ្នា ហើយងាកមុខមកនិយាយនឹងគួនអ៊ូថា ស្រុកយើឡាំដែលនៅក្នុងកណ្តាប់ដៃយើងនេះ យើងនឹងលើកប្រគល់ជូនអ្នកទាំងអស់ តែកុំឲ្យអ្នកភ្លេចគុណបំណាច់របស់ឡៅពីឡើយ ។

គួនអ៊ូបានឮកុងតៅថាដូច្នោះ ក៏ឃើញត្រូវគ្នានឹងសំដីស៊ុនខៀនទើបក្លែងបរសេះដេញចូលទៅក្នុងពួកទាហានកុងតៅ ៗ ក៏នាំឡៅផែកនឹងទាហានទាំងពួងរត់ទៅ ឯបណ្តាស្រុកចំណុះដែលឡើងស្តាប់បង្គាប់ស្រុកយើឡាំទាំងប៉ុន្មានដែលឡៅផែកនឹងកុងតៅវាយយកបាននោះ គួនអ៊ូក៏ប្រាប់ប្រាមបានរាបទាបដូចដើម ហើយគួនអ៊ូក៏លើកកងទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោវិញ នាំយកសេចក្តីទៅដំរាបប្អូនថា បានប្រាបប្រាមចោររាបទាបហើយ ៗ ប្អូនក៏សប្បាយរីករាយក្នុងចិត្តណាស់ ហៅគួនអ៊ូបរិភោគអាហារជាមួយគ្នា ហើយឲ្យបំណាច់រង្វាន់សេនាទាហានតាមគុណានុរូបដ៏សមគួរ ។

គួនអ៊ូក៏លាប្អូនមកផ្ទះ ទើបចូលទៅគំនាប់បងថ្លៃទាំង ២ ត្រង់មាត់ទ្វារ ពណ៌នាសេចក្តីដែលបានទៅធ្វើការសង្គ្រាម មានជ័យជំនះ ឲ្យបងថ្លៃស្តាប់គ្រប់ប្រការ ៗ នាងកាំហ៊ូយ៉ុនក៏សាកសួរថា ប្អូនទៅធ្វើសឹក ២ លើកហើយបានឮដំណឹងបងអ្នកឯងខ្លះដែរឬទេ? ៗ គួនអ៊ូក៏គិតថា បើនឹងពណ៌នាដោយត្រង់ក្រែងខ្វរខ្វាយសេចក្តីទៅដល់ប្អូន ទើបដំរាបថា " ខ្ញុំបាទទៅធ្វើការនោះក៏បានយកចិត្តគិតសាកសួរដំណឹងជាដរាប តែមិន

បានដឹងថាបងនៅទីឯណាសោះ" និយាយដូច្នោះហើយ គួនអ៊ូក៏លាបង ថ្លៃថយទៅទីក្រន្ទង ។ នាងកាំហ៊ុយ៉ិនឮគួនអ៊ូនិយាយដូច្នោះក៏ឲ្យពិកាល់ណាស់ ប្រឹក្សាគ្នានឹងនាងប៉ុហ៊ុយ៉ុនថា "ប្រហែលឡៅតីស្លាប់ហើយ គួនអ៊ូខ្លាចយើងនឹងសៅសោក ក៏ក្លែងបញ្ឆោតកុតយើងមិនប្រាប់តាមត្រង់" និយាយហើយក៏កៀកគ្នាសោកាទួញយំដំនុក ។

វេលានោះ មានទាហានចាស់របស់ឡៅតីដែលទៅជាទ័ពជាមួយនឹងគួនអ៊ូ បានឃើញកិរិយាឡៅតីសោកទួញយំដូច្នោះ ក៏ចូលទៅខ្សិបប្រាប់ថា អ្នកកុំជាទុក្ខព្រួយពេកឡើយ ឡៅតីចៅហ្វាយខ្ញុំបាទមិនមានអន្តរាយអ្វីទេ សព្វថ្ងៃលោកទៅនៅនឹងអ៊ួនសៀវចៅហ្វាយស្រុកគីជីវ ។ នាងកាំហ៊ុយ៉ិន នឹងនាងប៉ុហ៊ុយ៉ុនបានឮដូច្នោះក៏ធូរស្រាលក្នុងចិត្ត ទើបសួរថា ហេតុម្តេចបានជាអ្នកឯងដឹងរឿងនេះ? ។ ទាហាននោះក៏ជំរាបថា ខ្ញុំបាទបានទៅទ័ពជាមួយនឹងគួនអ៊ូមានគេមកប្រាប់ដំណឹងដូច្នេះ ។ នាងកាំហ៊ុយ៉ិនក៏ឲ្យហៅគួនអ៊ូមកហើយនិយាយថា អ្នកឯងនៅនឹងឡៅតី ៗ មិនបានធ្វើអ្វីឲ្យទាស់ចិត្តសោះ គ្រានេះបានចូលមកនៅនឹងចួច ៗ ក៏ទំនុកបំរុងឲ្យពេញប្រាថ្នា បានជាសប្បាយដោយយសបណ្ដាស័ក្តិភ្លេចទឹកដល់ឡៅតីហើយឬ? បានជាមិនយកដំណឹងដែលឮពិតនោះមកប្រាប់ឲ្យយើងដឹងផង ។ គួនអ៊ូក៏ភ័យស្លុតចិត្តលុតជង្គង់ចុះហើយជំរាបថា ខ្ញុំបាទនឹងបានគិតប្រទូសរ៉ាយនឹងឡៅតីជាបង ឬប៉ងនឹងបំភ្លេចគុណមិនទឹកនាដូច្នោះក៏ទេ តែថាបើខ្ញុំបាទនឹងជំរាបអ្នកជាបងតាមត្រង់ទៅ ខ្លាចគេដឹងសាយសុះបែករឿងនោះទៅដល់ចួច ៗ ក៏នឹងប្រែងប្រយ័ត្ន មិនឲ្យយើង

ចេញខ្លាត់ទៅបានដោយស្រួល ហេតុដូច្នេះបានជាខ្ញុំបាទមិនជំរាបដោយត្រង់ ។

នាងកាំហ៊ូយ៉ុនថា បើប្អូនមានចិត្តគិតដល់បងអ្នកជាក់ប្រាកដ បងសូមឲ្យគុណសណ្ឋិតជួយឲ្យប្អូនមានជ័យឈ្នះសត្រូវគ្រប់ទិសចុះ វេលានេះបានដំណឹងហើយគួរតែប្អូនរំពឹងគិត វេះរត់ទៅរកបងឲ្យឃើញមុខគ្នាជាប្រញាប់ ។ គួនអ៊ូក៏លាត្រឡប់មកវិញ ចេះតែរំពឹងគិតមិនឈប់សម្រាក ឃ្លាតចាកពេលបរិភោគអាហារនឹងនិទ្រាជានិរន្តរ៍ ។

ឯអ៊ុកឹមកាលទៅទ័ពជាមួយនឹងគួនអ៊ូនោះ លុះដឹងដំណឹងថា ឡៅតីទៅនៅនឹងអ៊ួនសៀវដូច្នោះ អ៊ុកឹមក៏នាំសេចក្តីនោះទៅជំរាបចូច្ចូគ្រប់ប្រការ ។ ចូច្ចូបានស្តាប់ពតិមានកាលណា ក៏មិនមានសេចក្តីសប្បាយសោះ ទើបប្រើទៀវលៀវឲ្យទៅស្តាប់ដំណឹងគួនអ៊ូតើជានឹងរំពឹងគិតយ៉ាងណា បើបានដឹងដំណឹងឡៅតីដូច្នេះហើយ ។ ទៀវលៀវក៏លាចូច្ចូទៅរកគួនអ៊ូដល់ហើយក៏គំនាប់គួរសមនឹងគ្នា ឃើញកិរិយាគួនអ៊ូមិនសប្បាយ ក៏និយាយថា ខ្ញុំឮគេថាអ្នកទៅគ្រានេះ បានឮដំណឹងឡៅតីថាទៅនៅស្រុកខាងទិសឯជើង ខ្ញុំក៏ក្លាយមានចិត្តសប្បាយជាមួយនឹងអ្នក ។ គួនអ៊ូតបថា ខ្ញុំដឹងដំណឹងឡៅតីមានជីវិតរស់នៅឡើយ ឥឡូវខ្ញុំក៏មានសេចក្តីព្រួយវិតក្កព្រោះតែពុំបានឃើញមុខឡៅតីនោះសោះ, ដែលអ្នកនឹងមានចិត្តសប្បាយជាមួយនឹងខ្ញុំនោះ ធ្វើម្តេចនឹងត្រូវ ។

ទៀវលៀវតបថា ខ្លួនអ្នកនឹងឡៅតីបានជាមិត្តភក្តិ ហាក់ដូចជាបងប្អូនបង្កើតនឹងគ្នាទៅហើយ ខ្លួនខ្ញុំនេះក៏ជាមិត្តភក្តិនឹងអ្នកដែរ តើចិត្តអ្នក

ដែលស្រឡាញ់ឡៅពីនឹងខ្ញុំនោះដូចគ្នាដែរ ឬដូចម្តេច? ។ គួនអ៊ូតបថា
អ្នកនឹងខ្ញុំជាមិត្រពប់អានគ្នាក៏មែន តែខ្ញុំមិនមែនមានចិត្តស្រឡាញ់ឲ្យស្មើ
ឡៅពីទេ ព្រោះឡៅពីនោះខ្ញុំបានកប់ប្រសព្វមកយូរហើយ ខាងខ្ញុំក៏
លើកទុកដាក់ជាជាបងហើយជានាយហៅហ្វាយផង មួយទៀតបានទាំង
ស្បថស្បាទ់ទុកនឹងគ្នាទៅវិញទៅមក ហេតុនេះ បានជាខ្ញុំត្រូវពប់អាន
ស្រឡាញ់ឡៅពីជាជាងអ្នក ។ ទៀវលៀវថា ឥឡូវអ្នកដឹងដំណឹងថា
ឡៅពីនៅនឹងអ៊ួនសៀវហើយ អ្នកនឹងទៅរកឬ ។ នឹងគិតប្រការម្តេច? ។

គួនអ៊ូតបថា ពីដើមដំបូងខ្ញុំក៏បានដំរាបទុកមកដល់មហាឧបរាជដូច
ខ្លួនអ្នកធ្វើជាបន្ទាល់ខ្ញុំស្រាប់ ថាខ្ញុំសូមលាទៅតាមពាក្យសញ្ញា ហេតុ
នេះបើអ្នកស្រឡាញ់ខ្ញុំសូមឲ្យជួយអនុគ្រោះនាំយកធុរៈនេះ ទៅស្នើដល់
មហាឧបរាជឲ្យទានផងចុះ សូមកុំឲ្យមហាឧបរាជមានកំហឹងនឹងខ្ញុំឡើយ ។

ទៀវលៀវក៏នាំយកសេចក្តីនោះ ទៅដំរាបចូចូស្តាប់គ្រប់ប្រការ ចូចូ
ក៏ថា យើងរិះគិតបងចិត្តគួនអ៊ូទុកឲ្យបាន តែគួនអ៊ូចេះរំខានព្រួយចិត្តគិត
ទៅរកឡៅពីមិនភ្លេច ។

ខណៈនោះ មានបំរើទៅប្រាប់គួនអ៊ូថា មានគេមករកលោក ។ គួនអ៊ូ
ឲ្យហៅចូលទៅហើយសួរថា អ្នកឯងឈ្មោះអ្វី, នៅស្រុកណា, មានការ
អ្វីមករកយើង? គាត់ជិនឆ្លើយថា ខ្ញុំបាទឈ្មោះគាត់ជិនជាទាហានអ៊ួន
សៀវ ឥឡូវអ៊ួនសៀវប្រើខ្ញុំបាទឲ្យនាំសំបុត្រឡៅពីមកជូនលោក ។ គួនអ៊ូ
មានសេចក្តីត្រេកអរពន់ពេក ទើបទទួលយកសំបុត្រនោះមកមើលឃើញ
សេចក្តីថា “សំបុត្រឡៅពីឲ្យមកដល់គួនអ៊ូបានដឹង ពីដើមខ្លួនយើងបាន

ស្បថស្បាទ់នឹងគ្នាទៅវិញទៅមកទាំង ៣ នាក់នៅទីសួនផ្កាថា នឹងរួមសុខ
ទុក្ខនឹងគ្នា តែខ្លួនយើងបានទៅនៅពឹងប្រស្រ័យនឹងអ៊ួនសៀវរបៅហ្វាយ-
ស្រុកគីជីវ ខាងខ្លួនអ្នកមកពឹងពាក់អាស្រ័យនៅនឹងបូធូធ្វើការសង្គ្រាម
មានសេចក្ដីគាប់ប្រសើរ គេក៏បានស្នើឲ្យគុណបំណាច់នឹងយសបណ្ដា-
ស័ក្ដិសមគួរនឹងគុណស្រ័យបានសេចក្ដីសុខដោយស្រីគ្គារបរិវារ វេលា
នេះ ប្រហែលខ្លួនអ្នកភ្លេចពាក្យដែលបានស្បថស្បាទ់នឹងយើងនោះហើយ
គ្រានេះខ្លួនយើងក៏រស់នៅឡើយមិនទាន់ស្លាប់ បើអ្នកប្រាថ្នានឹងបង់បាន
គុណគាប់ឲ្យបូធូរាប់អាន បានឡើងយសស័ក្ដិឡើងទៀត យើងសុំឲ្យអ្នក
ធ្វៀតចេញមកកាត់យកក្បាលយើងទៅឲ្យបូធូចុះ" ។

*
*　*

## កណ្ឌទី ២៤

តាំងពីគួនអ៊ូទទួលសំបុត្រឡៅពីហើយយំរលឹកឡៅពី រហូតដល់គួនអ៊ូរត់ពីបូធូទៅ, ហៃហ្សូរទុន លើកទាហានទៅតាមចាប់ខ្លួន មានបំរើកាន់សំបុត្របូធូមកឃាត់កុំឲ្យចាប់ឲ្យបើកគួនអ៊ូទៅ ។

---

លុះគួនអ៊ូមើលសេចក្ដីសំបុត្រចប់ ក៏ស្ទូតស្ងួបជាទុក្ខស្រក់ទឹកភ្នែក
នៅមុខបំរើនោះហើយនិយាយថា ដែលខ្ញុំមកនៅនឹងបូធូនេះព្រោះតែ
ទាល់គំនិត នឹងបានគិតបំភ្លេចមិននឹកដល់ឡៅពីជាបងនោះក៏ទេ ពោះបើ
ខ្ញុំសុំយកអាសាចេញទៅច្បាំងវេលាណា ក៏តែងស៊ើបសួរដំណឹងជាដរាប
លុះបានដំណឹងថាបងទៅនៅនឹងអ៊ួនសៀវច្បាស់ ក៏រិះគិតនឹងរកឱកាស
ទៅ តែមិនទាន់មានពេលបន្ទោះសោះ ។ គាន់ដឹងថា បើអ្នកមានចិត្ត
សប្បុរសរក្សាពាក្យសត្យពិតដូចពាក្យថា ក៏គួរខំខុសហ្វាហ៍រិះគិតទៅរកឡៅពី

កុំឲ្យខាន ។ គួនអ៊ីតបថា "កាលខ្ញុំចុះចិត្តមកនៅទីងបុប្ផជាបឋម ខ្ញុំក៏បានប្តេជ្ញាទុកទីងបុប្ផ ៣ ប្រការ, ឥឡូវនេះបើដឹងដំណឹងហើយប្រញាប់ទៅតាមសញ្ញាមែនក៏គិតខ្លាចគេគរហារនិន្ទា, ដូច្នេះ យើងត្រូវគិតរកឧបាយលាបុប្ផទៅឲ្យបានដោយស្រួលសិន ពោះបីបុប្ផទីងមិនព្រមឲ្យទៅ ខ្ញុំក៏ត្រូវតែទៅឲ្យបាន" ហើយគួនអ៊ីក៏តែងសំបុត្រតបទៅឡើងវិញ តាមដំណើរដើមទងគ្រប់ប្រការ ប្រគល់ឲ្យតាខ្ចិន ។ ទទួលសំបុត្រហើយក៏លាគួនអ៊ីចេញទៅវិញ ។ គួនអ៊ីក៏នាំសំបុត្រនោះទៅពណ៌នាប្រាប់បងថ្លៃទាំង ២ ឲ្យជ្រាបគ្រប់ប្រការ ។ បងថ្លៃទាំង ២ ក៏សោមនស្សត្រេកអរណាស់ គួនអ៊ីក៏លាបងថ្លៃទៅរកបុប្ផដើម្បីទីងលាទៅរកឡៀត ។

ខណៈនោះមានមនុស្សចូលទៅជំរាបបុប្ផថា គួនអ៊ីទីងចូលមកជំរាបលាលោកទៅរកឡៀតហើយ ។ បុប្ផក៏បិទទ្វារផ្ទះទាំងអស់ ហើយសរសេរសំបុត្របំពាមបិទទុកនៅមាត់ទ្វារថា មហាឧបកជមិនសូវសប្បាយ កុំឲ្យអ្នកផងទាំងឡាយចូលទៅប្រឹក្សាការអ្វី ៗ ឡើយ ។ គួនអ៊ីដឹងដូច្នោះក៏ទៅដល់មាត់ទ្វារមើលបំពាមឃើញហាមហើយ ក៏ត្រឡប់ទៅលំនៅវិញ ហើយឲ្យទាហានរបស់ខ្លួន ១១ - ១២ នាក់ រៀបប្រឹះប្រៀបរថសម្រាប់ឲ្យបងថ្លៃទាំង ២ ជិះទីងផ្ទុកទ្រព្យរបស់ស្រោល ។ គឺគ្រឿងសម្លៀកបំពាក់ទីងមាសប្រាក់ ឯរបស់ទ្រព្យឯទៀតទីងស្រីបំរើដែលបុប្ផឲ្យទៅនៅសម្រាប់ប្រើប្រាស់នោះ កុំឲ្យនរណាយកទៅណា លុះពេលព្រឹកគួនអ៊ីក៏ចូលទៅលាម្តងទៀត ឃើញបិទទ្វារដដែលក៏ដើរចូលទៅផ្ទះទៀវលៀវ, តែអ្នកចាំទ្វារមិនព្រមឲ្យចូលទៅប្រាប់ថាទៀវលៀវឈឺ ។

គួនអ៊ូគិតថា "ប៊ូចធ្វើដូច្នេះគឺក្លែងមិនចង់ឲ្យយើងទៅជួបនឹងទៀតពៅ ខ្លួនយើងក៏មានបរិវត្តក្តីទឹងបង្អង់នៅតទៅមិនបាន" ក៏ត្រឡប់មកទីឋានវិញ ហើយសរសេរសំបុត្រទុកថា "ខ្ញុំបាទគួនអ៊ូ សូមថ្លែងជំរាបសេចក្តីឲ្យមហាឧបាសជ្រាប ព្រោះខ្ញុំបាទនឹងទៀតពៅនោះបានស្បថស្បាទុកនឹងគ្នាថា នឹងរួមចិត្តជីវិតមួយគឺសុខទុក្ខជាមួយគ្នា បើនរណាស្លាប់ក៏សូមស្លាប់ជាមួយគ្នា នរណាៗ ក៏បានដឹងគ្រប់ទាំងអស់ កាលលើកកងទ័ពទៅវាយយកស្រុកហៃហ្វ៊ូនោះ ខ្ញុំបាទក៏បានចុះសញ្ញាជូនលោក ៗ ក៏ព្រមទទួលបដិញ្ញាណ បានជាខ្ញុំចូលមកនៅធ្វើការនឹងលោករហូតមកដល់ថ្ងៃនេះ ឥឡូវខ្ញុំបាទដឹងដំណឹងទៀតពៅច្បាស់ហើយ ខ្ញុំបាទសូមប្រណិប័តន៍លាលោកទៅរកទៀតពៅតាមពាក្យប្តេជ្ញា ដែលលោកមានគុណឧបការបានជួយឧបត្ថម្ភទំនុកបំរុងខ្លួនខ្ញុំបាទដរាបមកបានសេចក្តីសុខនោះ ខ្ញុំបាទក៏ត្រូវនឹករលឹកដល់ព្រះតេជព្រះគុណមិនភ្លេចទេ តែនឹងត្រឡប់លុបគុណទៀតពីដែលមានមកពីមុននោះមិនបាន បើអំណើះទៅមុខខ្ញុំបាទនៅមានជីវិត គង់នឹងត្រឡប់មកតបស្នងសងគុណលោកទៀត" លុះសរសេរចប់ហើយក៏បិទស្រោមប្រើបំរើយកទៅប្រគល់ឲ្យនាយទ្វារ ដែលរក្សាផ្ទះចូច ៗ គួនអ៊ូក៏យកត្រាសម្រាប់ការនឹងទ្រព្យរបស់ដែលចូចឲ្យនោះដាក់ក្នុងហិប ចាក់សោប្រគល់ឲ្យស្រីបំរើរក្សាទុកហើយ ទើបអញ្ជើញបងថ្លៃទាំង ២ ឡើងលើរថ ខ្លួនគួនអ៊ូឯងកាន់ដាវជិះសេះសឹកថៅនាំទាហាន ១១,១២ នាក់ចេញតាមទ្វារស្រុកខាងទិសឯជើង នាយទ្វារឃាត់មិនឲ្យចេញ គួនអ៊ូស្រែកគំហកដោយសំឡេងខ្លាំង នាយទ្វារក៏ភ័យភាំងស្មារតី

សុះតែទៅ គួនអ៊ូឲ្យទាហាន ១១, ១២ នាក់ក្រាបនៃថ្ងៃចេញទៅខាងមុខ, ខ្លួនគួនអ៊ូក៏នៅការពារពីខាងក្រោយ ទាហានទាំងនោះក៏បររថបណ្ដាយ តាមផ្លូវហ្លួងចេញទៅ ។

ឯចូចូប្រឹក្សាគ្នានឹងនាយទាហានទាំងពួង ដើម្បីនឹងរកទំនងចង់គួនអ៊ូទុក តែសេចក្ដីនោះក៏នៅមិនទាន់ស្រេះស្រួលគ្នា ទទួលនាយទ្វារយកសំបុត្រ គួនអ៊ូទៅជូនចូចូៗ ទទួលយកមកមើល លុះដឹងសេចក្ដីហើយក៏ភ្ញាក់ស្មារតី ឆ្ងេឆ្ងានិយាយថា បើដូច្នោះគួនអ៊ូមិនទៅហើយឬ? ។ ទទួលស្រីបំរើ ១០ នាក់នាំយកហិបដែលដាក់គ្រឿងទ្រព្យរបស់ ដែលគួនអ៊ូប្រគល់ ទុកឲ្យនោះនាំទៅជូនចូចូ ហើយជំរាបថា ឥឡូវគួនអ៊ូនាំបងថ្លៃទាំង ២ ចេញបាត់ទៅហើយ ។ ចូចូមិនទាន់ឆ្លើយតបថាម្ដេច ស្រាប់តែ នាយទ្វារស្រុកខាងទិសឯជើង នាំយកដំណឹងមកជំរាបចូចូថា គួនអ៊ូនាំ បងថ្លៃចេញទៅហើយ ខ្ញុំបាទឃាត់ក៏មិនស្ដាប់ បើនឹងចាប់អូសទង់ទាញ ក៏ខ្លាចគួនអ៊ូសម្លាប់ ។ ចូចូនឹងទីប្រឹក្សាមិនទាន់ថាដូចម្ដេច ស្ទួយហ៊ុងនាយ ទាហានបានស្ដាប់ដូច្នោះទើបឆ្លើយជំរាបចូចូថា ដែលគួនអ៊ូតែទៅនោះ ខ្ញុំបាទសុំទាហាន ៣ ពាន់ យកអាសាទៅតាមចាប់យកខ្លួនមកជូន លោកវិញ ។

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតំណាល

លោកសមិត មូត្យ័ផមៈ តែង

លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

— ទូលព្រះបង្គំជាមហាក្សត្រិយ៍សោយរាជ្យនៅប្រទេសនេះ; កងទ័ពសត្រូវដែលមានអានុភាពជាងកងទ័ពទូលព្រះបង្គំបានវាយកំទេចនៅក្នុងទីសមរភូមិ ដណ្តើមយកព្រះរាជអាណាចក្រ នឹងព្រះស្នំទូលព្រះបង្គំ ។ល។ នេះហើយជាហេតុឲ្យទូលព្រះបង្គំកើតទុក្ខពន់ប្រមាណ; ទូលព្រះបង្គំភ័យភិតខ្លាចបច្ចាមិត្តជាខ្លាំងមិនហ៊ានស្ថិតនៅក្នុងទីក្រុងណាសោះឡើយ ទើបទូលព្រះបង្គំស៊ូដើរវង្វេងទៅក្នុងព្រៃតែម្នាក់ឯង ។ បើអ្នកណាបានស្តាប់រឿងរ៉ាវប្រកបដោយសេចក្តីទុក្ខដែលទូលព្រះបង្គំទិទាននេះហើយ អ្នកនោះឯងនឹងមានទុក្ខ ប្រៀបដូចជាថ្មធ្លាក់ចំមកលើខ្លួន" ។

ក្រោយដែលទ្រង់ព្រះសណ្តាប់នូវពាក្យនេះ, ព្រះបាទវិក្រមាទិត្យទ្រង់បានព្រះរាជទាននូវវត្ថុពិសិដ្ឋទាំង ៣ នោះទៅព្រះមហាក្សត្រិយ៍ដែលបរាជ័យនោះ, រួចទ្រង់បន្តព្រះរាជដំណើរទៅកាន់រាជធានីព្រះអង្គវិញ ។

ចំណែកព្រះមហាក្សត្រិយ៍បរាជ័យនោះ លុះដល់ទ្រង់បានវត្ថុដ៏ប្រសើរទាំងបីហើយ ទ្រង់ក៏បានវាយដណ្តើមយកព្រះរាជអាណាចក្រ, ព្រះស្នំ ... ល .. មកវិញ" ។

រូបទេពនិម្មិតទី ១៩ ទូលបន្ទែមថា: "បពិត្រព្រះបាទភោជៈ, ទូលព្រះបង្គំបានពណ៌នាអំពីមហាសប្បុរសនៃព្រះបាទវិក្រមាទិត្យ, បើទ្រង់មានព្រះរាជចរិយាបែបនេះ, ទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន" ។

ក្នុងពេលនោះ, ព្រះបាទភោជៈទ្រង់ព្រះសណ្ដាប់ នូវពាក្យដែលរូបទេពនិម្មិតបានថ្លែង ទ្រង់ក៏ចៀសចេញពីបល្ល័ង្កទិព្យនោះទៅ ។

## និទាននៃរូបទេពនិម្មិតទី ២០

មានមួយថ្ងៃ, រូបទេពនិម្មិតទី ២០ បានទតទៅឃើញមហារាជភោជៈ ទ្រង់កំពុងស្ដេចយាងមកជិតព្រះបល្ល័ង្កទិព្យ, ទ្រង់ក៏មានព្រះបន្ទូលថា: "បើទ្រង់មានព្រះរាជចរិយាដូចគ្នានឹងព្រះមហាក្សត្រិយ៍វិក្រមាទិត្យ ទ្រង់ទើបអាចគង់លើបល្ល័ង្កទិព្យនេះបាន ដើម្បីទ្រង់ទទួលព្រះរាជាភិសេក, សូមទ្រង់ជ្រាបអំពីព្រះរាជចរិយានៃព្រះមហាក្សត្រិយ៍វិក្រមាទិត្យ ដូចតទៅនេះ :

' មានកាលមួយថ្ងៃព្រះរាជទីប្រឹក្សារបស់ព្រះបាទវិក្រមាទិត្យ មួយនាក់ ឈ្មោះពុទ្ធិសាគរ (Buddhi sāgara) បានពិនិត្យទៅឃើញថាបុត្រលោកនាមពុទ្ធិសេខរ: (Buddhi Cekhara) ជាបុគ្គលល្ងង់ខ្លៅ, មានប្រាជ្ញាទន់ទាបជាយ៉ាងក្រៃលែង ក៏បាននិយាយនឹងកូននោះថា: ឱកូន! កូនឯងជាពូជព្រះរាជទីប្រឹក្សាហើយ តែកូនឯងជាមនុស្សល្ងង់ ព្រោះកូនឯងស្ថិតនៅជិតបណ្ឌិតតែមិនបានប្រតិបត្តិតាមពាក្យទូន្មាន ដែលមានតារទុកក្នុងសាស្ត្រ: ។ មនុស្សណាដែលគ្មានប្រាជ្ញាមិនបានសូត្ររៀន

ទូវសាស្ត្រៈ មិនបានព្យាយាមអប់រំខ្លួនទៅកាន់សុក្រិតភាព, មនុស្ស នោះមានមុខមាត់ជាមនុស្សក៏ពិតមែនហើយ, តែត្រូវឲ្យដឹងថាជា មនុស្សមានសភាពឃោរឃៅពាលសាមាន្យ ។ ឱកូនសំឡាញ់ឪពុក! មែនពិត, មនុស្សយើងដែលពេញចិត្តក្នុងការសិក្សារៀនសូត្រសាស្ត្រៈ តែងខុសគ្នាពីមនុស្សពាលសាមាន្យ តាមលំនាំដែលរស់នៅក្នុងលោក ។ បើតាមសភាពផ្ទុយវិញ, មនុស្សណាដែលកង្វល់រវល់តែនឹងម្ហូបអាហារ, ដេក, ខ្លាច, ស្រឡាញ់ ។ល។ មនុស្សនោះប្រៀបដូចជាសត្វតិរច្ឆាន ។ បានសេចក្តីថាមនុស្សនោះនឹងសត្វតិរច្ឆាន មានសភាពមិនខុសគ្នាទេ ។ ប្រាជ្ញាដែលបានមកពីការសិក្សារៀនសូត្រសាស្ត្រៈ កូនឯងគ្មានក្នុងខ្លួន សោះឡើយ; ម្ល៉ោះហើយ ជីវិតពេញឯងជាការឥតប្រយោជន៍" ។

"ពុទ្ធិសេខរៈ ក្រោយដែលបានស្តាប់ពាក្យបន្ទោសរបស់បិតា ចំពោះការសិក្សារបស់ខ្លួន ក៏បានធ្វើដំណើរទៅកាន់បរទេសដើម្បីនឹង សិក្សារៀនសូត្រសាស្ត្រៈ លោកបានចូលទៅប្រស្រ័យនឹងលោកគ្រូ មួយរូប, បានរៀនសូត្រសាស្ត្រៈទាំងអស់ចប់សព្វគ្រប់ហើយ ក៏វិល ត្រឡប់មកប្រទេសលោកវិញ ។

តាមរយៈផ្លូវដែលលោកធ្វើដំណើរមក លោកបានក្រឡេកទៅ ឃើញទីក្រុងមួយមានបូជនីយដ្ឋាននាងទេវធីតា, លោកក៏បានអញ្ជើញ ទៅកាន់បូជនីយដ្ឋាននោះ ហើយក៏សម្រាកនៅទីនោះ ។ ពេល សាយណ្ហសម័យ, លោកបានឃើញនាងកញ្ញា ៨ នាក់ ចេញពីបឹងមួយ ដែលស្ថិតនៅជិតបូជនីយដ្ឋាននោះ; នាងបានខិតចូលទៅជិតបូជនី-

យដ្ឋាន ហើយក្នុងយប់នោះនាងសំដែងគារវភាពចំពោះនាងទេវតា, ព្រមទាំងសូត្រធម៌សំដែងបសំសនកថាផ្សេងៗ ថ្វាយជយមង្គល ៗ ដល់ពេលបច្ចូសសម័យ នាងក៏វិលចូលទៅក្នុងបឹងវិញ ។

ក្រោយដែលបានឃើញមហាអច្ឆរិយភាពនោះ ពុទ្ធិសេខរៈក៏វិលត្រឡប់មកកាន់មាតុភូមិវិញ, ហើយចូលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យ ។ កាលទ្រង់ព្រះសណ្ដាប់នូវរឿងរ៉ាវនោះហើយ ទ្រង់ក៏យល់ថាជាអច្ឆរិយភាពពិតមែន, ទ្រង់ក៏ស្ដេចយាងទៅកាន់បូជនីយដ្ឋាននោះ ។ ដល់ពេលសាយណ្ហសម័យទ្រង់ក៏បានទតទៅឃើញនាងកញ្ញា ដូចជាពុទ្ធិសេខរៈបុត្រព្រះរាជទីប្រឹក្សាបានក្រាបបង្គំទូលដូច្នោះមែន ។ លុះដល់ពេលអរុណរះ, នាងកញ្ញាក៏លោតទៅក្នុងទឹកបឹងនោះបាត់ទៅ ។ មហារាជទ្រង់ទតទៅឃើញហេតុដូចនោះ, ទ្រង់ក៏លោតទៅក្នុងទឹកបឹងតាមស្ដ្រីទាំងនោះ ។

"នាងកញ្ញាបានឃើញព្រះរាជសកម្មភាព នៃមហារាជវិក្រមាទិត្យក៏ពោលពាក្យថា: "ឱ! ព្រះបាទវិក្រមាទិត្យ! ព្រះអង្គទ្រង់ជាចមកត, ទ្រង់មានព្រះរាជហឫទ័យសោមនស្សពន់ពេក ចំពោះអច្ឆរិយភាពដែល, ទ្រង់ទតទៅឃើញ ទ្រង់ក៏បានតាមយើងមកកាន់ទីនេះ" ។ នាងកញ្ញា, ក្រោយដែលបានពោលពាក្យដូច្នេះហើយ ក៏ដង្ហែរមហារាជវិក្រមាទិត្យ ទៅកាន់នគររបស់ខ្លួនដែលរចនាដោយកែវត្បូងភ្លឺផ្លេកប្រាក់, ស្ថិតនៅលើកពបាតាលហើយ ក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យថា: "បពិត្រព្រះសម្មតិទេព! សូមទ្រង់គង់នៅនគរនេះ ដូចជានគរ

របស់ព្រះអង្គចុះ ។ ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះរាជឱង្ការទៅកាន់នាងកញ្ញាថា៖ “ខ្ញុំមានទោសខ្ញុំហើយ ឲ្យខ្ញុំត្រូវការទោសនេះដូចម្ដេចបាន? តែខ្ញុំសូមសួរនាងថា៖ “តើទោសនេះយ៉ាងណា?” ។ នាងកញ្ញាទាំងអស់ក៏ក្រាបបង្គំទូលថា៖ យើងខ្ញុំជានាងកញ្ញា ៨ នាក់ជាស្រីប្រកបដោយបញ្ចពិធកល្យាណី” ទោសនេះជាគេហដ្ឋានសម្រាប់លេងល្បែងរបស់យើងខ្ញុំ យើងខ្ញុំមានចិត្តសោមនស្សពន់ពេកដោយបានឃើញទ្រង់ក្នុងពេលនេះ, យើងខ្ញុំសូមថ្វាយនូវកែវ ៨, (១) សូមព្រះអង្គទ្រង់ទទួលយកចុះ ឯគុណសម្បត្តិនៃកែវទាំង ៨ នោះដូចតទៅនេះ ៖

កែវទី ១ អាចឲ្យមានព្រះប្រាជ្ញាជាសុក្រិត, កែវទី ២ អាចមានព្រះរាជបំណងចង់សោយព្រះក្រយាហារអ្វីតាមព្រះរាជហឫទ័យ (២), កែវទី ៣ អាចបញ្ចេញកងទ័ពមាន ៤ កង (៣) ថ្វាយ; កែវទី ៤ អាចឲ្យមហារាជសម្រេចទៅតាមដោតរសនាជាទិព្យ (៤), កែវទី ៥ អាចថ្វាយទ្រង់នូវព្រះសុពណ៌បាទមានរិទ្ធិជាយ៉ាងក្រៃលែង; កែវទី ៦ អាចឲ្យមហារាជធ្វើរបស់ដែលគេម្រែកឲ្យស្ថិតនៅនឹងបាន; កែវទី ៧ អាចឲ្យទ្រង់បានព្រះប្រាជ្ញាដ៏មោះមុត; កែវទី ៨ អាចឲ្យទ្រង់បានសេចក្ដីសុខជាអនេក ។ នាងកញ្ញាទាំងអស់បានថ្វាយកែវទាំង ៨ ចំពោះមហារាជ ក្រោយដែល

---

១ ត្រូវប្រៀបធៀបនឹងនិទាននៃរូបទេពនិម្មិត ទី ៣, ទី ១៧ និង ទី ១៩ ។

២ កែវ ទី ១ នៃនិទានរូបទេពនិម្មិត ទី ៣ ។

៣ កែវ ទី ៣ នៃនិទានរូបទេពនិម្មិត ទី ៤ ។

៤ គឺទ្រង់អធិដ្ឋានព្រះបរមរូប ជារូបទេវតា បានដោយទេវឫទ្ធិ ។

បាន ក្រាបបង្គំទូលនូវគុណសម្បត្តិនៃកែវទាំងនោះ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ក៏បានទទួលនូវកែវទាំង ៨ ពីនាងកញ្ញាទាំងនោះ ហើយក៏ទ្រង់ស្ដេចយាងវិលត្រឡប់ទៅកាន់ព្រះរាជនិវេសនដ្ឋានវិញ ។

ព្រះរាជាកាលដែលទ្រង់ស្ដេចយាងតាមផ្លូវមក ទ្រង់បានទតទៅឃើញព្រាហ្មណ៍ទុគ៌តម្នាក់ ។ ព្រាហ្មណ៍ក្រឡេកទៅឃើញព្រះបាទវិក្រមាទិត្យ ស្គាល់ជាព្រះអង្គហើយក៏មកថ្វាយបង្គំព្រះអង្គ ហើយស្រែកសូមទានព្រះអង្គថា: "បពិត្រព្រះសម្មតិទេព ! ទូលព្រះបង្គំជាខ្ញុំ ជាព្រាហ្មណ៍មានសេចក្ដីទុក្ខលំបាកក្រប៉ាន់ក្នុងពេលនេះ, ទ្រង់ជាមហាករាជប្រកបដោយមហាសប្បុរិសធម៌ សូមទ្រង់ព្រះរាជទានអ្វីមួយ ដែលជាហេតុធ្វើឲ្យទូលព្រះបង្គំលែងមានទុក្ខលំបាក ដោយសេចក្ដីត្រូវការអ្វីសោះឡើយ, សូមឲ្យទូលព្រះបង្គំស្ថិតនៅជាសុខ" ។ មហារាជវិក្រមាទិត្យទ្រង់ព្រះសណ្ដាប់នូវពាក្យព្រាហ្មណ៍, ទ្រង់ក៏បានព្រះរាជទានកែវទាំង ៨ ទៅព្រាហ្មណ៍នោះហើយ ទ្រង់ក៏បន្តព្រះរាជដំណើរទៅដល់ព្រះរាជនិវេសនដ្ឋាន ។

រូបទេពនិម្មិតទី ២០ ទូលបន្ថែមថា: "បពិត្រមហាក្សត្រិយ៍ភោជៈ បើទ្រង់មានព្រះមហាសប្បុរិសធម៌ ដូចព្រះបាទវិក្រមាទិត្យ, ទ្រង់ស្ដេចយាងមកគង់លើបល្ល័ង្កទិព្វនេះចុះ ។ បើមិនដូច្នោះទេ, ទ្រង់កុំខិតចូលមកជិតបល្ល័ង្កទិព្វនេះឡើយ" ។

ក្នុងពេលនោះព្រះបាទភោជៈ ខ្មាសអៀនក៏ទ្រង់ថយពីទីកន្លែងនោះ ។

* * *

(មានត)

# ពុទ្ធសាសនបណ្ឌិត្យ

និង

# ពិព័រណ៍អន្តរជាតិ នៅក្រុងភ្នំពេញ

លោក ជាប-ពិន រៀបរៀង

---

កាលពីថ្ងៃ ១៥ វិច្ឆិកា ដល់ថ្ងៃទី ១១ ធ្នូ ព.ស. ២៤៩៨ គ.ស. ១៩៥៥ ប្រទេសកម្ពុជាបានតាក់តាំងសម្ភារៈ ហៅថា "ពិព័រណ៍អន្តរជាតិ" នៅជុំវិញបរិវេណវត្តភ្នំ ក្រុងភ្នំពេញ ។ ការតាំងនោះមានជាតិនានាចំនួន ១២ ប្រទេសមករួមតាំងជាស្តង់មួយៗ ដោយឡែកតាមសញ្ជាតិ គឺប្រទេសអាមេរិក, បារាំង, ឥណ្ឌា, ជប៉ុន, ថៃ, លាវ, វៀតណាមខាងត្បូង, អង់គ្លេស, ម៉ាឡេស៊ី សឹង្ហបុរី, និង (ហុល្លង់មកមិនទាន់) ។

ក្រសួងពុទ្ធសាសនបណ្ឌិត្យ និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ក៏ត្រូវចូលតាំងជាមួយនឹងគេដែរ គឺតាំងសម្ភារៈដែលទាក់ទងខាងវប្បធម៌ខ្មែរក្នុងស្តង់មួយនៅខាងត្បូងភ្នំជាមួយក្រសួងសិក្សាធិការជាតិ, សាលាវិចិត្រសិល្បៈខេមរៈ និងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ។

ការតាំងនេះចែកជា ២ ផ្នែក :

— ផ្នែកពុទ្ធសាសនបណ្ឌិត្យ តាំងបុរាណវត្ថុផ្សេងៗ ជាវត្ថុសម្រាប់វត្តខាងព្រះពុទ្ធសាសនាហើយជារចនារបស់ខ្មែរ មានដើមជា: គម្ពីរស្លឹករឹតបិទមាសក្របមខ្មៅ, សៀវភៅព្រះត្រៃបិដកបោះពុម្ព, វចនានុក្រមខ្មែរ, ក្រាំងនិងសៀវភៅក្របចម្លាក់បិទមាស, បាត្រត្របដាំខ្យង,

ផ្តិតមន្ត្រីសង្ឃ, ត្រាសម្រាប់វត្ត, ចែត់យោគី, ព្រះពុទ្ធរូបអង្គតូចៗ ។ វត្ថុទាំងនេះ តាំងលើតុធំវែងមួយក្រាលកម្រាលសំពត់ខ្សែនព័ណ៌ស៊ុំខ្ទួទ្វីជមានលំអគួរឲ្យចង់ទស្សនា ។ នៅខាងមុខតុមានក្រែទេសនារូបកាជ-សីហ៍បិទមាសលំអដោយឆ័ត្រួតពាសអង្កាំ, មានទូបិទមាសសម្រាប់ដាក់គម្ពីរ និងមានរទេះបំបោល ។ល។

— ផ្នែកក្រមជំនុំទំនៀមទម្លាប់តាំងពីបុរាណវត្ថុផ្សេងៗ ជារចនារបស់ខ្មែរ ហើយជាវត្ថុទាក់ទងខាងទំនៀមទម្លាប់ខ្មែរ មានដើមជា: រូបភាពពពិលជាវិការនៃសម្រិទ្ធសម្រាប់ប្រើក្នុងពិធីមង្គលផ្សេងៗ, ព្រះពុទ្ធ-បដិមាដែលគេសាងក្នុងវេលាភ្ជុំបិណ្ឌ, រូបភាពព្រះសិវៈ · ព្រះវិស្ណុ ជាសរណវត្ថុខាងសាសនាព្រាហ្មណ៍, ក្រាំងចម្លាក់បិទមាសនិយាយពីក្បួនព្រហ្មជាតិមានគំនូរឲ្យព័ណ៌ជារូបសត្វផ្សេងៗ ដែលមាននាមលើឆ្នាំនិងខែទាំង ១២, ក្រាំងតែក្រូមនិយាយពីពិធីសង់ត្រឹះស្ពាន; ខ្សែគម្ពីរត្បាញជាអក្សរខ្មែរដាក់នាមទីកន្លែងនិងសេចក្ដីប្រាថ្នាអ្នកសាង, ក្រាំងបិទមាសនិយាយពីក្បួនត្បាញខ្សែគម្ពីរ, អាវគេជៈសម្រាប់អ្នកច្បាំងពាក់ការពារខ្លួន ។ល។ វត្ថុទាំងនេះ តាំងនៅលើតុធំវែងមួយក្រាលកម្រាលដូចគ្នា ។

នៅនាជញ្ជាំងឯត្បូងខាងក្រោយតុទាំង ២ មានបដាផ្ទាំងធំៗ គូរដាក់ព័ណ៌ជារូបភាពល្បែងផ្សេងៗ បង្ហាញឲ្យទស្សនជនស្គាល់ទំនៀមល្បែងបុរាណរបស់ខ្មែរមនៗ គឺល្បែងត្រដិ រាំស្នងទទេរ្យាង កន្ដែរ៉ ស្វរព្រ័ត្ត ដាំដូង យោលទោង ទាំពែកជល់គ្នា គុនដំបង ស្ទួលពាំត្បាល់ ព្រះរាជពិធីច្រត់ព្រះនង្គ័ល ពិធីពូនភ្នំស្រូវ កន្សែងយ័ន្ត ។ល។

នៅចន្លោះខាងក្រោយតុទាំង២ មានរូបមួយធំដាក់សៀវភៅសំខាន់ៗ ដែលបានបោះពុម្ពផ្សាយចេញពីក្រសួងពុទ្ធសាសនបណ្ឌិត្យ សម្រាប់ផ្សាយទាំងផ្លូវលោកផ្លូវធម៌ ។

នៅចន្លោះមុខតុទាំង ២ មានដំកល់ព្រះបរមឆាយាល័ក្ខណ៍ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តម-សុរាម្រិត, សម្ដេចព្រះមហាក្សត្រិយានី កុសុមនារីរ័ត្ន៍ របនាដោយកញ្ចក់ និងសម្ដេចព្រះឧបយុវរាជនរោត្តម-សីហនុ របនាដោយម្នាងសិលា ទ្រង់ព្រះសណ្ឋិតជាប្រមុខ នៅចំកណ្ដាលត្រង់ចន្លោះខាងមុខតុតាំង ដ៏មានលំអដោយផើងដើមពោធិ៍ស្រស់ញញឹមអមព្រះអង្គ ។

នៅជញ្ជាំងខាងកើតតុទាំងនោះ មានតាំងព្រះបដផ្ទាំងធំៗ គឺព្រះពុទ្ធរូបគ្រាសំដែងព្រះធម្មចក្រប្រោសបញ្ចវគ្គីយ គ្រាសំដែងព្រះអភិធម្មប្រោសពុទ្ធមាតា និងមានរបនាដោយសន្ទឹកព្រះបដតូចៗ រឿងទសជាតក៍ព័ទ្ធជុំវិញបដាធំៗ ជាភាពអក្សរ ដែលសំគាល់សេចក្ដីថា "ពុទ្ធសាសនបណ្ឌិត្យ ឬ ពុទ្ធសាសនា" នាំឲ្យទស្សនជនពិតពិលរមិលមើលដក់ភ្នែកយូរៗមិនចង់លែង ។

ស្ដង់នេះមានខេមរជន និងជនបរទេសមកទស្សនាជាច្រើនយ៉ាងកុះករ, តែបណ្ដាទស្សនជនទាំងនោះ ជនបរទេសចូលចិត្តទស្សនាបុរាណវត្ថុផ្សេងៗ ដោយសង្កេតហាក់បត់ជាងខេមរជន; ដែលគេពេញចិត្តជាងគេនោះ គឺអាវគេជ: និងពពិល ។

មានភ្នាក់ងារសារពត៌មានបរទេសជាច្រើន មកថតមកសាកសួរយកការណ៍ទៅចុះសារពត៌មានផ្សេងៗ សរសើរស្ដង់នេះពុំដាច់មាត់ ។ ដោយហេតុនេះហើយ ទើបគណៈកម្មាធិការពិព័រណ៌អន្តរជាតិ បានចេញគ្រឿងឥស្សរិយយស (មេដាយ) ប្រាក់ ១ ឲ្យទុកជាកិត្តិយសនឹងជាអនុស្សាវរីយ៍ ដើម្បីបង្ហាញប្រជាជនខេមរជាតិឲ្យស្គាល់ថា ក្រសួងពុទ្ធសាសនបណ្ឌិត្យ បានរួបរួមតាំងស្ដង់ខាងវប្បធម៌ខ្មែរ ដ៏ឧឡារិកជាមួយនឹងពិព័រណ៌អន្តរជាតិ ដែលជាករណីយកិច្ចមានសារប្រយោជន៍ដល់ប្រទេសកម្ពុជាយើង ។

## សម្ភាសន៍

នៅថ្ងៃទី ១៧ វិច្ឆិកា ១៩៥៥ មានភ្នាក់ងារទស្សនាវដ្ដីហ្វ្រង់-អាស៊ី ពីរនាក់ដែលមកសង្កេតយកការណ៍អំពីពិព័រណ៌អន្តរជាតិ នៅភ្នំពេញ បានមកធ្វើសម្ភាសន៍អំពីស្ដង់ពុទ្ធសាសនបណ្ឌិត្យ ជាភាសាបារាំងជាមួយលោក ឃៀន-ចឹម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ អំពីស្ដង់នេះ ។ ការសម្ភាសន៍នេះ ដោយបញ្ចូលសំឡេងទៅក្នុងថាសម៉ាស៊ីន មានសេចក្ដីដូចតទៅនេះ ៖

ស – សូមលោកមានប្រសាសន៍អធិប្បាយអំពីក្រសួងពុទ្ធសាសន-បណ្ឌិត្យ អំពីកិច្ចការនឹងអំពីសារសំខាន់នៃក្រសួងនេះ ក្នុងការតាំងពិព័រណ៌នេះ ឲ្យខ្ញុំបាទទាំងពីរនាក់ស្ដាប់បន្តិច ?

ឆ.– ក្រសួងពុទ្ធសាសនបណ្ឌិត្យជាទីប្រជុំចិត្តនៃប្រជាជនខ្មែរ ។ គោលបំណងធំ គឺត្រួតត្រា នឹងសម្រុះសម្រួលការសិក្សាខាងលទ្ធិព្រះពុទ្ធសាសនាផ្នែកហីនយានឬហៅថា "ថេរវាទ" ជាមួយនឹង

ប្រជាជនខ្មែរក្នុងប្រទេសហើយនិងពួកខ្មែរមួយក្រុម ដែលនៅវៀតណាមប៉ែកខាងត្បូង ។

ឯការសំខាន់របស់ក្រសួងនេះ គឺ:

១.– ការបោះពុម្ពផ្សាយសៀវភៅជាភាសាបាលីនិងភាសាខ្មែរ ដូចជាសៀវភៅព្រះត្រៃបិដក (ដែលលោក.ឃើញនៅខាងមុខនេះស្រាប់) វចនានុក្រមខ្មែរ និងទស្សនាវដ្តីប្រចាំខែជាច្រើនទៀតជាភាសាបាលី-ខ្មែរ និងជាភាសាបរទេស ។ សៀវភៅទាំងនេះអធិប្បាយអំពីសិល្បៈ អំពីការស្រាវជ្រាវរកបុរាណវត្ថុ អំពីសាសនានិងអំពីពង្សាវតារខ្មែរ;

២.- ការសិក្សាភាសាដែលជាឫសគល់នៃភាសាឯទៀត គឺបាលីនិងសំស្ក្រឹត ។ មានព្រះសង្ឃជាអ្នកប្រាជ្ញមួយក្រុម កំពុងសិក្សាភាសាទាំងនេះដោយម៉ត់ចត់ ដើម្បីឲ្យចេះដឹងនូវលទ្ធិព្រះពុទ្ធសាសនាផង ដើម្បីឲ្យចេះដឹងភាសាទាំងនេះផង;

៣ - មាននិពន្ធបណ្ឌិតមួយក្រុមជាអ្នកស្រាវជ្រាវរិះរកនិងសរសេរអត្ថបទផ្សេងៗ ដើម្បីអប់រំនិងបណ្ដុះនូវគុណសម្បត្តិខាងចរិយានិងខាងផ្លូវចិត្តរបស់ប្រជាជន;

៤.– ការបង្កើតឲ្យមានបណ្ណាល័យមួយ សម្រាប់ពួកបព្វជិត គ្រហស្ថ-និស្សិត-អ្នកពជការក្នុងប្រទេសនិងបរទេស អានមើលសិក្សារៀនសូត្រ;

៥.– ការស្រាវជ្រាវរកនិងរក្សាទុកនូវឯកសារចាស់ៗ ដែលស្តីអំពីសាសនា ទំនៀមទម្លាប់និងពង្សាវតារស្រុកខ្មែរ ។

ស.- ហេតុដូចម្ដេចបានជាលោកមកតាំងស្ដង់លោកនៅក្នុងបន្ទប់សម្រាប់តាំងរបស់ដែលជាប់ទាក់ទងនឹងប្រពៃណីជាតិដូច្នេះ?

ឆ.- គោលបំណងធំនៃការតាំងនេះមានពីរយ៉ាង ៖

១.- ដើម្បីបង្ហាញដល់ទស្សនជន អំពីសារៈសំខាន់នៃព្រះពុទ្ធសាសនា អំពីការជឿនិងការគោរពរបស់ប្រជាជនខ្មែរចំពោះព្រះពុទ្ធសាសនា;

២.- ដើម្បីបង្ហាញដល់ទស្សនជនថា នៅពេលដែលការធ្មេញកងលោកកំពុងតែរីកពាយ ប្រជាជនខ្មែរនៅតែរក្សាភ្ជាប់នូវទំនៀមទម្លាប់ពីបុរាណ;

ស.- តើលោកអាចបង្ហាញឲ្យខ្ញុំស្គាល់របស់ក្នុងស្ដង់លោកផងបានទេ?

ឆ.- ក្នុងស្ដង់ខ្ញុំមានរបស់ ៣ ផ្នែក ៖

ផ្នែកទីមួយ: របស់សម្រាប់វត្ត ដូចជាទូដាក់សាត្រា, ក្រែទេសនាធ្លាក់ជារូបពាជសីហ៍មានក្បាច់ចាំងពីលើផង, រទេះបំពោលសម្រាប់ទៅអធិការទិមន្ដទៅណាមកណា, ជូតសម្រាប់មន្ត្រីសង្ឃ, បាត្រសម្រាប់ព្រះសង្ឃទិមន្ដបិណ្ឌបាត្រ, ត្រាសម្រាប់វត្ត, ឈើច្រត់, ផ្ទាំងព្រះបដសាត្រាស្លឹករឹតនឹងសៀវភៅឯទៀតដែលមានក្របធ្វើអំពីឈើចម្លាក់;

ផ្នែកទីពីរ: វត្ថុនិងរូបភាព ដែលសុទ្ធតែជារបស់ជាប់ទាក់ទងនឹងទំនៀមទម្លាប់ ដូចជាក្បួនទំនាយ, ក្បួនមន្តអាគម, រូបគំនូរ ។ល។

ស.- សូមលោកអធិប្បាយពន្យល់អំពីរបស់ពីរមុខនេះឲ្យខ្ញុំបាន

ស្តាប់បន្តិច គឺអាវគេជៈនឹងពពិល ព្រោះរបស់នេះធ្វើឲ្យខ្ញុំចាប់ចិត្តចង់ដឹងណាស់?

ជ.— អាវគេជៈ អាវនេះធ្វើអំពីក្រណាត់សំពត់ធម្មតា មានពងខ្លូលាយ ៗ នៅលើផ្ទាំងអាវនោះទាំងសង្ខាងមានគូរយ័ន្ត នឹងគាថាបាលីផ្សេងៗ សរសេរជាក្បាច់លើអាវនោះ ។ អាវនេះកាលជាន់ដើម គេពាក់ចេញចម្បាំងដើម្បីកុំឲ្យគេបាញ់ត្រូវ ។

២.— ពពិល: ជាវត្ថុធ្វើអំពីសម្រិទ្ធ សម្រាប់ប្រើជាមង្គលក្នុងពិធីរៀបការ ដែលជាទំនៀមព្រាហ្មណ៍ នឹងក្នុងពេលបំបួសនាគ ។ ពពិលនេះ ខ្លះមានពងស្រួចដូចជាសន្លឹកពោធិ៍ ខ្លះមានពងមូល ហើយឆ្លាក់ជារូបភាពផ្សេងៗ ។ ពពិលនេះគេធ្វើសម្រាប់សុំពរព្រះឥន្ទ្រ ។

ស.— ចុះផ្នែកទី ៣ គឺអ្វីខ្លះ?

ជ.— ក្រោយបំផុតនេះ គឺទូរដាក់សៀវភៅ សម្រាប់ផ្សាយសៀវភៅសំខាន់ៗ ទាំងខាងផ្លូវលោក ទាំងខាងផ្លូវធម៌ ដែលបានបោះពុម្ពចេញពីក្រសួងនេះ ។

## កំណត់ជីង ប្រវត្តិការណ៍

# ពិធីបុណ្យគម្រប់ ២៥០០ ព្រះវស្សា នៃព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា

របស់ពុទ្ធសាសនបណ្ឌិត្យ

---

ក្នុងថ្ងៃទី ២៥ មករា ១៩៥៦ នៅមហាបន្ទប់នៃពុទ្ធសាសនបណ្ឌិត្យ ដែលមានទូសៀវភៅអមជុំវិញ ព្រមទាំងមានអគ្គិសនីទីនិងវីជនីសំយុងពីលើផាត់កំដៅមិនឲ្យចូលមកបាន មានធ្វើមហាសន្និបាតមួយ ដើម្បីកំណត់ទីសម្រាប់ធ្វើពិធីបុណ្យគម្រប់ ២៥០០ ព្រះវស្សា នាអង្គរវត្ត នៅថ្ងៃ ១៥ កើតខែពិសាខ ព.ស. ២៥០០, គ.ស. ១៩៥៧ តាមរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះឧបយុវរាជ នរោត្តម-សីហនុ ជាព្រះនាយក ទ្រង់តាំងគណៈកម្មការមួយក្រុមមានរដ្ឋមន្ត្រីក្រសួងធម្មការជាប្រធាន ។

ក្នុងវេលានោះគេសង្កេតឃើញ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណព្រះធម្មត្រៃលោកាចារ្យ កេត ចិតសីលោ តំណាងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ លោក ព៉យ-លុត តំណាងពុទ្ធិកសមាគម, លោក អ៊ុក-សាអៀម តំណាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, លោក ព៉យ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ, លោក ឡាំ-ថាញ់សី តំណាងរដ្ឋមន្ត្រីក្រសួង

ហិរញ្ញវត្ថុ, លោក ហាំ - សុង តំណាងរដ្ឋមន្ត្រីក្រសួងការបរទេស, លោក លឿង - ណាល់ តំណាងឯកឧត្តមរាជប្រតិភូប្រចាំខេត្តសៀមរាប, លោក ហែម - ចំរើន ចាងហ្វាងជាតិមន្ទីរទេសចរ, លោក មុំ-នាង អាចារ្យវត្តទណ្ឌលោម តំណាងខាងគណៈមហានិកាយ និងលោក ទន់ - កាន់ តំណាងខាងគណៈធម្មយុត្តិ បាននិមន្តបានអញ្ជើញទៅជួបជុំផង ។

លុះជួបជុំគ្នាហើយ លោក ទិញ - រ៉ាញ ប្រធានគណៈកម្មការ បានថ្លែងអំណរគុណចំពោះសម្តេច និងអស់លោកទាំងអស់ជាសមាជិក ដែលបាននិមន្ត បានអញ្ជើញតាមសេចក្តីនិមន្តនិងអញ្ជើញរបស់ក្រសួងធម្មការ ។ បន្ទាប់មក លោកប្រធានបានចាប់អធិប្បាយក៏យកប់អំពីដើមហេតុនៃការរៀបចំធ្វើពិធីបុណ្យនេះ ។ រួចហើយលោកប្រធានបានដាក់ជូនគណៈកម្មការពិនិត្យនិងសម្រេចនូវសេចក្តីគ្រោងដូចតទៅនេះ ៖

១.- កន្លែងដែលត្រូវធ្វើពិធីបុណ្យ :

លោក ទិញ - រ៉ាញ បានជំរាបទៅប្រជុំថា តាមព្រះទ័យសម្តេចព្រះឧបយុវរាជ ទ្រង់យល់ថាគួរធ្វើនៅអង្គរវត្ត ដែលជាអតីតទីក្រុងនៃប្រទេសកម្ពុជា ។ ចំពោះទីកន្លែងនេះ សមាជិកភាគច្រើន មានលោក លឿង - ណាល់ជាដើម បានថ្លែងនូវការពិបាកគ្រប់យ៉ាង ក្នុងការរៀបចំទទួលភ្ញៀវបរទេសដោយខ្វះទីលំនៅ ទឹកភ្លើងនិងកន្លែងបន្ទោបង់ ។ តែដោយគិតឃើញថាជាបុណ្យខាងព្រះពុទ្ធសាសនា ដែលព្រះមហាក្សត្រខ្មែរបានទ្រទ្រង់មកជាយូរយារហើយ គួរតែបង្ហាញនូវស្នាព្រះហស្តរបស់ព្រះអង្គឲ្យជនបរទេសបានឃើញផង គឺប្រាសាទអង្គរវត្ត ទើប

គណៈកម្មការបានសម្រេចជាឯកច្ឆន្ទ យល់ព្រមយកអគ្គិវត្តធ្វើជាកន្លែងធ្វើបុណ្យ ស្របទៅតាមព្រះយោបល់សម្តេចព្រះឧបយុវរាជ ។

២ – តាំងគណៈកម្មាធិការនាយកមួយ សំរាប់ចាត់ចែងរៀបចំពិធីបុណ្យ :

ដោយយល់ឃើញថាពិធីបុណ្យនេះ ជាពិធីបុណ្យមួយដែលត្រូវធ្វើឲ្យបានអឹកធឹកនោះ គណៈកម្មការបានរៀបចំឲ្យមានគណៈកម្មាធិការនាយកមួយ សម្រាប់ចាត់ចែងរៀបចំការគ្រប់ចំពូក ដោយមានសមាសភាពដូចតទៅ ៖

រដ្ឋមន្ត្រីក្រសួងធម្មការជាប្រធាន មានអនុប្រធាន ៥ រូបគឺ: សម្តេចសង្ឃតាំងពីរគណៈ, លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាងលោករដ្ឋមន្ត្រីក្រសួងសាធារណការ ឬក៏តំណាងលោកចាងហ្វាងជាតិមន្ទីរទេសចរ ហើយមានសមាជិកឯទៀតជាច្រើន គឺមានតំណាងព្រះបរមរាជវាំង ១ រូប, តំណាងមន្ទីរស្ដីការរដ្ឋមន្ត្រីដទៃទៀត ១ រូប, តំណាងនៅសៀមរាប ១ រូប, តំណាងរដ្ឋសភាពីររូប, តំណាងក្រុមប្រឹក្សាព្រះរាជអាណាចក្រពីររូប ទីងពុទ្ធសាសនិក ៤ រូប គឺខាងគណៈធម្មយុត្តិ ២ រូប ខាងគណមហានិកាយ ២ រូប ។

គណៈកម្មាធិការនាយកនឹងរៀបចំកម្មវិធី ព្រមទាំងតម្រូវដល់ក្រុមផ្សេង ៗ នៅក្រោមឱវាទគេឲ្យរៀបចំអនុគណៈកម្មាធិការ ដើម្បីជួយគ្រប់កិច្ចរៀបចំនេះ ។

៣ កាលបរិច្ឆេទដែលធ្វើបុណ្យនឹងចំនួនថ្ងៃ:

លោកប្រធានគណៈកម្មការ បានថ្លែងថាពុទ្ធសករាជប្រទេសឥណ្ឌា លង្កា និង ភូមា លឿនជាងពុទ្ធសករាជខ្មែរ, លាវ និងថៃ ១ ឆ្នាំ គេនឹងរៀបចំធ្វើពិធីបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនា នៅខែឧសភា ១៩៥៦ នេះ ចំណែកយើងខ្មែរ យើងនឹងធ្វើនៅឆ្នាំក្រោយ (១៩៥៧) គឺក្រោយឥណ្ឌា ១ ឆ្នាំ ។ ចំពោះកាលបរិច្ឆេទនេះ សម្តេចព្រះសង្ឃនាយកបានថ្លែងថា ពុំដឹងជាខាងណាខុសខាងណាត្រូវទេ តែកាលបរិច្ឆេទកំណត់ពាក់កណ្តាលព្រះពុទ្ធសាសនា សម្រាប់ប្រទេសខ្មែរយើង គឺៈនៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំរកា នព្វស័ក ព.ស. ២៥០០ គត់ ត្រូវនឹងថ្ងៃទី ១៣ ឧសភា ១៩៥៧ ប្រទេសកម្ពុជាយើងកំណត់ធ្វើបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនា ព្រមទាំងបុណ្យសម្ពោធឆ្លងព្រះចេតិយ ១ ដែលកំពុងកសាងសព្វថ្ងៃ នៅមុខស្ថានីយ៍រាជអយស្ម័យយាន ក្រុងភ្នំពេញជាអនុស្សាវរីយ៍ ។

ពិធីបុណ្យនេះនឹងធ្វើចំនួន ១៥ ថ្ងៃ ដោយកំណត់តាមពិធីបុណ្យកាលព្រះមហាសម្ពុទ្ធទ្រង់បរិនិព្វានដែលមានចំនួន ១៥ ថ្ងៃដែរ ។

៤.– អំពីប្រទេសត្រូវអញ្ជើញមកក្នុងពិធីបុណ្យៈ

គណៈកម្មាធិការបានគ្រោងថា នឹងអញ្ជើញប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចតទៅនេះ គឺ ឥណ្ឌា, លង្កា, ភូមា, នេប៉ាល់, ថៃ, លាវ, វៀតណាម, ជប៉ុន, មហាពោធិសមាគមនិងពុទ្ធិកសមាគមនៃប្រទេសខាងលើនេះ ព្រមទាំងពុទ្ធិកសមាគមប្រទេសបារាំង, អង់គ្លេស, អូស្ត្រាលី, ឥណ្ឌូណេស៊ី, អាល្លឺម៉ង់, អាមេរិក និងម៉ាឡេស៊ី ។ល។

ចំពោះការអញ្ជើញនេះ គណៈកម្មការបានសុំឲ្យក្រសួងធម្មការពិនិត្យមើលក្រៅពីប្រទេសខាងលើនេះ តើក្រែងមានប្រទេសណាខ្លះទៀតកាន់ព្រះពុទ្ធសាសនាឬមានពុទ្ធិកសមាគម ដើម្បីនឹងបញ្ចូលបន្ថែមក្នុងបញ្ជីទៀត ។

៥.– គ្រោងប្រាក់ចំណាយសំរាប់ធ្វើបុណ្យ:

រឿងប្រាក់ចំណាយ ទីប្រជុំបានញែកជាពីរផ្នែក:

ក) នឹងសុំពីរាជរដ្ឋាភិបាល ដែលគណៈកម្មាធិការនាយកនឹងគ្រោងចំនួនជាក្រោយ;

ខ) នឹងអំពាវនាវដល់ពុទ្ធសាសនិកជនទូទៅ គឺ:

១- ដោយសុំផ្ទាល់;

២- ដោយធ្វើសញ្ញាប័ត្របកោដ្ឋព្រះសារីរិកធាតុជាដើរ;

៣- ដោយធ្វើបុណ្យផ្សេងៗ ។

ចំពោះរឿងនេះគណៈកម្មការយល់ថា ពលរដ្ឋកម្ពុជាដែលរស់នៅសព្វថ្ងៃសុទ្ធតែជាអ្នកកសាងល្អ ទើបបានជួបនឹងឯករាជ្យពេញបរិបូណ៌ថ្មីៗដោយសារព្រះមហាក្សត្ររបស់ខ្លួន ហើយសុទ្ធតែមានសំណាងបានទាន់ពាក់កណ្តាលព្រះពុទ្ធសាសនាផង, បើទាន់ដូច្នេះ តើខេមរជនណានឹងបណ្តោយឲ្យពិធីបុណ្យរំលឹកពាក់កណ្តាលព្រះពុទ្ធសាសនានេះមិនរុងរឿងទៅកើត ។

៦.– កិច្ចការដែលត្រូវធ្វើ:

ពិតមែនតែជាភារៈលើគណៈកម្មាធិការនាយកដែលត្រូវចាត់ចែងតែ ទីប្រជុំបានគ្រោងការខ្វះទុកដូចតទៅ ៖

- ត្រូវរៀបចំទីកន្លែងធ្វើបុណ្យឲ្យបានសមរម្យ;
- ត្រូវរៀបចំធ្វើបុស្បុកដើម្បីដំកល់ព្រះសារីរិកធាតុ ដែលសុំយកមកពីប្រទេសលង្កា;
- រៀបចំទីលំនៅសំរាប់ទទួលភ្ញៀវបរទេស ភ្ញៀវក្នុងស្រុកដោយមានទឹក-ភ្លើង មន្ទីរបន្ទោបង់;
- រៀបចំសំអាតទីក្រុងសៀមរាប, ផ្លូវថ្នល់ទៅអង្គរ ទៅភ្នំក្រោម ទឹងបារាយណ៍ទឹកថ្លា ព្រោះទឹងមានភ្ញៀវបរទេសមកទស្សនាពុំខាន;
- ចាត់ចែងកន្លែងសំណាក់ដោយឡែក កន្លែងលក់ដូរដោយឡែក;
- រៀបចំបោះសៀវភៅអធិប្បាយ អំពីពិធីបុណ្យពាក់កណ្ដាលព្រះពុទ្ធសាសនា ។

ទីប្រជុំបានបញ្ចប់ដោយសេចក្ដីរីករាយ ហើយសូមឲ្យគណៈកម្មាធិការនាយកចាប់ផ្ដើមធ្វើឲ្យរួសរាន់ ដើម្បីចាត់ការឲ្យបានស្រួលក្រែងពុំទាន់ពេលវេលា ព្រោះ១ឆ្នាំបាយមិនជាយូរប៉ុន្មានឡើយ ។

# ពិធីបញ្ចប់កិច្ចសិក្សា

## ខាងវិជ្ជាគរុកោសល្យនៃសមណសាស្ត្ថាចារ្យ

### របស់ពុទ្ធសាសនបណ្ឌិត្យ

—▪—

កាលពីថ្ងៃអង្គារ ទី ១៤ កុម្ភៈ ១៩៥៦ វេលាម៉ោង ១៦,៣០ នាទី ក្នុងកំពែងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត មានធ្វើពិធីប្រគេនសញ្ញាប័ត្រ ដល់សមណសាស្ត្ថាចារ្យទាំងឡាយចំនួន ១៦១ ដោយបញ្ជាក់អំពីបញ្ចប់កិច្ចសិក្សាខាងវិជ្ជាគរុកោសល្យ ក្រោមអធិបតីភាពនៃលោក ទៀញ-ពាំញ រដ្ឋលេខាធិការក្រសួងធម្មការ ។

ក្នុងវេលានោះគេសង្កេតឃើញ សម្តេច ព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, ព្រះតេជព្រះគុណព្រះធម្មត្រៃលោកាចារ្យ កេត-បិតសីលោ ជាតំណាងព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ, លោក ម៉ី-នរសីហ៍, លោកហៃរ្យ លេខាធិការ ទី ២ នៃស្ថានទូតអាមេរិកាំង និងឥស្សរជនបរទេសឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយមិនបានរាប់នាមទាំងអស់ក្នុងទីនេះ ។

នៅឱកាសនៃការជួបជុំឥស្សរជនទាំងនោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត បានហាំងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត បានថ្វាយសុន្ទរកថាមួយដ៏វិសេស ដែលយើងស្រង់យកមកសំដែងនៅខាងមុខឥតមានកែប្រែ ។ បន្ទាប់មក លោក ទៀញ-ពាំញ មានប្រសាសន៍ក្នុងនាមនៃរដ្ឋាភិបាល សរសើរចំពោះសមណសាស្ត្ថាចារ្យទាំងឡាយ ដែល

សព្វព្រះទ័យបង្ហាត់បង្រៀន រួចរំលឹកនូវកិច្ចការដ៏ធ្ងន់ ដែលធ្លាក់មកលើសាស្ត្រាចារ្យទាំងឡាយដោយអនេកបរិយាយ ។ បន្ទាប់មកទៀតសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ បានថ្លែងសង្កថាមួយមានសេចក្ដីដ៏ខ្លី ដោយរំលឹកថា សុំឲ្យសាស្ត្រាចារ្យទាំងនោះ ខំយកចិត្តទុកដាក់បង្ហាត់បង្រៀនតាមមុខងាររបស់ខ្លួន ដើម្បីឲ្យបានជាទីស្រឡាញ់រាប់អាននៃអនាគតសិស្សទាំងឡាយ នឹងដើម្បីឲ្យគួរដល់សេចក្ដីរាប់អាននៃមាតុប្រទេស ។

ពិធីនេះបានចប់នៅវេលាម៉ោង ១៧, ១៥ ។

## សុន្ទរកថាព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

សូមក្រាបថ្វាយបង្គំដោយគោរពចំពោះសម្ដេច !

សូមជំរាបលោករដ្ឋលេខាធិការ នឹងអស់លោកទាំងឡាយ !

ការបង្រៀនវិជ្ជាគរុកោសល្យនេះ, កាលពីក្នុងខែវិច្ឆិកា ១៩៥៥ បានផ្ដើមធ្វើមួយលើកហើយ ចំពោះលោកអាចារ្យក្នុងសាលាបាលីរងចំនួន ១៣៧ រូប ដល់មកក្នុងខែមករា នឹង កុម្ភៈ ១៩៥៦ នេះ បានចាប់ធ្វើ ១ លើកទៀត ជាលើកទី ២ ចំពោះលោកអាចារ្យក្នុងសាលាបាលីរងចំនួន ១៦១ រួមទាំងពីរលើកជាចំនួនលោកអាចារ្យអ្នកសិក្សា ២៩៨ រូប ។

ការបង្រៀនទាំងពីរលើកនេះ ដែលបានសម្រេច ដោយអាស្រ័យសេចក្ដីឧបត្ថម្ភរបស់ក្រុមបេសកកម្មអាមេរិកាំង ក្នុងការជួយផ្ដល់ដោយតម្លៃនៃអាហារូបករណ៍ចំពោះព្រះសង្ឃទាំងនោះ ។ មិនតែប៉ុណ្ណោះ

ការបង្រៀននេះបានទទួលព្រះបរមរាជានុញ្ញាតអំពីសម្តេចព្រះឧបយុវរាជ កាលទ្រង់ជានាយករដ្ឋមន្ត្រីលើកមុន ។

ចំណែកគ្រូបង្រៀនវិជ្ជាគរុកោសល្យនេះ បានតម្រូវលើគ្រូក្នុងពុទ្ធិក-វិទ្យាល័យនេះខ្លះ ក្រសួងសិក្សាធិការជាតិបានចាត់អស់លោកខ្លះ ដែលមានចំណេះយ៉ាងជំនាញឲ្យមកជួយខ្លះ គ្រូទាំងអស់នេះ ក៏ត្រូវបានទទួលបំណាច់រង្វាន់អំពីក្រុមបេសកកម្មអាមេរិកាំង ដូចជាលោកអាចារ្យអ្នកសិក្សាទាំងនោះដែរ ។

ខ្ញុំព្រះករុណា អាត្មាភាព មានអំណរដ៏លើសលុបចំពោះព្រះគុណសម្តេច ដែលបាននិមន្តមកជាអធិបតីភាពនៃពិធីនេះ សូមទទួលអំណរដ៏ក្រៃលែងចំពោះលោករដ្ឋលេខាធិការ និងអស់លោកទាំងឡាយដែលបានអញ្ជើញមកជាមង្គលនិងជាកិត្តិយសដ៏ប្រសើរក្នុងពិធីនេះ សូមអរគុណចំពោះក្រុមបេសកកម្មអាមេរិកាំង ដែលមានសេចក្តីសប្បុរសជួយឲ្យបានសម្រេចការបណ្តុះបណ្តាលវិជ្ជាគរុកោសល្យដល់លោកអាចារ្យ នៅសាលាបាលីរងទាំងឡាយក្នុងព្រះរាជអាណាចក្រ សូមអរគុណចំពោះអស់លោកជាគ្រូបង្ហាត់បង្រៀនទាំងឡាយ ដែលបានខំយកចិត្តទុកដាក់បង្រៀនអស់រយៈកាល ១ ខែកន្លងទៅនេះ ។

ចំណែកអស់លោកអាចារ្យទាំងឡាយ ដែលបានចូលមកសិក្សានេះ ខ្ញុំសូមរំលឹក សូមឲ្យយកចិត្តទុកដាក់បង្ហាត់បង្រៀនសិស្សតទៅ ដើម្បីជួយឲ្យព្រះពុទ្ធសាសនា និងប្រទេសជាតិមានដំណើរទៅមុខបានដោយសុវត្ថិភាព ។

ម្យ៉ាងទៀតសញ្ញាប័ត្រដែលប្រគេនក្នុងកាលឥឡូវនេះ គ្រាន់តែជាគ្រឿងបញ្ជាក់ថា បានមកសិក្សាវិជ្ជាគរុកោសល្យប៉ុណ្ណោះឯង ហើយទុកសម្រាប់ជាអនុស្សាវរីយ៍តទៅ ។

ទីបំផុតនេះ សូមគុណព្រះរតនត្រ័យនឹងទេវតាគ្រប់ទិសទីជួយអភិបាលរក្សាសម្តេច លោករដ្ឋលេខាធិការនិងអស់លោកអ្នកទាំងឡាយឲ្យបានសុខចំរើនតរៀងទៅ ។

# ការប្រគល់ឲ្យជាឧឡារិកនូវព្រះធាតុ
# នៃព្រះសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ
# ទៅសមាគម "មហាពោធិ" នៅប្រទេសឥណ្ឌា

នៅចំណតអាកាសយានញូ-ដែលី លោកនេរុនាយករដ្ឋមន្ត្រីបានប្រគល់ព្រះធាតុនៃព្រះសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ចំនួន ៣ កោដ្ឋ ឲ្យទៅសមាគម "មហាពោធិ" ។ ពិធីបុណ្យនេះបានធ្វើជាឧឡារិកនៅទីចំណតអាកាសយានញូ-ដែលីតែម្តង ។ ព្រះធាតុទាំងនោះ គេបាននាំយកមកពីប្រទេសអង់គ្លេសដោយស្នាដៃនៃលោកស្រី "វិសាយ៉ា-ឡាកាមី" ជាឧត្តមស្នងការឥណ្ឌាប្រចាំប្រទេសអង់គ្លេស ។

នៅពេលដែលយន្តហោះមកដល់ គេសង្កេតឃើញលោកនេរុនាយករដ្ឋមន្ត្រី ព្រមទាំងវរជនជាច្រើននាក់នឹងអ្នកការទូតប្រទេសដទៃដែលកាន់ព្រះពុទ្ធសាសនា បានរង់ចាំទទួលព្រះធាតុទាំងនោះ ។ នៅក្នុងចំណោមវរជនទាំងអស់នោះ ឯកឧត្តម វ៉ា-កាមិល ជាឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសឥណ្ឌាបានមកប្រជុំក្នុងពិធីបុណ្យនេះដែរ ។

ព្រះធាតុទាំងនោះ គេបានរកឃើញនៅក្នុងចេតិយ ដែលឋិតនៅសញ្ជី តាំងពី គ. ស. ១៨៥៦ ហើយគេបាននាំយកទៅដំកល់ទុកនៅក្នុងវិរីធភណ្ឌដ្ឋាននៃប្រទេសអង់គ្លេស នៅក្នុងទីក្រុង «ឡុង» តាំងពី គ. ស. ១៨៨៧ ។ ឥឡូវ រដ្ឋាភិបាលឥណ្ឌាទើបនឹងទទួលនូវព្រះធាតុទាំងនោះពីទីចាត់ការនៃវិរីធភណ្ឌដ្ឋានអង់គ្លេសមកវិញ ។

គេបានដឹងថា នៅក្នុងកោដ្ឋទី ១ នឹងទី ២ មានបញ្ចុះព្រះធាតុនៃព្រះមហាវិនយ, ព្រះអបត្រីយ, ព្រះកោដិនិបុត្ត នឹងព្រះវដីសុរិដរត ។ នៅក្នុងកោដ្ឋទី ៣ មានព្រះធាតុនៃព្រះដោសេកបុត្ត, ព្រះគោតិបុត្ត នឹង ព្រះមោគល្លីបុត្ត ។

កាលណាគេបាននាំព្រះធាតុទាំងអស់នោះ ទៅដល់ទីកន្លែងដើមឯសញ្ជីវិញហើយ រដ្ឋាភិបាលឥណ្ឌាប៉ុរុងនឹងបង្ហាញកោដ្ឋទី ៣ ទៅរដ្ឋាភិបាលកោះសិរីលង្កាជាមិនខាន ។

នៅពេលឥឡូវនេះ សមាគម "មហាពោធិ" បានរៀបតាំងជាសាធារណៈនូវព្រះធាតុទាំងនោះ រួចហើយទើបនាំយកទៅដំកល់ទុកឯសញ្ជីតាមផ្លូវរទេះភ្លើង ។